ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

# សទ្ទានុក្រម
# វប្បធម៌ និង វិចិត្រសិល្បៈ
## ខ្មែរ-អង់គ្លេស-បារាំង

# LEXICON
# OF
# CULTURE AND FINE ARTS
## Khmer-English-French


ក្រុមប្រឹក្សាជាតិភាសាខ្មែរ

គណៈកម្មការវប្បធម៌ និង វិចិត្រសិល្បៈ

គណៈកម្មការវប្បធម៌

គណៈកម្មការវិចិត្រសិល្បៈ


សីហា ២០១៥


អាសយដ្ឋាន: មហាវិថីសហព័ន្ធរុស្ស៊ី, សង្កាត់កាកាប, ខណ្ឌពោធិ៍សែនជ័យ, រាជធានីភ្នំពេញ

ទូរសព្ទដៃ: (៨៥៥) ១២ ៩១១ ៣៥៧ / (៨៥៥) ១២ ៩០៦ ៥៨៥, អ៊ីមែល: info@nckl.gov.kh, គេហទំព័រ: www.nckl.gov.kh

# បុព្វកថា

ក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.) មានភារកិច្ចស្វែងរកឯកភាពឱ្យភាសាខ្មែរ ទាំងខាងអក្ខរាវិរុទ្ធ ទាំងខាងអំណាននិងទាំងខាងពាក្យពេចន៍។ ទន្ទឹមនឹងការស្វែងរកឯកភាពនេះ ក.ជ.ភ.ខ. ក៏មានតួនាទីអភិរក្សនូវពាក្យពេចន៍មួយចំនួនរបស់បុព្វបុរសខ្មែរជំនាន់ដើម ដែលបានខិតខំបង្កើតឡើង និងរក្សាទុកតៗមកអស់ជាច្រើនជំនាន់មកហើយដែរ។ ពាក្យពេចន៍ដែលទាក់ទងនឹងខ្នាតបុរាណរបស់ខ្មែរត្រូវបានស្រាវជ្រាវយកមកចងក្រង ដោយគណៈកម្មការបច្ចេកសព្ទវប្បធម៌ រហូតដល់មានការអនុម័តជាផ្លូវការពីសំណាក់ ក.ជ.ភ.ខ. ក្រោមការចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់របស់សម្តេច បណ្ឌិតសភាចារ្យ អគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង ជាគុរុគណៈនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ។

ការអភិរក្សពាក្យពេចន៍ដែលទាក់ទងនឹងវប្បធម៌និងវិចិត្រសិល្បៈ គឺជាផ្នែកមួយនៃការចូលរួមចំណែកអភិរក្សវប្បធម៌ ដែលជាអត្តសញ្ញាណនិងជាអាយុជីវិតដ៏មានតម្លៃមិនអាចខ្វះបានរបស់ជាតិនីមួយៗ សមដូចពាក្យទំនៀមមួយឃ្លាពោលថា «វប្បធម៌រលត់ ជាតិរលាយ វប្បធម៌ពណ្ណរាយ ជាតិថ្កុំថ្កើង»។

សទ្ទានុក្រមនៃពាក្យដែលគណៈកម្មការវប្បធម៌និងវិចិត្រសិល្បៈបានស្នើ និង ដែល ក.ជ.ភ.ខ. បានអនុម័តជាផ្លូវការជាឧបករណ៍សម្រាប់បង្ហាញអត្តសញ្ញាណជាតិខ្មែរ ដែលមានទេពកោសល្យក្នុងវិស័យសិល្បៈ។

សូមអ្នកស្រឡាញ់ភាសាជាតិទទួលយកសទ្ទានុក្រមនេះទៅប្រើប្រាស់ ដើម្បីស្វែងយល់ពីបច្ចេកសព្ទទាក់ទងនឹងវប្បធម៌និងវិចិត្រសិល្បៈរបស់ជាតិយើង។

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**និង ជាប្រធានកិត្តិយសនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ**

បណ្ឌិតសភាចារ្យ **សុខ អាន**

# អារម្ភកថា

ពាក្យទាក់ទងនឹងវប្បធម៌និងវិចិត្រសិល្បៈ ដែលមានក្នុងសទ្ទានុក្រមនេះត្រូវបានបោះពុម្ពផ្សាយតាមព្រឹត្តិបត្រម្តងហើយ ប៉ុន្តែព្រឹត្តិបត្រទាំងនោះ ត្រូវបានចែកផ្សព្វផ្សាយតែក្នុងមជ្ឈដ្ឋានថ្នាក់ដឹកនាំក្រសួងនានា មន្ទីរអប់រំខេត្ត ការិយាល័យអប់រំស្រុក/ក្រុង/ខណ្ឌ នាយកសាលា...។ ម្យ៉ាងទៀត ដើម្បីឱ្យក្រុមប្រឹក្សាជាតិភាសាខ្មែរ(ក.ជ.ភ.ខ.) ងាយអនុម័តពាក្យទាំងនោះ គណៈកម្មការវប្បធម៌និងគណៈ-កម្មការវិចិត្រសិល្បៈត្រូវផ្តល់ពាក្យគន្លឹះជាមុន ទោះពាក្យគន្លឹះនោះកើតចេញពីព្យញ្ជនៈណាក៏ដោយ ដើម្បីឱ្យងាយពន្យល់ពាក្យពាក់ព័ន្ធ។ ក្នុងសទ្ទានុក្រមនេះ ពាក្យដែលមានភាពប៉ាត់ប៉ោយក្នុងព្រឹត្តិបត្រត្រូវបានស្រង់មកតម្រៀបតាមលំដាប់អក្ខរក្រម ព្រមទាំងដាក់បច្ចេកសព្ទវប្បធម៌និងបច្ចេកសព្ទវិចិត្រ-សិល្បៈដោយឡែកពីគ្នា (បច្ចេកសព្ទវប្បធម៌មានចំនួន១៤៧ពាក្យ និង បច្ចេកសព្ទវិចិត្រសិល្បៈមានចំនួន២៧៥ពាក្យ)។

សទ្ទានុក្រមជាមធ្យោបាយផ្សព្វផ្សាយទី៣របស់យើង បន្ទាប់ពីព្រឹត្តិបត្រនិងគេហទំព័រ ហើយយើងសង្ឃឹមថា មធ្យោបាយនេះអាចផ្សព្វផ្សាយបានទូលំទូលាយជាងមធ្យោបាយមុនៗនៅក្នុងប្រទេសកម្ពុជា។

ក.ជ.ភ.ខ. មិនអាចដំណើរការបានទេ បើគ្មានការគាំទ្រជាថវិកាពីសំណាក់សម្តេច បណ្ឌិតសភាចារ្យ អគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង ជាគរុ-គណនៃ ក.ជ.ភ.ខ. តាមរយៈឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ជាប្រធានកិត្តិយសនៃ ក.ជ.ភ.ខ.។

អាស្រ័យហេតុនេះ ក្នុងនាម ក.ជ.ភ.ខ.ទាំងមូល ខ្ញុំបាទសូមថ្លែងអំណរគុណព្រមទាំងកតញ្ញូតាយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំខាងលើដែលជាអាណាព្យាបាលនៃ ក.ជ.ភ.ខ.យើង ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត។

រាជធានីភ្នំពេញ, ថ្ងៃ សុក្រ ទី ៣១ ខែ កក្កដា ឆ្នាំ២០១៥

**ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ**

បណ្ឌិតសភាចារ្យ **ច្រាំ ម៉ល់**

## សមាជិក
## គណៈកម្មការវប្បធម៌និងវិចិត្រសិល្បៈ

| | |
|---|---|
| ១- លោកសាស្ត្រាចារ្យបណ្ឌិត នូ ចាន់សុភី | ប្រធាន |
| ២- លោក ផុន កសិកា | អនុប្រធាន |
| ៣- លោកស្រីសាស្ត្រាចារ្យបណ្ឌិត ព្រុំ ទេវី | សមាជិក |
| ៤- លោក លឹម សុក្រាត | សមាជិក |
| ៥- លោក ហៀង លាងហុង | សមាជិក |
| ៦- លោកស្រី អ៊ឹង ម៉ាល័យ | សមាជិក |

**រៀបចំបោះពុម្ពផ្សាយដោយ ៖**

ផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្ដុះបណ្ដាល
នៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ

# សមាជិក
# គណៈកម្មការវប្បធម៌

| | |
|---|---|
| ១-ឯកឧត្តមបណ្ឌិត នូ ចាន់សុភី | ប្រធាន |
| ២- លោក ផុន កសិកា | អនុប្រធាន |
| ៣- លោកបណ្ឌិត គឹម ពីនន់ | អនុប្រធាន |
| ៤- លោក មាឃ សារី | សមាជិក |
| ៥- លោក ប្រែង ពិសិដ្ឋ | សមាជិក |
| ៦- លោកស្រី យ៉ាន់ វិភារតន៍ | សមាជិក |
| ៧- លោក គុយ រិន | ជំនួយខាងភាសា |
| ៨- កញ្ញា សុង ឧស្សាហ៍ | លេខាធិការ |
| ៩- លោក ព្រាប ចាន់ម៉ារ៉ា | សមាជិក |

## រៀបចំបោះពុម្ពផ្សាយដោយ ៖

ផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្តុះបណ្តាល
នៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ

# សមាជិក
# គណៈកម្មការវិចិត្រសិល្បៈ

| | |
|---|---|
| ១- ឯកឧត្តមបណ្ឌិតសភាចារ្យ តិច សំណាង | ប្រធាន |
| ២- ឯកឧត្តម ប៊ុត សុម៉េត | អនុប្រធាន |
| ៣- ឯកឧត្តមបណ្ឌិត ហ៊ឹម សុភី | សមាជិក |
| ៤- លោកបណ្ឌិត ធុយ ចាន់ធួន | សមាជិក |
| ៥- លោកបណ្ឌិត លី រស្មី | សមាជិក |
| ៦- លោក ហៀង លាងហុង | សមាជិក |
| ៧- លោកបណ្ឌិត ឈឹម សុខាន់ដារា | សមាជិក |
| ៨- លោក លឹម សុក្រាត | សមាជិក |
| ៩- លោក ឡេា សាន | សមាជិក |
| ១០- លោកស្រី កែវ ណារុំ | សមាជិក |
| ១១- លោក ជា សម្បត្តិ | សមាជិក |
| ១២- លោកស្រី ហង់ លក្ខិណា | ជំនួយខាងភាសា |
| ១៣- លោក គឹម សុវត្ថិ | សមាជិក |
| ១៤- លោក សឿរ សោភា | សមាជិក |
| ១៥- លោក ប៉ាង ចាន់ថា | សមាជិក |

## រៀបចំបោះពុម្ពផ្សាយដោយ ៖

ផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្តុះបណ្តាល
នៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ

# បច្ចេកសព្ទវប្បធម៌ និង ចចិត្រសិល្បៈ ដែលគណៈកម្មាធិការជាតិភាសាខ្មែរ / គ.ជ.ភ.ខ. (បច្ចុប្បន្ន ក្រុមប្រឹក្សាជាតិភាសាខ្មែរ / ក.ជ.ភ.ខ.) បានអនុម័ត

## ១- បច្ចេកសព្ទវប្បធម៌

| | |
|---|---|
| ១- កញ្ចើ | ខ្នាតវង្វាល់ខ្មែរពីបុរាណ សម្រាប់វាល់គ្រាប់ធញ្ញជាតិ វត្ថុល្អិតៗ ជាដើម ដែលត្បាញដោយបន្ទោះឫស្សី ខាងលើមានរាងមូល ហៅថា មាត់ ក្ដាប់នឹងបន្ទោះផ្ដៅ, ខាងក្រោមរាប ហៅថា បាត។ ឧ. អង្ករមួយកញ្ចើ។ |
| ២- កន្ដាំង | ខ្នាតវង្វាល់ខ្មែរពីបុរាណ (មានរាងដូចល្អី) សម្រាប់វាល់គ្រាប់ធញ្ញជាតិ មាន ស្រូវ អង្ករ ជាដើម, ជារង្វាល់អនុភាគ ដែលមានចំណុះពីរភាគឬបីភាគឬក៏បួនភាគនៃតៅ។ អ្នកខ្លះហៅថា ខ្ទឹង។ ឧ. ស្រូវបីកន្ដាំង។ |
| ៣- កម្បង់ | ខ្នាតវង្វាល់ខ្មែរពីបុរាណ ដែលប្រើបាតដៃទាំងពីរផ្ដុំគ្នាហើយផ្ងារ ធ្វើឱ្យដក់បន្តិច សម្រាប់ក្បង់គ្រាប់ធញ្ញជាតិតូចៗ ឬ វត្ថុអ្វីៗមានទំហំតូចល្អិតៗឬក៏ម៉ដ្ឋៗ ដាក់ពេញថ្នក់បាតដៃទាំងពីរនោះ។ ឧ. អង្ករពីរកម្បង់។ |
| **៤- ការការពារ**<br>អ. protection<br>បារ. protection (f.) | សកម្មភាពដែលតម្រូវឱ្យមានការកំណត់លក្ខខណ្ឌផ្សេងៗ ដើម្បីសង្គ្រោះបុរាណវត្ថុ សិល្បៈ ប្រាសាទបុរាណ ស្ថានីយបុរាណវត្ថុវិទ្យា តំបន់ |

| | |
|---|---|
| | ប្រវត្តិសាស្ត្រ និង ធនធានបេតិកភណ្ឌ ដើម្បីទប់ស្កាត់អំពើចោរកម្ម ការរំលោភ ការបំផ្លិចបំផ្លាញ រួមទាំងការបំផ្លាញពីធម្មជាតិ។<br>២. អាជ្ញាធរជាតិព្រះវិហាររៀបចំតំបន់ការពារដើម្បីអភិរក្សនិងអភិវឌ្ឍតំបន់ប្រាសាទព្រះវិហារ។ |
| **៥- ការបង្ការ**<br>អ. preservation<br>បារ. prévention ( f. ) | ការចាត់វិធានការចាំបាច់ផ្សេងៗ ដើម្បីថែរក្សាបុរាណវត្ថុ សិល្បៈ ប្រាសាទបុរាណ ស្ថានីយបុរាណវត្ថុវិទ្យា និង ធនធានបេតិកភណ្ឌឱ្យនៅគង់វង្ស។ |
| **៦- ការពង្រឹង**<br>អ. consolidation<br>បារ. consolidation ( f. ) | ការបិទ ការភ្ជិត ការលាប ... លើបុរាណវត្ថុផ្សេងៗ តាមរយៈការប្រើប្រាស់សារធាតុផ្សេងៗ ដើម្បីរក្សាទម្រង់បុរាណវត្ថុនោះឱ្យស្ថិតនៅគង់វង្ស។<br>២. ការពង្រឹងកុលាលភាជន៍បែកបាក់ មុននឹងយកទៅដាក់តាំងបង្ហាញ។ |
| **៧- ការតាក់តែងលម្អនិម្មាបនកម្ម/ការតាក់-តែងលម្អស្ថាបត្យកម្ម**<br>អ. architectural decoration<br>បារ. décoration ( f. ) architecturale | ការរចនាលើសំណង់អគារ ដើម្បីបង្កើនការទាក់ទាញឱ្យមានការចាប់អារម្មណ៍។ |

| | |
|---|---|
| **៨- ការអភិរក្ស**<br>អ. conservation<br>បារ. conservation (f.) | ការគ្រប់គ្រង ថែរក្សា ការពារ ដើម្បីប្រើប្រាស់ប្រកបដោយនិរន្តរភាពនូវបុរាណវត្ថុ សិល្បៈ ប្រាសាទបុរាណ ស្ថានីយបុរាណវត្ថុវិទ្យា និងធនធានបេតិកភណ្ឌ ឱ្យមានសុវត្ថិភាព ដើម្បីបញ្ចៀសហានិភ័យផ្សេងៗ។<br>ទស្សនៈទូទៅនៃពាក្យ "អភិរក្ស" ផ្ដោតលើការការពារផ្សេងៗដល់អគារ ស្ថានីយបុរាណ ទីក្រុងបុរាណ រួមមាន ការថែទាំ ការជួសជុល ការពង្រឹង និង ការបន្ថែមកម្លាំង។ |
| **៩- កុណ្ឌី** | ប្រដាប់ប្រើប្រាស់មួយប្រភេទ មានរាងដូចថូ ជាទូទៅមានចំពួយដូចកំសៀវ ធ្វើពីដីដុត ឬលោហៈ ដូចជា មាស ប្រាក់ សំរិទ្ធិ ស្ពាន់ ជាដើម ខ្លះមានរចនាវិចិត្រផ្សេងៗ ប្រើសម្រាប់ដាក់ទឹកជ្រួចក្នុងពិធីផ្សេងៗ។ |
| **១០- កុលាលភាជន៍**<br>អ. pottery<br>បារ. poterie (f.) | បុរាណវត្ថុសិល្បៈមានដូចជា ភាជន៍ដី, ចាន, ឆ្នាំងឬក្អមដែលធ្វើដោយដីឥដ្ឋដុតក្នុងសីតុណ្ហភាពខ្ពស់ សម្រាប់ដាក់ភោជនាហារ មានបាយ ទឹក ជាដើម។ |
| **១១- កុលាលភាជន៍រឹង**<br>អ. stoneware (pottery)<br>បារ. poterie en grès (f.) | កុលាលភាជន៍មួយប្រភេទដែលមានលក្ខណៈរឹងនិងមិនជ្រាបទឹក ដែលដុតក្នុងសីតុណ្ហភាពពី ១២០០ ទៅ ១៣៥០អង្សាសេ។ |

| | |
|---|---|
| **១២- កំប៉េះ** | សម្ភារៈប្រើប្រាស់មួយប្រភេទ រាងដូចថាស មានជើងភ្ជាប់ជាទម្រ ធ្វើពីឈើ បន្ទោះឬស្សី ផ្ដៅ រពាក់ ធាងត្នោត ជាដើម លាបម្រក្សណ៍ មានរចនាក្បាច់វិចិត្រ ប្រើសម្រាប់ដាក់របស់របរផ្សេងៗ។<br>ឧ. គេរៀបគ្រឿងតង្វាយព្រះមួយកំប៉េះក្នុងពិធីបុណ្យបច្ច័យបួន។<br>ឧ. ដូនជីរៀបផ្លែឈើមួយកំប៉េះប្រគេនព្រះ-សង្ឃ។<br> |
| **១៣- កំពែង**<br>អ. rampart<br>បារ. rempart ( m. ) | សំណង់ការពារធ្វើពីដី ពីឥដ្ឋ ឬពីថ្ម ដែលលើកព័ទ្ធជុំវិញក្រុង, បន្ទាយ, វាំង, ប្រាសាទជាដើម។<br>ឧ. កំពែងក្រុងអង្គរបុរីសង់ពីឥដ្ឋ។ |
| **១៤- ក្ដាប់** | ខ្នាតរង្វាល់ខ្មែរពីបុរាណ ប្រើម្រាមដៃម្ខាងរួបក្រសោបបិទ សម្រាប់ចាប់គ្រាប់ធញ្ញជាតិតូចៗ ឬវត្ថុអ្វីៗមានទំហំតូចល្អិតៗឬក៏ម៉ដ្ឋៗ។<br>ឧ. អង្ករមួយក្ដាប់។ |

| | |
|---|---|
| **១៥- ក្ដារបែន**<br>អ. Kda Ben<br>( cruciform platform ) | ឈ្មោះព្រះលានមួយដែលមានសណ្ឋានជាជើងក្អែកតភ្ជាប់ពីស្ពានហាលទៅគោបុរនៃខ្លោងទ្វារធំប្រាសាទ។ ក្ដារបែន គឺសម្រាប់ព្រះមហាក្សត្រទទួលនាម៉ឺនសព្វមុខមន្ត្រីនិងសម្រាប់ទតក្បួនដង្ហែផ្សេងៗក្នុងពិធីបុណ្យ។<br>ឧ. ប្រដាប់ជាឋាន ក្ដារបែនសោតមាន<br>បស្ចិមទិសា រោងរម្យកក្លាក<br>ស្អាងស្អាតសោភា សឹងថ្មសិលា<br>ប្រកិតក្រាស់ក្រៃ។<br>( ដកស្រង់ពីល្បើកអង្គរ ក្នុងវគ្គទី១៣៣ ) |
| **១៦- ក្លង** | ប្រដាប់ប្រើប្រាស់មួយប្រភេទ មានរាងជាបំពង់ខ្លីៗ មានគម្រប មានសណ្ឋានដូចក្លាក់ ធ្វើពីបំពង់ឫស្សី ឈើ ភ្លុក ឬ លោហៈ ប្រើសម្រាប់ដាក់ក្រមួន ប្រេង ម្សៅ ឬ របស់ផ្សេងៗ ដូចជាគ្រឿងអលង្ការជាដើម។ បច្ចុប្បន្ន ក្លងមានទ្រង់ទ្រាយច្រើនយ៉ាង ដូចជា រាងមូល ជ្រុងជាដើម។ |
| **១៧- ក្លាក់** | ប្រដាប់ប្រើប្រាស់មួយប្រភេទមានរាងជាបំពង់ ឬមានសណ្ឋានប្រហាក់ប្រហែលបំពង់ មានគម្រប ធ្វើពីបំពង់ឫស្សី ឈើ ស្នាច់ក្រដាស ឬ លោហៈផ្សេងៗ ហើយ ខ្លះមានក្បាច់រចនាវិចិត្រ មានទំហំខុសៗគ្នា ប្រើសម្រាប់ប្រក |

| | |
|---|---|
| | របស់ផ្សេងៗ ដូចជា លិខិត ទៀន ធូប បារី ម្ហូល។ល។<br>៤. ភ្លាក់ព្រះរាជសារ។<br>  |
| **១៨- គក់ / ហត្ថក្រពុំ** | រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ ដោយគិតពីត្រឹមកែងដៃទៅដល់គល់ម្រាមកូនដៃដែលក្ដាប់ក្ដោបចូល ដោយមានប្រវែងប្រហាក់ប្រហែល ១៦អ៊ិញ (ប្រហែល៤០,៦២៤សង់ទីម៉ែត្រ)។<br>**បញ្ជាក់** : *១អ៊ិញ ប្រវែងប្រហែល ២,៥៣៩ សង់ទីម៉ែត្រ។* |
| **១៩- គាវុត** | រង្វាស់ប្រវែងខ្នាតខ្មែរពីបុរាណ ដែលមានប្រវែង ២០០០ព្យាម ឬ ១០០សិន ស្មើនឹង ៤០០០ ម៉ែត្រ។ |
| **២០- គូ / គូទឹក**<br>អ. moat<br>បារ. douve ( f. ) | សំណង់ស្នាមភ្លោះបុរាណព័ទ្ធជុំវិញបន្ទាយ, វាំង, ប្រាសាទ, វត្តឬភូមិ; ពាក្យបុរាណ ហៅ កសិណ ដូចយ៉ាង កសិណព័ទ្ធជុំវិញអង្គរវត្ត ជាដើម។ |

| | |
|---|---|
| **២១- គូ** | ខ្នាតឯកតាខ្មែរពីបុរាណ ដែលកំណត់ចំនួនពីរផ្ទឹមគ្នា។<br>ឧ. សត្វលលកមួយគូ, ស្បែកជើងមួយគូ, ចង្កឹះមួយគូ។ |
| **២២- គ្រុះ** | ប្រដាប់ប្រើប្រាស់ត្បាញពីបន្ទោះឫស្សី មានរាងក្រឡូម ស្មើរស្មើលើស្មើក្រោម មាត់មូល មានកណ្ដាប់ធ្វើពីបន្ទះឫស្សី ច្រើនក្ដាប់នឹងចម្រៀកផ្ដៅ មានសើមចម្រៀកឫស្សីនៅពីខាងលើ ហើយ បាតខាងក្រោមរាងបួនជ្រុងភ្ជាប់នឹងចម្រៀកឫស្សីខ្វែងគ្នាទ្រពីក្រោម ហៅថា ជើងគ្រុះ។ គ្រុះលាបជ័រទឹក គេប្រើសម្រាប់ដាក់ទឹក និងដងទឹក។<br>  |
| **២៣- គ្រឿងដីដុតរឹង**<br>អ. stoneware | ប្រភេទមួយនៃសេរ៉ាមិក ដែលមានលក្ខណៈរឹងនិងមិនជ្រាបទឹក ដែលដុតក្នុងសីតុណ្ហភាពពី ១២០០ ទៅ ១ ៣៥០អង្សាសេ។ |
| **២៤- ង៉ារ** | ខ្នាតរង្វាស់ពីបុរាណ ដែលមានផ្ទៃដីទំហំ ១០ ព្យាម៤ជ្រុង ត្រូវជា ១០០ព្យាមក្រឡា,ប្រហែល |

| | |
|---|---|
| | ២០ម៉ែត្រ៤ជ្រុង ឬ ៤០០ម៉ែត្រការ៉េ។<br>ឧ. ភ្ជួរស្រែមួយព្រឹកបានពីរងារ។ |
| **២៥- ចង្អុលដៃ** | រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ ដោយគិតពីត្រឹមចុងមកដល់គល់ម្រាមចង្អុលដៃ។<br>ឧ. យប់មិញទឹកស្រកមួយចង្អុលដៃ។ |
| **២៦- ចាប់** | ខ្នាតរង្វាស់ទំហំខ្មែរពីបុរាណ ដែលគេអាចក្ដោបពេញបាតដៃ(ដោយគិតពីចុងម្រាមមេដៃដល់ចុងម្រាមចង្អុលខ្ទោចទៅលើរបស់ផ្សេងៗបានមួយជុំ។<br>ឧ. ស្មៅមួយចាប់។ |
| **២៧- ចឹប** | ខ្នាតរង្វាល់ខ្មែរពីបុរាណ ប្រើចុងម្រាមដៃម្ខាងរួបប្រួមផ្គុំគ្នា ច្បិចគ្រាប់ធញ្ញជាតិតូចៗ ឬវត្ថុអ្វីៗមានទំហំតូចល្អិតៗ ឬក៏ម៉ដ្ឋៗ។<br>ឧ. អំបិលមួយចឹប។ |
| **២៨- ចុង** | ខ្នាតខ្មែរបុរាណ ដែលមានទម្ងន់កន្លះហាប ឬ៥០នាឡិ(ប្រហែល ៣០គីឡូក្រាម)។<br>ឧ. អង្ករមួយចុង។ |
| **២៩- ចំអាម** | រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ ដោយគិតត្រឹមចុងមេដៃទៅចុងម្រាមដៃកណ្ដាលដែលញែកតឹងកន្ទែកពីគ្នា។ មួយចំអាមប្រវែងកន្លះហត្ថឬប្រហែល ២៥សង់ទីម៉ែត្រ។ |

| | |
|---|---|
| **៣០- ជ័យតដាក/<br>វាលរាជដាក**<br>អ. Jayatataka | ឈ្មោះតដាកដែលសាងនៅសតវត្សរ៍ទី១២ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧(១១៨១-១២២០?) ទំហំ ៣.៥គ.ម. x ១គ.ម. ដែលមានប្រាសាទនាគព័ន្ធសង់នៅចំកណ្ដាល។ បច្ចុប្បន្ន អ្នកស្រុកនៅតំបន់អង្គរច្រើនហៅ វាលរាជដាក។ |
| **៣១- ជី** | ខ្នាតខ្មែរពីបុរាណ ដែលមានទម្ងន់ ១/១០តម្លឹង ឬ១០ហ៊ុន ប្រមាណ៣,៧៥ក្រាម។<br>ឧ. មាសមួយជី។ |
| **៣២- ជើងស្រាពក៍** | ជើងទម្រផ្ដិលធ្វើពីលោហៈឬវត្ថុជាតុនានាដែលផ្នែកខាងលើរាងមូលក្រឡូមដែលខ្លះមានរចនាក្បាច់វិចិត្រ ប្រើសម្រាប់ទ្រផ្ដិលឬដាក់របស់របរក្នុងពិធីផ្សេងៗ។<br>ឧ. អាចារ្យរៀបផ្កាស្លាដាក់លើជើងស្រាពក៍។<br><br> |
| **៣៣- ជើងអាធារ** | ប្រដាប់ប្រើប្រាស់មួយប្រភេទធ្វើពីឈើ មានជើងខ្វែងគ្នា ប្រើសម្រាប់ទ្រគម្ពីរសាស្ត្រាផ្សេងៗ។ ជើងអាធារទាបសម្រាប់ទ្រគម្ពីរសាស្ត្រាដើម្បីរៀន គេហៅថា «ជើងអាធាររៀន»។ ជើងអាធារ |

| | |
|---|---|
| | ខ្ពស់ច្រើនមានក្បាច់រចនាវិចិត្រផ្សេងៗ សម្រាប់ទ្រគម្ពីរសាស្ត្រា ដាក់ពីមុខគ្រែទេសន៍ ដើម្បីព្រះសង្ឃសម្ដែងធម្មទេសនា គេហៅថា «ជើងអាធារទេសន៍»។<br>   |
| **៣៤- ជំហាន** | រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ ដែលមានប្រវែងមួយជំហានឈានដើរ ដោយគិតពីត្រឹមកែងជើងក្រោយទៅដល់កែងជើងមុខ (ជំហានមានពីរ គឺ ជំហានធម្មតា និង ជំហានតឹង)។<br>ឧ. ក្បាលដីនេះមាន១៥ជំហាន។ |
| **៣៥- ជន្លាប់** | ប្រដាប់ប្រើប្រាស់មួយប្រភេទ មានរាងជាប្រអប់តូចៗ មានគម្រប មានសណ្ឋានមូលត្រមៀច ធ្វើពីដីដុត ឈើ ភ្លុក ឬ លោហៈ ប្រើសម្រាប់ដាក់ក្រមួន ម្សៅ ឬ គ្រឿងអលង្ការផ្សេងៗ។<br>ឧ. ក្រមួនមួយជន្លាប់។<br>  |

| | |
|---|---|
| **៣៦- ដឹក** | រង្វាស់រង្វាល់ខ្មែរពីបុរាណ សម្រាប់វាល់ស្រូវ ចំណុះ ២០ថាំង ដែលអាចដឹកបានដោយរទេះគោឬក្របី។<br>ឧ. ស្រូវមួយដឹក។ |
| **៣៧- ដំប** | ខ្នាតឯកតាខ្មែរពីបុរាណ ដែលជាទូទៅកំណត់ចំនួនពីរគូឬចំនួន៤។ ពាក្យសម្រាប់ប្រើរាប់ផ្លែឈើ កណ្ដាប់សំណាប ឬ សត្វតូចៗ។<br>ឧ. ផ្លែស្វាយបីដំប ឬ ស្វាយ១២ផ្លែ។ |
| **៣៨- តក់** | ខ្នាតរង្វាល់ខ្មែរពីបុរាណ ធ្វើពីត្រឡោកដូងតក់ ឬដូងក្លៀបឬក៏ដូងស្ដ មានទំហំតូចជាងនាឡិបន្តិច ប្រើសម្រាប់វាល់អង្ករ។ ជួនកាលគេហៅនាឡិតូច ក៏បាន។<br>ឧ. អង្ករបីតក់។ |
| **៣៩- តដាក**<br>អ. water reservoir | បឹងធំដែលកើតឡើងដោយការលើកដីជាទំនប់ព័ទ្ធជុំវិញរាងបួនជ្រុង។ លុះតយូរមកដល់សព្វថ្ងៃនេះ តដាក ហៅក្លាយជា ប៉ដាក ឬ ប្រដាក។ ពាក្យ តដាក ជាពាក្យបុរាណដែលមានចារក្នុងសិលាចារឹកសម័យអង្គរ (K. 598 B: 7, K. 933:24, K. 265 N: 5)។<br>ឧ. ព្រះរាជាក្នុងសម័យអង្គរបានកសាងតដាកជាច្រើននៅក្នុងតំបន់អង្គរ។ |

| | |
|---|---|
| **៤០- តម្លឹង** | ខ្នាតខ្មែរពីបុរាណ ដែលមានទម្ងន់ ១/១៦នាឡិ ឬ១០ជី ប្រមាណ ៣៧,៥ក្រាម ។<br>ឧ. មាសពីរតម្លឹង។ |
| **៤១- តយ** | ប្រដាប់ឬឧបករណ៍ធ្វើពីបំពង់ឫស្សីប្រើសម្រាប់វាល់វត្ថុរាវ ហើយ ដែលមានចំណុះ ១/៤លីត្រ ឬ១/២លីត្រ។<br>ឧ. ទឹកត្នោតជូរឬផ្អែមពីរតយ។ |
| **៤២- តុ** | ពាក្យវប្បធម៌មិនសម្គាល់ន័យដូចតុធម្មតាទេ គឺសម្គាល់សម្ភារៈប្រពៃណីប្រភេទជាថាស មានជើងធ្វើពីលោហៈ ឈើ រពាក់ ជាងត្នោត ជាដើម មានរចនាក្បាច់វិចិត្រ ដែលផ្នែកខាងលើរាងមូលសំប៉ែតឬមូលក្រឡូម  មានទំហំធំជាងជើងពាន ប្រើសម្រាប់ដាក់របស់របរក្នុងពិធីផ្សេងៗ។<br>ឧ. តុតម្កល់ក្រាំង។<br>  |
| **៤៣- តួ**<br>អ. character<br>បារ. personage<br>( m. ) | មនុស្ស សត្វ វត្ថុ រុក្ខជាតិ ដែលសម្ដែងដោយតំណាងឱ្យសភាវៈផ្សេងៗ នៅក្នុងរឿងល្ខោន នៅក្នុងទម្រង់សិល្បៈណាមួយដែលបង្កើតឡើងដោយអ្នកនិពន្ធ។<br>ឧ. លោក អៀង ស៊ីថុល ដើរតួជាតួនេនទុំ ក្នុងរឿងទុំទាវ។ |

| | |
|---|---|
| **៤៤- តួតុក**<br>**អ.** comedian, comic<br>**បារ.** comédien (m.) | មនុស្ស សត្វ វត្ថុ រុក្ខជាតិ ដែលធ្វើឱ្យអ្នកស្ដាប់ អ្នកទស្សនា សើចសប្បាយតាមរយៈការសម្ដែងកាយវិការ ពាក្យសម្ដី បទចម្រៀង... ដែលកំណត់ដោយអ្នកនិពន្ធ និង អ្នកដឹកនាំរឿង នៅក្នុងសិល្បៈទស្សនីយភាព ជាពិសេស ល្ខោនយីកេ និង ល្ខោនបាសាក់។<br>ឧ. លោកគ្រូ អ៊ុច សំអុល ហៅ តាប៉ោក និង លោក ព្រីង សាយន គឺជាតួតុកដ៏ល្បីនៅក្នុងល្ខោនយីកេរឿងទុំ ទាវ (នាទសវត្សរ៍ទី៨នៃសតវត្សរ៍ទី២០)។ |
| **៤៥- តួនាង**<br>អ. Tour Neang (female role dancer)<br>បារ. danseur role (m.) | ពាក្យសម្រាប់ហៅអ្នកសម្ដែងជាតួស្រីនៅក្នុងល្ខោនព្រះរាជទ្រព្យខ្មែរ ឬ ល្ខោនក្បាច់បុរាណខ្មែរ និង របាំព្រះរាជទ្រព្យខ្មែរ ឬ របាំក្បាច់បុរាណខ្មែរ។ ដើម្បីដើរតួនាង គ្រូបង្ហាត់ល្ខោនព្រះរាជទ្រព្យខ្មែរជ្រើសរើសសិល្បការិនីដែលមានរាងតូចស្ដើងនិងមានសម្ផស្សជានារីខ្មែរ។<br>ឧ. សិល្បការិនីនេះសម្ដែងជាតួនាង ក្នុងរឿងរាមកេរ្ដិ៍ជាព្រះនាងសីតា។ |
| **៤៦- តួនាយរោង** | ពាក្យសម្រាប់ហៅអ្នកសម្ដែងជាតួប្រុសនៅក្នុងល្ខោនព្រះរាជទ្រព្យខ្មែរនិងរបាំព្រះរាជទ្រព្យខ្មែរ។ ព្រះរាម ព្រះលក្ស្មណ៍ ជាតួនាយរោង។ |

| | |
|---|---|
| **៤៧- តួបន្ទាប់បន្សំ**<br>**អ**. extra role<br>**បារ**. figurant ( m. ) | មនុស្ស សត្វ វត្ថុ រុក្ខជាតិ ដែលសម្តែងជាតួក្រៅពីតួឯកនិងតួរង នៅក្នុងរឿងណាមួយ។<br>ឧ. នៅក្នុងល្ខោនយីកេរឿងទុំទាវ មានតួបន្ទាប់បន្សំជាច្រើន ដូចជា តួកីលៀង តួអាមាត្យ តួអ្នកស្រុក ជាដើម។ |
| **៤៨- តួរង**<br>អ. second role<br>បារ. second rôle / rôle secondaire ( m. ) | មនុស្ស សត្វ វត្ថុ រុក្ខជាតិ ដែលសម្តែងជាតួសំខាន់បន្ទាប់ពីតួឯក នៅក្នុងរឿងណាមួយ។<br>ឧ. លោក សម ម៉ាលី ជាអតីតសិល្បករនៅនាយកដ្ឋានសិល្បៈនិងទស្សនីយភាព សម្តែងជាតួរង( តួនេនពេជ្រ )នៅក្នុងល្ខោនយីកេរឿងទុំទាវ ក្នុងទសវត្សរ៍ទី៨នៃសតវត្សរ៍ទី២០។ |
| **៤៩- តួសម្តែង**<br>អ. actor, actress<br>**បារ.** acteur ( m. ), actrice ( f. ) | សិល្បករ សិល្បការិនី ដែលសម្តែងនៅលើឆាក ទូរទស្សន៍ វិទ្យុ និង ភាពយន្ត... ដោយប្រើប្រាស់ចលនាកាយវិការ ពាក្យពេចន៍ ចម្រៀង ការរាំ និង ការប្រគំតន្ត្រីបង្កើតឡើងដោយអ្នកដឹកនាំរឿង។ តួសម្តែងប្រុស (actor), តួសម្តែងស្រី (actress)។<br>ឧ. លោក សាំង សារុន សម្តែងជាតួព្រះធិនវង្ស នៅក្នុងល្ខោនបាសាក់ រឿងព្រះធិនវង្ស និង នាងពៅ។ |
| **៥០- តួឯក**<br>អ. principle role<br>បារ. rôle principal / premier rôle ( m. ) | មនុស្ស សត្វ វត្ថុ រុក្ខជាតិ ដែលសម្តែងជាតួសំខាន់ជាងគេ នៅក្នុងរឿងណាមួយ។<br>ឧ. លោក សាំង សារុន សម្តែងជាតួឯក (ឈ្មោះព្រះធិនវង្ស )នៅក្នុងល្ខោនបាសាក់ រឿងព្រះធិនវង្ស និង នាងពៅ។ |

| | |
|---|---|
| **៥១- តៀប** | ប្រដាប់មួយប្រភេទមានរាងមូលក្រឡូម មានជើងជាទម្រ មានគម្របធ្វើពី ឈើ ធាងត្នោត លោហៈ ឬ ស្មាច់ ហើយ លាបម្រក្សណ៍ (បើធ្វើពីលោហៈ មិនលាបម្រក្សណ៍ទេ) មានរចនាវិចិត្រ ប្រើសម្រាប់ដាក់របស់របរក្នុងពិធីផ្សេងៗ។<br>ឧ. កូនអណ្ដើកកាន់តៀបហែកំណាត់ក្នុងពិធីមង្គលការ។<br>   |
| **៥២- តោក** | ប្រដាប់មួយប្រភេទមានរាងក្រឡូម (មូលឬជ្រុងៗ) ជ្រៅជាងតុ មានជើងទម្រខ្ពស់បន្តិច ធ្វើពីឈើ ធាងត្នោត លោហៈ ឬ ស្មាច់ ហើយ លាបម្រក្សណ៍ (បើធ្វើពីលោហៈ មិនលាបម្រក្សណ៍ទេ) មានរចនាក្បាច់វិចិត្រទឹបមាស ដាំខ្យង ឬ ដាំកញ្ចក់ ប្រើសម្រាប់ដាក់របស់របរក្នុងពិធីផ្សេងៗ។<br>ឧ.គេប្រើតោកដាក់គ្រឿងសក្ការៈក្នុងពិធីបញ្ជាន់អារក្ស។<br>  |

| | |
|---|---|
| **៥៣- តៅ** | រង្វាស់រង្វាល់ខ្មែរពីបុរាណសម្រាប់វាល់គ្រាប់ធញ្ញជាតិ មានស្រូវ អង្ករ ជាដើម។ ស្រូវ១តៅមានទម្ងន់ ១២គីឡូក្រាម, អង្ករមួយតៅមានទម្ងន់ ១៥គីឡូក្រាម។ |
| **៥៤- ត្របក** | ខ្នាតឯកតាខ្មែរពីបុរាណសម្រាប់រាប់ស្លឹកម្លូមួយដុំ ដែលមានចំនួន១០ស្មើ គឺ ២០សន្លឹក។ ឧ. ម្លូមួយត្របក។ |
| **៥៥- ថង់រង** | ប្រដាប់ប្រើប្រាស់មួយប្រភេទ មានសណ្ឋានស្រដៀងនឹងហិបស្លា តែ ខ្ពស់ជាង មានគម្របមានរាងបួនជ្រុង ប្រាំមួយជ្រុង... ធ្វើពីឈើ ធាង ត្នោត ឬ លោហៈ មានក្បាច់រចនាវិចិត្រ ប្រើសម្រាប់ដាក់ទ្រគ្រឿងម្លូស្លាក្នុងពិធីផ្សេងៗ ជាពិសេសក្នុងពិធីអាពាហ៍ពិពាហ៍។  |
| **៥៦- ថាស** | ប្រដាប់ប្រើប្រាស់មួយប្រភេទរាងមូល មានបាតរាបស្មើ គែមខ្ពស់បន្តិច មានជើងឬឥតជើង ធ្វើពីលោហៈផ្សេងៗ ជ័រ។ល។ មានរចនាវិចិត្រ ខ្លះលាបពណ៌និងគូររូបផ្សេងៗ ប្រើសម្រាប់ទ្រចានដាក់ភោជនាហារ ឬ ប្រើដាក់របស់របរក្នុងពិធីផ្សេងៗ ជាដើម។ បច្ចុប្បន្ន ថាសមានរាង |

| | |
|---|---|
| | ផ្សេងៗ ដូចជា រាងជ្រុង រាងពងក្រពើ។ល។<br>ឧ. កូនចៅរៀបសំណែនមួយថាស សែនជូនតា។<br>  |
| **៥៧- ថាំង** | រង្វាស់រង្វាល់ខ្មែរពីបុរាណដែលមានចំណុះស្មើពីរតៅ។<br>ឧ. ស្រូវបីថាំង។ |
| **៥៨- ថាំងតែ / ក្បាក់** | ប្រដាប់ប្រើប្រាស់មួយប្រភេទរាងមូល មានបាតរាបស្មើ គែមខ្ពង់បន្តិចដូចថាស ធ្វើពីឈើ មានរចនាវិចិត្រ ប្រើសម្រាប់ដាក់ប៉ាន់និងពែងតែ។ ថាំងតែអាចប្រើសម្រាប់ដាក់របស់របរក្នុងពិធីផ្សេងៗក៏បាន។<br>ឧ. គេប្រើថាំងតែសម្រាប់ដាក់ផ្លែឈើ។<br> |
| **៥៩- ថ្នាំងដៃ** | រង្វាស់ប្រវែងខ្មែរនៃខ្នាតខ្មែរពីបុរាណដោយគិតពីត្រឹមចុងចង្អុលដៃមកត្រឹមគន្លាក់ដំបូង។<br>ឧ. សំណាបទើបដុះបានមួយថ្នាំងដៃ។ |
| **៦០- ទូកដៃ** | ខ្នាតរង្វាល់ខ្មែរពីបុរាណដែលប្រើបាតដៃម្ខាងដាក់ផ្ងារធ្វើឱ្យដក់បន្តិច សម្រាប់ចូកវាល់គ្រាប់ |

| | |
|---|---|
| | ធញ្ញជាតិតូចៗ ឬ វត្ថុអ្វីៗមានទំហំតូចល្អិតៗ ឬក៏ម៉ដ្ឋៗ ដាក់ពេញថ្នក់បាតដៃនោះ។<br>ឧ. គ្រាប់ល្ងមួយទូកដៃ។ |
| **៦១- ទែរ៉ាកូតា**<br>**អ.** terra cotta<br>**បារ.** terre cuite ( f. ) | សេរ៉ាមិកមួយប្រភេទជាគ្រឿងដីដុតដែលដុតនៅក្នុងសីតុណ្ហភាពក្រោម ៩០០អង្សាសេ ហើយ មានភាពស្ពោត(មិនហាប់)។ គេប្រើវាសម្រាប់ផលិតវត្ថុសិល្បៈ ដូចជា ផើងផ្កា ផែនរូបភាពផ្សេងៗ គ្រាប់លញ់ ត្រល់ ជើងសំណាញ់ ជាដើម។ បច្ចុប្បន្ន ទែរ៉ាកូតាជាវត្ថុសិល្បៈធ្វើដីឥដ្ឋ មានដូចជា បដិមានិងសម្ភារៈសំណង់ ជាដើម។ |
| **៦២- ទោម** | រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ ដោយគិតពីត្រឹមចុងមេដៃទៅចុងចង្អុលដៃដែលញែកឱ្យតឹងកន្ទែកពីគ្នា។<br>ឧ. កំណាត់សំពត់ប្រវែងប្រាំពីរទោម។ |
| **៦៣- ទះ** | ខ្នាតរង្វាស់ប្រវែងខ្មែរពីបុរាណដោយគិតប្រវែងទទឹងបាតដៃផ្គាប់។<br>ឧ. កំណាត់សំពត់រហែកប្រវែងមួយទះដៃ។ |
| **៦៤- ទ្រទូង** | ខ្នាតរង្វាស់កម្ពស់ខ្មែរពីបុរាណ ដែលគិតពីចុងជើងជំទើតត្រង់ ទៅចុងម្រាមដៃដែលលើកឡើងលើ។<br>ឧ. ទឹកជម្រៅពីរទ្រទូង។ |

| | |
|---|---|
| **៦៥- ផ្ទាប់** | ខ្នាតរង្វាស់ប្រវែងខ្មែរពីបុរាណ ដោយគិតតាមទទឹងម្រាមដៃនីមួយៗ។ មួយធ្នាប់ស្មើមួយភាគដប់ពីរនៃចំអាម ឬ ប្រហែល (២៥/១២សង់ទីម៉ែត្រ)។<br>- មួយធ្នាប់ គិតប្រវែងទទឹងម្រាមចង្អុលដៃ។<br>- ពីរធ្នាប់ គិតប្រវែងទទឹងម្រាមចង្អុលដៃនិងម្រាមចង្អុលខ្មោច។<br>- បីធ្នាប់ គិតប្រវែងទទឹងម្រាមចង្អុលដៃ ម្រាមចង្អុលខ្មោចនិងម្រាមនាងដៃ។<br>- បួនធ្នាប់ គិតប្រវែងទទឹងម្រាមចង្អុលដៃ ម្រាមចង្អុលខ្មោច ម្រាមនាងដៃ និង ម្រាមកូនដៃ។ |
| **៦៦- នាដកថា**<br>អ. script of the play<br>បារ. pièce de théâtre (f.) | អត្ថបទរឿងល្ខោនដែលពណ៌នាលម្អិតអំពីចំណងជើងរឿង ឈ្មោះអ្នកនិពន្ធ កាលបរិច្ឆេទនិពន្ធ រាយតួសម្ដែង ឆាកឈុត ការកាត់កងឆាក ពាក្យពេចន៍សន្ទនា ឯកវាទ (ការនិយាយម្នាក់ឯង) បទចម្រៀង ភ្លេងកំដរ...។<br>ឧ. នាដកថា *រឿងថៅកែចិត្តចោរ* ជាស្នាដៃរបស់អ្នកនិពន្ធ អ៊ំ ឈឺន និង ពៅ យូឡេង។ |
| **៦៧- នាលិ / នាឡិ** | រង្វាល់ខ្មែរពីបុរាណ ធ្វើពីត្រឡោកដូង ប្រើសម្រាប់វាល់គ្រាប់ធញ្ញជាតិ មានអង្ករ សណ្ដែកល្ង ជាដើម។ |
| **៦៨- និម្មាបនកម្ម / ស្ថាបត្យកម្ម** | វិទ្យាសាស្ត្រនិងសិល្បៈនៃការគូរប្លង់ក្នុងការសាងឬតាក់តែងដែលបង្កប់គំនិតបង្កើតថ្មី |

| | |
|---|---|
| អ. architecture<br>បារ. architecture<br>(f.) | ស្របតាមមុខងារនិងតួនាទីដែលមានអត្ថន័យក្នុងវិស័យវប្បធម៌ សេដ្ឋកិច្ច នយោបាយ និងការអប់រំ ជាដើម។<br>រចនាសម្ព័ន្ធ(ភាគផ្សំ)នៃអគារដែលបានសាងសង់ទៅតាមគោលការណ៍ណាមួយ។<br>ឧ. គួរស្ញើចសរសើរនូវនិម្មាបនកម្មឬស្ថាបត្យ-កម្មនៃប្រាសាទនគរវត្ត។ |
| **៦៩- និម្មាបនកម្មទេសភាព / ស្ថាបត្យកម្មទេសភាព**<br>អ. landscape architecture<br>បារ. architecture paysagiste (f.) | វិទ្យាសាស្ត្រនិងសិល្បៈនៃការគូរប្លង់ ទេសភាពនិងបង្កើតទេសភាពដោយប្រើប្រាស់ធនធានធម្មជាតិជាធាតុផ្សំ ៖ រុក្ខជាតិ (ដើមផ្កា ស្មៅ ដើមឈើ វល្លិ៍) ថ្មល់ សំណង់អគារ ថ្មភ្នំ បឹង ...។<br>ឧ. និម្មាបនកម្មទេសភាពឬស្ថាបត្យកម្មទេស-ភាពខ្មែរមានតាំងពីសតវត្សរ៍ទី៥ម្ល៉េះ គឺទីក្រុងស្រេស្ឋបុរៈ(រាជធានីចេនឡា)នៅស្រុកចម្ប៉ា-សាក់ ខេត្តចម្ប៉ាសាក់ ប្រទេសឡាវ។ ទីក្រុងស្រេស្ឋបុរៈមានប្រាសាទមួយ គឺ ប្រាសាទវត្តភូសាងលើចង្កេះភ្នំលិង្គ ដោយយកផ្ទាំងថ្មធម្ម-ជាតិជាឆាកធម្មជាតិនៅពីក្រោយប្រាសាទវត្តភូនិងនៅខាងមុខប្រាសាទមានទន្លេមេគង្គ។ ស្រេស្ឋបុរៈជាទីក្រុងមានប្លង់មុនគេនៅអាស៊ីអាគ្នេយ៍។ ក្រុងស្រេស្ឋបុរៈនិងប្រាសាទវត្តភូជាបេតិកភណ្ឌពិភពលោក។ |

| | |
|---|---|
| **៧០- និម្មាបនវិទូ / ស្ថាបត្យវិទូ**<br>អ. architect<br>បារ. architecte ( m. / f. ) | អ្នកប្រាជ្ញដែលមានជំនាញឯកទេសខាងនិម្មាបនកម្មឬស្ថាបត្យកម្ម។ |
| **៧១- និម្មាបនិក / ស្ថាបត្យករ**<br>អ. architect<br>បារ. architecte ( m. / f. ) | អ្នកមានអាជីពខាងនិម្មាបនកម្ម។ អ្នកកាន់កាប់មុខការខាងសម្របសម្រួលនិងត្រួតពិនិត្យរាល់ទិដ្ឋភាពនៃសំណង់អគារ។ |
| **៧២- និម្មាបនិកទេសភាព/ស្ថាបត្យករទេសភាព**<br>អ. landscape architect<br>បារ. architecte paysagiste ( m. ) | អ្នកមានអាជីពខាងនិម្មាបនកម្មទេសភាព ឬស្ថាបត្យកម្មទេសភាព។ |
| **៧៣- នឹម** | ខ្នាតឯកតាខ្មែរពីបុរាណ ដែលកំណត់ចំនួនសត្វពាហនៈ មានគោឬក្របីចំនួនពីរ ដែលនៅក្នុងនឹមរទេះឬនង្គ័លតែមួយ។<br>ឧ. គោមួយនឹមកំពុងភ្ជួរស្រែ។ |
| **៧៤- បន្ទាយគូ**<br>អ. circular earthwork | ឈ្មោះស្ថានីយបុរាណវត្ថុវិទ្យា មានសំណង់ដីរាងមូលដែលមនុស្សបានកសាងឡើង ដោយជីកគូ (គូទឹក)និងលើកកំពែងព័ទ្ធជុំវិញ ដូចជា បន្ទាយគូនៅមេមត់ បន្ទាយគូនៅជើងឯក ជាដើម។ |

| | |
|---|---|
| បារ. fortification circulaire en terre (f.) | អ្នកស្រាវជ្រាវបារាំងឈ្មោះ Bernard Philippe Groslier ហៅ បន្ទាយគូមេមត់ ថា rond village។ |
| **៧៥- បាកាន**<br>អ. Bakan | - តួប៉មទាំងប្រាំនៅរួតទីបីនៃប្រាសាទអង្គរវត្ត។<br>ឧ. មានរូបបីជាន់ ល្អល្អះគ្រាប់គ្រាន់<br>ត្រសោលត្រសំ ជាសារពើសូត<br>រហូតដល់កំ- ពូលពេជ្រឧត្តម<br>បាកានទាំងប្រាំ។<br>(ដកស្រង់ពីល្បើកអង្គរ ក្នុងវគ្គទី១២០)<br>- ឈ្មោះប្រាសាទមួយនៅក្នុងឃុំតាសែង ស្រុកកំពង់ស្វាយ ខេត្តព្រះវិហារ។ មានឯកសារស្រាវជ្រាវខ្លះហៅ បាកាន ឬ ប្រាសាទព្រះខ័ន (កំពង់ស្វាយ)។<br>- ឈ្មោះស្រុកមួយនៅក្នុងខេត្តពោធិ៍សាត់។ |
| **៧៦- បុរាណវត្ថុ**<br>អ. antique<br>បារ. antiquité (f.) | វត្ថុដែលបន្សល់ពីអតីតកាល។ |
| **៧៧- បុរាណវត្ថុវិទូ**<br>អ. archeologist<br>បារ. archéologue (m.) | អ្នកប្រាជ្ញខាងបុរាណវត្ថុវិទ្យា។ |
| **៧៨- បុរាណវត្ថុវិទ្យា**<br>អ. archeology<br>បារ. archéologie (f.) | វិទ្យាសាស្ត្រសិក្សាអំពីវប្បធម៌របស់មនុស្សនៅសម័យបុរាណតាមរយៈវត្ថុសំណល់ផ្សេងៗ ដូចជា វត្ថុសិល្បៈ សំណង់ប្រាសាទ ឆ្អឹងមនុស្ស និងសត្វ ជាដើម។ |

| | |
|---|---|
| **៧៩- បុរាណវត្ថុសិល្បៈ**<br>អ.  artifact<br>បារ.  objet d’art<br>antique ( m. ) | បុរាណវត្ថុដែលបង្កើតនិងកែច្នៃដោយមនុស្ស និងអាចផ្លាស់ប្តូរទីតាំងបាន ដូចជា កុលាល-ភាជន៍ គ្រឿងអលង្ការ និង គ្រឿងសស្ត្រាវុធ (ដាវ លំពែង ធ្នូ ស្នា...) ជាដើម។ |
| **៨០- បេតិកភណ្ឌវប្បធម៌**<br>អ. cultural heritage<br>បារ. patrimoine culturel ( m. ) | ទ្រព្យសម្បត្តិរូបីនិងអរូបីដែលជាកេរដំណែលមរតកវប្បធម៌របស់មនុស្សជាតិ បង្ហាញនូវសក្ខី-ភាពនៃស្នាដៃរបស់មនុស្សមានសារប្រយោជន៍ និងតម្លៃខាងបុរាណវត្ថុវិទ្យា ប្រវត្តិវិទ្យា សិល្បៈ វិទ្យាសាស្ត្រ សាសនា សោភណភាព ជាតិ-ពន្ធុវិទ្យា នរវិទ្យា ឬក៏បច្ចេកទេស ជាដើម។<br>ឧ. ប្រាសាទអង្គរវត្តជាបេតិកភណ្ឌវប្បធម៌រូបី (ទ្រព្យសម្បត្តិរូបីដែលត្រូវបានចុះក្នុងបញ្ជីបេ-តិកភណ្ឌពិភពលោក នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ១៩៩២)។<br>របាំព្រះរាជទ្រព្យឬរបាំក្បាច់បុរាណខ្មែរ ជាបេ-តិកភណ្ឌវប្បធម៌អរូបី (ទ្រព្យសម្បត្តិអរូបី) ជាស្នាដៃឯកនៃបេតិកភណ្ឌវប្បធម៌អរូបីរបស់មនុស្សជាតិ ចុះបញ្ជីនៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៣។ |
| **៨១- បេតិកភណ្ឌវប្បធម៌រូបី**<br>អ.  tangible cultural heritage | ស្នាដៃបង្កើតដោយមនុស្ស ជាទ្រព្យសម្បត្តិដែលអាចមើលឃើញ ប៉ះពាល់បាន ងាយយល់ និង មានតម្លៃប្រវត្តិសាស្ត្រ សោភណភាព សិល្បៈ សាសនា វិទ្យាសាស្ត្រ បុរាណវត្ថុវិទ្យា |

| | |
|---|---|
| បារ. patrimoine culturel matériel (m.) | ជាតិពន្ធុវិទ្យា នរវិទ្យា រួមមាន ប្រាសាទ វិមាន វិហារ អគារ ផ្ទះសម្បែង វត្តអារាម រមណីយ-ដ្ឋានវប្បធម៌ ជាដើម។<br>ឧ. ប្រាសាទអង្គរវត្តជាសម្បត្តិបេតិកភណ្ឌវប្បធម៌រូបីមួយ។ |
| **៨២- បេតិកភណ្ឌវប្បធម៌អរូបី**<br>អ. intangible cultural heritage<br>បារ. patrimoine culturel immatériel (m.) | មរតកបង្កើតដោយមនុស្សបានផ្ទេរបន្តពីជំនាន់មួយទៅជំនាន់មួយ តាមរយៈការប្រតិបត្តិ ការបង្ហាញ ការសម្តែង ការនិយាយ ឬ ការត្រាប់តៗគ្នា ដែលមិនអាចមើលឃើញ មិនអាចប៉ះពាល់បាន និង ពិបាកយល់ ដូចជា ចំណេះដឹងបំណិន ភាសា សិល្បៈ សាសនា ជំនឿ ទំនៀមទម្លាប់ ប្រពៃណី ឧបករណ៍សម្ភារៈ វត្ថុសិល្បៈជាដើម។<br>ឧ. របាំអប្សរា ចម្លាក់ គំនូរ សិលាចារឹក ជាមរតកបេតិកភណ្ឌវប្បធម៌អរូបី។ |
| **៨៣- បំណិនជីវិត** | បំណិនបញ្ញាបុគ្គលិកលក្ខណៈ អន្តរបុគ្គល និងវិជ្ជាជីវៈ ដែលអាចជួយដល់ ការធ្វើការសម្រេចចិត្ត ការធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព និងអាចដោះស្រាយនិងគ្រប់គ្រងខ្លួនឯងបាន។ វាជាបំណិនដែលរួមចំណែកក្នុងការលើកស្ទួយសុខុមាលភាពនិងជីវិតប្រកបដោយផលិតភាព។ (ពាក្យស្នើដោយក្រសួងអប់រំ យុវជន និង កីឡា) |

| | |
|---|---|
| **៨៤- បំពង់ (បំពង់ឫស្សី)** | ខ្នាតរង្វាល់ខ្មែរពីបុរាណ ធ្វើពីបំពង់ឫស្សីស្រុក ប្រើសម្រាប់វាលទឹកត្នោត ដែលមានចំណុះរវាង ២លីត្រ ទៅ ៣លីត្រ។ ឧ. ទឹកត្នោតពីរបំពង់។ ប្រដាប់ឬឧបករណ៍ធ្វើពីបំពង់ឫស្សី ប្រើសម្រាប់វាល់វត្ថុរាវ ដូចជា ទឹកត្នោត ជាដើម។ |
| **៨៥- ប្លង់**<br>អ. plan<br>បារ. plan (m.) | - គំនូសបំប្រួញពីរវិមាត្រ (2 Dimension or 2D) ដែលមានខ្នាតបញ្ជាក់ដោយបង្ហាញអំពីទីតាំងនិងទំហំឬផ្នែកណាមួយ។<br>- ផែនទីលម្អិតដែលបង្ហាញពីអគារ ឬ ទីក្រុង, គំនូរលម្អិតដែលបង្ហាញពីអគារ។<br>- ផែនទីផ្ទៃរាបខ្នាតតូចដែលជាកំណត់ត្រាដោយគំនូសបង្ហាញពីទម្រង់និងលក្ខណៈទីតាំងនៃបុរាណវត្ថុសិល្បៈ បុរាណអចលនវត្ថុ បុរាណសរីរវត្ថុ បុរាណភូគព្ភវត្ថុ និង រចនាសម្ព័ន្ធសំណង់ ដែលអាចមើលឃើញនៅក្នុងស្ថានីយឬរណ្តៅកំណាយ។ |
| **៨៦- ផ្តិល** | ប្រដាប់ប្រើប្រាស់មួយប្រភេទរាងមូលក្រឡូម ខ្លះមានជើងជាទម្រ ខ្លះមានគម្រប និង ខ្លះមានក្បាច់រចនាវិចិត្រ ធ្វើពីលោហៈផ្សេងៗ ដូចជា មាស ប្រាក់ ស្ពាន់ លង្ហិន សំរឹទ្ធិ ជាដើម ច្រើនប្រើសម្រាប់ដងទឹកឬដាក់ទឹកប្រើប្រាស់។<br>ឧ. ទឹកមួយផ្តិល។<br><br> |

| | |
|---|---|
| **៨៧- ផ្លូន** | ខ្នាតឯកតាខ្មែរពីបុរាណ ដែលរាប់ចំនួន១០ដំប ស្មើនឹងចំនួន៤០។<br>ឧ. ពោតមួយផ្លូន។ |
| **៨៨- ពព្រឺទ្បែន**<br>អ. porcelain/china<br>បារ. porcelaine (f.) | ប្រភេទមួយនៃសេរ៉ាមិក មានពណ៌ស សាច់ម៉ដ្ឋ ភ្លឺរលោង មានភាពរឹងខ្លាំង និង ដុតនៅក្នុងកម្តៅខ្ពស់ពី ១២៥០ ទៅ ១៤០០អង្សាសេ ធ្វើឡើងយ៉ាងផ្ចិតផ្ចង់ និងដោយប្រណីត ព្រមទាំងមានតម្លៃខាងសោភណភាព។<br>ជាគ្រឿងប្រដាប់ប្រើប្រាស់មាន ចាន ពែង ជាដើម។ ឧ. ចានពព្រឺទ្បែន។ |
| **៨៩- ពាន / ជើងពាន** | ប្រដាប់មួយប្រភេទធ្វើពី លោហជាតិផ្សេងៗ មាន ស្ពាន់ មាស ប្រាក់ ឬ ធ្វើពីវត្ថុឯទៀត ដូចជា ដីដុត ឈើ ជាដើម។ បើធ្វើពីផ្តៅ រពាក់ ជាងត្បាញច្រើនលាបម្រក្សណ៍។ ប្រដាប់នេះ ភាគច្រើនមានរចនាក្បាច់វិចិត្រ មានជើងជាទម្រខ្ពស់បន្តិច ហើយ ផ្នែកខាងលើ រាងមូលសំប៉ែតឬមូលក្រឡូម ប្រើសម្រាប់ដាក់របស់របរក្នុងពិធីផ្សេងៗ។<br>ឧ. គេរៀបគ្រឿងសក្ការៈបូជាដាក់លើពាន ថ្វាយព្រះ។<br>    |

| | |
|---|---|
| **៩០- ព្យាម** | រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ ស្មើមួយកាងដៃ ដោយគិតពីចុងម្រាមដៃកណ្តាល (ចង្អុលខ្មោច)នៃដៃខាងឆ្វេងទៅចុងម្រាមដៃកណ្តាល(ចង្អុលខ្មោច)នៃដៃខាងស្តាំ។ មួយព្យាមមានប្រវែងប្រហែលជាពីរម៉ែត្រ។ |
| **៩១- ព្យាមដំរី** | រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ ដោយគិតពីចុងម្រាមមេជើងឆ្វេងទៅចុងម្រាមដៃកណ្តាល (ចង្អុលខ្មោច)នៃដៃស្តាំ ស្របតាមបណ្តោយដងខ្លួនដែលដេកផ្កាប់មុខ ហើយ សណ្តូកដៃជើងឱ្យត្រង់។ |
| **៩២- យដ្ឋិ** (យ័ត-ឋិ) | រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ ដែលមានប្រវែង ៧ហត្ថខ្នាត ស្មើនឹង ៣ម៉ែត្រកន្លះ។ |
| **៩៣- យថាគ្រោះ**<br>អ. hazard<br>បារ. danger (m.) | បាតុភូតដែលបង្កឱ្យមានបញ្ហាប្រឈម នាំទៅដល់ការបំផ្លាញនិងឈានដល់ការវិនាសបុរាណវត្ថុសិល្បៈ ប្រាសាទបុរាណ និង ស្ថានីយបុរាណវត្ថុវិទ្យា។<br>ឧ. ទឹកទន្លេមេគង្គហូរច្រោះបាក់ដី បណ្តាលឱ្យមានគ្រោះថ្នាក់ រហូតដល់បាត់រូបរាង។ ប្រាសាទបាចុង ក្នុងខេត្តស្ទឹងត្រែង ត្រូវបានចាត់ទុកជាយថាគ្រោះ។ |
| **៩៤- យថាភូតភាព**<br>អ. authenticity | លក្ខណៈឬសណ្ឋានដើមនៃសម្ភារៈ ប្លង់ ទេព-កោសល្យ ស្នាដៃ បច្ចេកទេសស្ថាបត្យកម្ម |

| | |
|---|---|
| បារ. authenticité (f.) | បច្ចេកទេសវិស្វកម្ម និង ការរៀបចំនគរូបនីយ-កម្មដែលបង្កប់នៅក្នុងធនធានបេតិកភណ្ឌវប្បធម៌ ទៅតាមដំណាក់កាលប្រវត្តិសាស្ត្រ។<br>២. ការជួសជុលនិងអភិរក្សប្រាសាទព្រះវិហារ ដែលជាបេតិកភណ្ឌពិភពលោក ត្រូវរក្សាឱ្យបានល្អតាមយថាភូតភាព។ |
| **៩៥- យសោធរតដាក**<br>អ. Yasodhara-tataka | ឈ្មោះតដាកដែលសាងនៅក្នុងរាជ្យព្រះបាទយសោវរ្ម័នទី១ (៨៨៩-៩១០) ទំហំ ៧គ.ម. x ២គ.ម. ដែលមានប្រាសាទមេបុណ្យខាងកើតនៅចំកណ្ដាល, បច្ចុប្បន្ន គេច្រើនហៅថា បារាយណ៍ខាងកើត (Eastern Baray)។ |
| **៩៦- យោជន៍** | ១- រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ ដែលមានប្រវែង៤០០សិន ឬ ៤គាវុត ស្មើនឹង ១៦០០០ ម៉ែត្រ (១៦គីឡូម៉ែត្រ)។<br>២- រង្វាស់កម្ពស់នៃខ្នាតខ្មែរពីបុរាណដែលមានប្រវែង៧ហត្ថខ្នាត ស្មើនឹង ៣ម៉ែត្រកន្លះ។ |
| **៩៧- រចនាសម្ព័ន្ធសំណង់ (បុរាណវត្ថុវិទ្យា)**<br>អ. structure<br>បារ. structure (f.) | សំណង់ដែលមនុស្សបង្កើតឡើង មានគ្រឹះនៅជាប់នឹងដី ដូចជា ផ្ទះ, ប្រាសាទ, អគារ ជាដើម។ |
| **៩៨- របាំប្រជាប្រិយខ្មែរ** | ប្រភេទរបាំដែលជាប់ទាក់ទងទៅនឹងពិធីប្រពៃ-ណី សម្រាប់រាំលេងកម្សាន្ត ដើម្បីបំបាត់ការ |

| | |
|---|---|
| អ. khmer popular dance<br>បារ. danse populaire khmère (f.) | នឿយហត់ ក្រោយពីសម្រាកពីការងារផ្សេងៗ ឬ ពេលបានទទួលជោគជ័យថ្មីៗ ឬ ក្នុងពេលជួបជុំញាតិមិត្តជិតឆ្ងាយជាដើម។<br>ឧ. រាំវង់, រាំក្បាច់, សារ៉ាវ៉ាន់ ជារបាំប្រជាប្រិយខ្មែរ។ |
| **៩៩- របាំប្រពៃណីខ្មែរ**<br>អ. khmer folk dance<br>បារ. danse folklorique khmère (f.) | របាំទាំងឡាយដែលស្ថិតជាប់នឹងពិធីជាប្រពៃណីទំនៀមទម្លាប់ ជំនឿ សាសនា ឬ ពិធីជាតំណាត្រកូលដ៏យូរលង់របស់ជនជាតិខ្មែរនិងជនជាតិដើមភាគតិចនៅកម្ពុជា។<br>ឧ. របាំត្រុដិ, របាំគោះត្រឡោក, របាំកាប់ក្របីផឹកស្រា (ជនជាតិគ្រឹង), របាំបេះក្រវាញ (ជនជាតិព័រ), របាំវាយកួយ (ជនជាតិកួយ) ជារបាំប្រពៃណីខ្មែរ។ |
| **១០០- របាំព្រះរាជទ្រព្យខ្មែរ / របាំក្បាច់បុរាណខ្មែរ**<br>អ. royal ballet of Cambodia | ទម្រង់សិល្បៈទស្សនីយភាពដែលសម្តែងឡើងជារបាំដាច់ៗតែឯង មានលក្ខណៈសក្ការៈ អភិរក្សនិយម មានសោភណភាពនិងប្រណីតភាពខ្ពស់ តំណាងឱ្យវប្បធម៌និងអត្តសញ្ញាណជាតិខ្មែរ។ (របាំនេះ ពីដើម គេរាំតែនៅក្នុងព្រះរាជពិធីតែប៉ុណ្ណោះ)។<br>ឧ. របាំអប្សរា, របាំជូនពរ, របាំទេពមនោរម្យ។ |
| **១០១- រូត (ប្រាសាទ)**<br>អ. temple gradin | ជាន់ ឬ ថ្នាក់នៃប្រាសាទ។<br>ឧ. រូតបាកាននៃប្រាសាទអង្គរវត្ត។ |

| | |
|---|---|
| **១០២- វ៉ែ** | ខ្នាតរង្វាស់ផ្ទៃក្រឡាពីបុរាណ ស្មើចំនួនផ្ទៃដី ៤ងារ គឺប្រវែង ២០ព្យាម៤ជ្រុង ត្រូវជា៤០០ ព្យាមក្រឡា ឬ មួយជ្រុងៗប្រវែងប្រហែល ៤០ ម៉ែត្រ បើគិតជាផ្ទៃក្រឡាប្រហែល ១៦០០ម៉ែត្រ ការ៉េ (ម៉ែត្រទ្វេគុណ)។<br>ឧ. ដីដាំដំណាំទំហំមួយវ៉ែ។ |
| **១០៣- រោងថែវ / រោងទង**<br>អ. gallery<br>បារ. galerie (f.) | រោងជួរមានសណ្ឋានវែង ជាបរិវេណព័ទ្ធជុំវិញ ប្រាសាទឬវិហារជាដើម មានទ្វារធំទាំង៤ទិស ដែលមានល្វែងច្រើន បាំងជញ្ជាំងខណ្ឌដោយ សង្កាត់ៗ មានទ្វារខាងទទឹងរោង សម្រាប់ដាក់ តាំងបង្ហាញពីវត្ថុសិល្បៈ ដូចជា គំនូរ, ចម្លាក់ ជាដើម។<br>ឧ. រោងថែវប្រាសាទអង្គរវត្ត, រោងថែវប្រាសាទ ព្រះវិហារ, រោងថែវព្រះវិហារព្រះកែវមរកត ។ល។ |
| **១០៤- លី** | ខ្នាតខ្មែរពីបុរាណដែលមានទម្ងន់ ១/១០ហ៊ុន ប្រមាណ ០,០៣៧៥ក្រាម។<br>ឧ. មាសបីលី។ |
| **១០៥- លូក** | រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ ដោយគិតពី ត្រឹមក្លៀកទៅដល់ចុងម្រាមដៃកណ្តាល(ចង្អុល ខ្មោច)។<br>ឧ. រន្ធក្តាមនេះមានជម្រៅមួយលូក។ |
| **១០៦-ល្ខោន/ សិល្បៈ- នាដកម្ម** | ទម្រង់សិល្បៈទស្សនីយភាពដែលសម្តែងអំពី រឿងមួយតាមរយៈពាក្យសម្តីនិងសកម្មភាពតួ- |

| | |
|---|---|
| អ. theatre<br>បារ. art dramatique, théâtre (m.) | អង្គនៅក្នុងសាច់រឿង នៅចំពោះមុខទស្សនិកជន។<br>ឧ. ល្ខោនរឿង ថ្មរាំ។ |
| **១០៧- ល្ខោនព្រះរាជទ្រព្យខ្មែរ/ ល្ខោនក្បាច់បុរាណខ្មែរ** | ទម្រង់សិល្បៈទស្សនីយភាពដែលសម្តែងឡើងដោយប្រើក្បាច់របាំបុរាណខ្មែរ ជារឿងល្ខោនមានលក្ខណៈសក្ការៈ អភិរក្សនិយម មានសោភណភាពនិងប្រណីតភាពខ្ពស់ តំណាងឱ្យវប្បធម៌និងអត្តសញ្ញាណជាតិខ្មែរ។<br>ឧ. ល្ខោនព្រះរាជទ្រព្យ «រឿងរាមកេរ្តិ៍», «រឿងព្រះថោង នាងនាគ»។ |
| **១០៨- ល្បែងនាដកម្ម**<br>បារ. jeu dramatique (m.) | មុខវិជ្ជាបច្ចេកទេសសម្រាប់ហាត់សម្តែងសិល្បៈនាដកម្ម ដែលគ្រូបង្ហាត់ល្ខោនកំណត់ឱ្យសិស្សសម្តែងឈុតខ្លីៗ។<br>ឧ. ល្បែងនាដកម្មឈុតខ្លីមួយ «ចូលព្រៃដើរជាន់ពស់»។ |
| **១០៩- ល្អី** | ខ្នាតវង្វាល់ខ្មែរពីបុរាណ ដូចកញ្ជើដែរ តែមានរាងស្មើលើស្មើក្រោម សម្រាប់វាល់គ្រាប់ធញ្ញជាតិ វត្ថុល្អិតៗ ជាដើម។<br>ឧ. ស្រូវមួយល្អី។ |
| **១១០- ល្អីតៅ** | ប្រដាប់ប្រើប្រាស់ត្បាញពីបន្ទោះឫស្សីមានរាងក្រឡូម ស្មើរស្មើលើស្មើក្រោម មាត់មូល មានកណ្តាប់ធ្វើពីបន្ទះឫស្សី ច្រើនក្តាប់នឹងចម្រៀកផ្តៅ ប្រើសម្រាប់វាល់ស្រូវ ដែលមួយល្អីតៅមាន |

| | |
|---|---|
| | ចំណុះស្មើនឹងមួយតៅ។ ល្អីតៅប្រើសម្រាប់ដាក់ស្រូវ អង្ករ ឬ គ្រាប់ធញ្ញជាតិដទៃទៀត។ អ្នកស្រុកតំបន់ខ្លះហៅកាត់ថា តៅ។  |
| **១១១- វប្បធម៌**<br>អ. culture<br>បារ. culture ( f. ) | ការបណ្ដុះចំណេះវិជ្ជា ប្រាជ្ញាស្មារតី និង របៀបរស់នៅរបស់មនុស្ស ឱ្យបានលូតលាស់ចម្រើន ដើម្បីសម្របសម្រួលទៅនឹងបរិស្ថាន និង ការអភិវឌ្ឍសង្គមដោយវិទ្យាសាស្ត្រឬដោយសិល្បៈផ្សេងៗ ជាដើម។ |
| **១១២- វិចិត្រ**<br>អ. fine<br>បារ. beau ( adj. ) | ដែលមានគុណវុឌ្ឍិនិងសោភណភាព ប្រកបដោយការរំលេចពណ៌ឬក្បាច់រចនានិងសម្រស់ល្អប្លែក។ |
| **១១៣- វិចិត្រករ**<br>អ. creative artist<br>បារ. créateur artistique ( m. ) | អ្នកដែលមានអាជីពប្រកបដោយទេពកោសល្យក្នុងការបង្កបង្កើត រចនា តុបតែង រំលេចពណ៌ គូរ ឆ្លាក់ ថតរូប។<br>ឧ. រូបគំនូរស្រីកណ្ដៀតក្អមមួយផ្ទាំងនេះ គឺជាស្នាដៃឯករបស់លោក ញ៉ឹក ញ៉ឹម ដែលជាវិចិត្រករខ្មែរម្នាក់ដ៏ល្បី ក្នុងទសវត្សរ៍ទី៧នៃសតវត្សរ៍ទី២០។ |

| | |
|---|---|
| **១១៤- វិចិត្រសិល្បៈ**<br>អ. fine art<br>បារ. beaux arts<br>(m.) | ការងារជំនាញហត្ថកម្មនិងបញ្ញាពលកម្មដែលជាស្នាដៃគ្រប់បែបយ៉ាង កើតចេញពីភាពប៉ិនប្រសប់នៃគំនិតប្រាជ្ញាល្អប្លែករបស់មនុស្សប្រកបដោយសោភណភាព សិល្ប៍ គំនិតច្នៃប្រឌិត ទាក់ទងទៅនឹងការសម្តែង ការតែងនិពន្ធ ការប្រគុំ ការរាំ ការច្រៀង ការគូរ ការឆ្លាក់ ដើម្បីឱ្យមនុស្សចាប់ចិត្ត ចាប់អារម្មណ៍ ចង់ទស្សនា ចង់ឃើញ ចង់ស្គាល់ ចង់ស្តាប់...។ |
| **១១៥- សង្វេគនាដកម្ម**<br>អ. melodrama<br>បារ. mélodrame<br>(m.) | ប្រភេទរឿងល្ខោនកម្សត់ ជាប់ទាក់ទងទៅនឹងទំនាស់ខាងផ្នែកចរិយាធម៌ (morality) រវាងអំពើល្អ និង អំពើអាក្រក់ហួសពីភាពសាមញ្ញកើតឡើងក្នុងស្ថានការណ៍ប្រថុចប្រញ៉ុច ប្រផិតប្រផើយឬចៃដន្យ ហើយ នៅចុងបញ្ចប់នៃសាច់រឿង តួអង្គអាចស្រាយបញ្ហាបាន។<br>ឧ. សង្វេគនាដកម្ម រឿងធនញ្ជ័យ ។ |
| **១១៦- ស៊ង** | កញ្ចប់មានសណ្ឋានជ្រលម ធ្វើពីស្លឹកចេកស្រស់ឬពីលោហៈ។ ស៊ងធ្វើពីស្លឹកចេកស្រស់មានស្រទាប់ហូតចេញ មានពីរបែប គឺ ស៊ងតូចប្រើ សម្រាប់ដាក់ម្លូបៀកនិងស្លាចំណិត ថ្នាំជក់ឬបារី, រីឯស៊ងធំ គេប្រើសម្រាប់ដាក់ស្លឹកម្លូស្លា កំបោរ ស្លាផ្លា ថ្នាំជក់ ជាដើម។ ចំពោះស៊ងធ្វើពីលោហៈ ដូចជា មាស ប្រាក់ ឬ ស្ពាន់ឥតមានស្រទាប់ហូតបានទេ ប្រើសម្រាប់ដាក់ |

| | |
|---|---|
| | ស្លឹកម្លូ បារី កន្សែងដៃ ជាដើម។<br>៎. យាយៗធ្វើស៊ងដាក់ម្លូ ស្លា ប្រគេនព្រះ-<br>សង្ឃ។<br>  |
| **១១៧- សិន** | រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ ដែលមានប្រវែង ២០ព្យាម ស្មើនឹង ៤០ម៉ែត្រ។ |
| **១១៨- សិល្បៈ**<br>អ. art<br>បារ. art ( f. ) | ការងារជំនាញហត្ថកម្មនិងបញ្ញាពលកម្មដែលជាស្នាដៃគ្រប់បែបយ៉ាងដែលមានសិល្ប៍ ពោលគឺធ្វើឱ្យមនុស្សចាប់ចិត្ត ចាប់អារម្មណ៍ ចង់មើល ចង់ឃើញ ចង់ស្គាល់។ សិល្បៈមានច្រើនប្រភេទណាស់ ដូចជា សិល្បៈរបាំ ចម្រៀង ភ្លេង ល្ខោន គំនូរ សំណង់ សូនរូប។ ល។ |
| **១១៩- សិល្បករ**<br>អ. artist<br>បារ. artiste ( m. ) | អ្នកដែលមានវិជ្ជាជីវៈខាងសិល្បៈ ដូចជា របាំ ចម្រៀង ភ្លេង ល្ខោន គំនូរ សូនរូប ។ល។ អាចបង្កើតបានជាស្នាដៃចេញពីការស្រមៃ និង ការច្នៃប្រឌិតប្រកបដោយសោភណភាព តាមរយៈកាយពលកម្មនិងបញ្ញាពលកម្ម ធ្វើឱ្យមនុស្សចាប់ចិត្ត ចាប់អារម្មណ៍ ចង់មើល ចង់ឃើញ |

| | |
|---|---|
| | ចង់ស្តាប់ និង ចង់ស្គាល់។ បើស្ត្រី ហៅថា សិល្ប-ការិនី។<br>ឧ. ភិរម្យ ប្រាជ្ញ ឈួន ជាសិល្បករចម្រៀងចា-ប៉ី។ នៅឆ្នាំ ២០០១ លោកបានទទួលវិញ្ញាបន-បត្រជាព្រឹទ្ធសិល្បករពីរាជបណ្ឌិត្យសភាកម្ពុជា។ |
| **១២០- សិល្បៈទស្សនីយភាព**<br>អ. performing arts<br>បារ. arts d'interpré-tation (arts du spectacle) (m.) | ទម្រង់សិល្បៈសម្តែងគ្រប់ប្រភេទ កើតពីការប្រតិបត្តិ ពីទេពកោសល្យនិងការប្រឌិតញាណដ៏អស្ចារ្យរបស់មនុស្សដែលគួរ**ឱ្យ**រំភើប គួរ**ឱ្យ**ចង់មើល គួរ**ឱ្យ**ចង់ស្តាប់ និង គួរគិត។<br>ឧ. តន្ត្រី របាំ ល្ខោន ការនិទានរឿង ការសូត្រកំណាព្យ... ជាសិល្បៈទស្សនីយភាព។ |
| **១២១- សេរ៉ាមិក**<br>អ. ceramic<br>បារ. céramique (f.) | បុរាណវត្ថុសិល្បៈធ្វើពីដីឥដ្ឋដុត មានលក្ខណៈរឹង ធន់នឹងកម្តៅ និង សារធាតុគីមី។ សេរ៉ាមិករួមមាន កុលាលភាជន៍ ពរ្សឺឡែន ទែរ៉ាកូតា និង ផលិតផលធ្វើពីដីដុតផ្សេងៗទៀត។ |
| **១២២- សោកនាដកម្ម**<br>អ. tragedy<br>បារ. tragédie (f.) | ប្រភេទរឿងល្ខោនដែលបង្ហាញពីបញ្ហាទាក់ទងទៅនឹងគ្រោះកម្មវាសនា ទុក្ខសោក ទុក្ខវេទនា សេចក្តីវិនាសអន្តរាយ ហើយ តួឯកត្រូវស្លាប់នៅចុងបញ្ចប់នៃសាច់រឿង ដែលធ្វើឱ្យអ្នកស្តាប់ អ្នកទស្សនា ក្តុកក្តួល រំជួលចិត្ត អាណិតអាសូរ និង ភ័យរន្ធត់។<br>ឧ. សោកនាដកម្ម ៖ រឿងទុំទាវ, រឿងម៉ាក់ថឺង, ...។ |

| | |
|---|---|
| **១២៣- សោកហាសនាដកម្ម**<br>អ. tragicomedy<br>បារ. tragi-comédie (f.) | ប្រភេទរឿងល្ខោនដែលផ្តោតខ្លាំងទៅលើរឿងរ៉ាវដ៏ក្រៀមក្រំទុក្ខសោកផងនិងសប្បាយរីក-រាយផង។<br>ឧ. សោកហាសនាដកម្មរឿង សំបុកឥតមេបា។ |
| **១២៤- ស្ថានីយ**<br>អ. site<br>បារ. site (m.) | ទីកន្លែងនៃសកម្មភាពគ្រប់ប្រភេទរបស់មនុស្សពីសម័យបុរាណ ដូចជា ទីកន្លែងសម្រាប់សម្នាក់, ទីកន្លែងសម្រាប់ឈប់, ទីកន្លែងសម្រាប់ចត, ...។ |
| **១២៥- ស្ថានីយបុរាណវត្ថុវិទ្យា**<br>អ. archeological site<br>បារ. site archéolo-gique (m.) | ទីកន្លែងនៅលើដី ក្នុងដី ក្រោមទឹក ដែលមានស្នាម ឬ វត្ថុសំណល់ផ្សេងៗ ពីសម័យបុរាណ ដូចជា បុរាណវត្ថុសិល្បៈ បុរាណអចលនវត្ថុ បុរាណជីវ-វត្ថុ បុរាណភូគព្ភវត្ថុ និង រចនាសម្ព័ន្ធសំណង់។<br>ឧ. ស្ថានីយបុរាណវត្ថុវិទ្យាសំរោងសែន។ |
| **១២៦- ស្ទើ** | ខ្នាតឯកតាខ្មែរពីបុរាណសម្រាប់រាប់ស្លឹកម្លូដែលចាប់ផ្តួបត្រួតលើគ្នាចំនួនពីរសន្លឹក។<br>ឧ. ម្លូពីរស្ទើ (បួនសន្លឹក)។ |
| **១២៧- ស្តក** | ថាសឈើឬតុឈើ រាងបួនជ្រុងឬរាងមូល គ្មានជើងឬមានជើងជាទម្រ ប្រើសម្រាប់ដាក់ចានរៀបភោជនាហារ។<br>ឧ. រៀបចង្ហាន់មួយស្តកប្រគេនព្រះសង្ឃ។<br><br> |

| | |
|---|---|
| **១២៨- ស្ពានហាល**<br>អ. causeway | សំណង់ស្ពានថ្មបុរាណឆ្លងកាត់កសិណទឹកឬកាត់ផ្លាដីគោកឆ្ពោះទៅកាន់ប្រាសាទបុរាណ។<br>ឧ. ទេសចរចូលទស្សនាប្រាសាទអង្គរវត្តដោយដើរឆ្លងកាត់ស្ពានហាលពីទិសខាងលិច។ |
| **១២៩- ស្រទាប់វប្បធម៌**<br>អ. cultural layer<br>បារ. strate culturelle (f.) | ស្រទាប់ដីដែលមានសំណល់សកម្មភាពមនុស្សមានដូចជា បុរាណវត្ថុសិល្បៈ បុរាណអចលនវត្ថុ បុរាណជីវវត្ថុ បុរាណភូគព្ភវត្ថុ រចនាសម្ព័ន្ធសំណង់ជាដើម ដែលអាចឱ្យយើងយល់ដឹងនិងបែងចែកសម័យកាលនីមួយៗដាច់ដោយឡែកៗពីគ្នា។ |
| **១៣០- ស្រាក់** | ខ្នាតឯកតាខ្មែរពីបុរាណដែលដាក់អ្វីៗតម្រួតលើគ្នា ហើយ ចងរុំឱ្យនៅក្នុងដុំតែមួយ ដូចជាស្លូវផែនឬចានជាដើម។ ចំពោះស្រាក់ស្លូវផែនគេខ្ចប់ចងរុំដោយស្លឹកត្នោត មាន១០ផែនឬ២០ផែនឬក៏ច្រើនជាងនេះ ហៅ មួយស្រាក់។ រីឯចានវិញ គេចងរុំ ចំនួន១០ឬចំនួន១២ ក៏ហៅមួយស្រាក់ដែរ។<br>ឧ. ស្លូវផែនពីរស្រាក់, ចានបីស្រាក់ ។ |
| **១៣១- ស្រាពក៏** | ផ្តិលធំមានជើងជាទម្រដាប់ឬមិនជាប់ ធ្វើពីលោហៈឬវត្ថុធាតុនានា ប្រើសម្រាប់ដាក់ទឹកក្នុងពិធីផ្សេងៗ ។ |

| | |
|---|---|
| | ឧ. គេដាក់ទឹកក្នុងស្រាពក៏សម្រាប់ព្រះសង្ឃ ប្រោះព្រំ។<br><br> |
| **១៣២- ស្លឹក** | ខ្នាតឯកតាខ្មែរពីបុរាណដែលរាប់ចំនួន ១០ផ្លូន ស្មើនឹងចំនួន ៤០០។<br>ឧ. ពោតមួយស្លឹក។ |
| **១៣៣- ហត្ថ** | រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ គិតប្រវែងពីត្រឹមកែងដៃដល់ចុងម្រាមដៃកណ្តាល (ចង្អុលខ្មោច)។ មួយហត្ថ គឺប្រហែលពីរចំអាម។ |
| **១៣៤- ហត្ថខ្នាត** | រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ ដោយគិតពីត្រឹមកែងដៃទៅដល់ចុងម្រាមដៃកណ្តាល (ចង្អុលខ្មោច) ដែលមានប្រវែងស្មើនឹងកន្លះម៉ែត្រ។<br><u>សម្គាល់</u> : មួយហត្ថខ្នាត គឺកំណត់ដោយប្រវែងដាក់លាក់ដែលមនុស្សម្នាក់កំណត់ចំណាំខ្លួនឯងឱ្យស្មើនឹងកន្លះម៉ែត្រ។<br>ឧ. ដៃខ្ញុំខ្លី ដើម្បីបានមួយហត្ថខ្នាត ខ្ញុំត្រូវវាស់មួយហត្ថដៃខ្ញុំ ហើយថែមពីរធ្នាប់។ |

| | |
|---|---|
| **១៣៥- ហានិភ័យ**<br>អ. risk<br>បារ. risque ( m. ) | ហេតុ ឬ បញ្ហាប្រឈមផ្សេងៗដែលអាចនាំឱ្យបាត់បង់ ឬ ខូចខាតនូវបុរាណវត្ថុសិល្បៈ ប្រាសាទបុរាណ និង ស្ថានីយបុរាណវត្ថុវិទ្យា។<br>ឧ. ដំណើរថ្មភក់នៃប្រាសាទភ្នំបាខែងទទួលរងហានិភ័យដោយកត្តាធម្មជាតិ ដូចជា ទឹកភ្លៀងហូរច្រោះ ឫសឈើដុះចាក់ និង មនុស្សដើរឡើងចុះជាន់ផ្ទាល់។ |
| **១៣៦- ហាប** | ខ្នាតខ្មែរបុរាណ ដែលមានទម្ងន់ ១០០នាឡិ ឬពីរចុង( ប្រហែល ៦០គីឡូក្រាម )។<br>ឧ. ប្រហុកមួយហាប, ជ្រូកមួយហាប, ស្រូវមួយហាប។ |
| **១៣៧- ហាសនាដកម្ម**<br>អ. comedy<br>បារ. comédie ( f. ) | ប្រភេទរឿងល្ខោនដែលធ្វើឱ្យអ្នកស្តាប់ អ្នកទស្សនាផ្ទុះសំណើច អាចទទួលបាននូវការកម្សាន្តសប្បាយផង និង ទាំងការទិតៀនរិះគន់ផង តាមរយៈការសម្តែង ការអធិប្បាយ ការក្លែងធ្វើពុត ធ្វើពើ ធ្វើពត្លីពត្លើ ធ្វើល្ងីល្ងើ របស់ជនល្ងង់ខ្លៅ តួត្លុក តួក្រមាច់ ជាដើម។<br>ឧ. ហាសនាដកម្ម *រឿងជនកំណាញ់ក្រៅតម្រា* និពន្ធដោយ លោក Molière។ |
| **១៣៨- ហឹបស្លា** | ប្រដាប់ប្រើប្រាស់មួយប្រភេទ មានកម្ពស់ទាប មានរាងមូលឬរាងជ្រុង មានគម្រប ធ្វើពីឈើ ជាងត្នោតឬលោហៈ មានក្បាច់រចនាវិចិត្រ ប្រើសម្រាប់ដាក់គ្រឿងម្លូស្លា (អ្នកខ្លះហៅថា ប្រ- |

| | |
|---|---|
| | អប់ស្លា, ក្នុងករណីប្រអប់មានរាងមូល គេហៅថា ប្រអប់ជើងជំរី)។   |
| **១៣៩- ហ៊ុន** | ខ្នាតខ្មែរពីបុរាណ ដែលមានទម្ងន់ ១/១០ជី ឬ ១០លី ប្រមាណ ០,៣៧៥ក្រាម។<br>ឧ. មាសពីរហ៊ុន។ |
| **១៤០- ហោត្រៃ**<br>**(ប្រាសាទ)**<br>អ. hortrai (library) | សំណង់អគារបុរាណនៅក្នុងបរិវេណប្រាសាទ ជាទូទៅបែរមុខបញ្ច្រាសទិសនឹងតួប៉មកណ្ដាលនៃប្រាសាទនោះ។<br>ឧ. ជាប្រាង្គប្រាសាទ ល្អល្អះស្អាងស្អាត<br>សុទ្ធសឹងតែថ្ម មានរោងជំនុំ<br>ទាំងស្រះបួនល្អ ហោត្រៃសឹងថ្ម<br>ឆ្វេងស្ដាំផងណា។<br>(ដកស្រង់ពីល្បើកអង្គរ ក្នុងវគ្គទី១១៥) |
| **១៤១- ឡូ** | ខ្នាតឯកតាខ្មែរពីបុរាណដែលមានចំនួន១២។<br>ឧ. ចានមួយឡូ, សៀវភៅមួយឡូ។ |
| **១៤២- អព្ភន្តរ**<br>(អ័ប-ភ័ន-តៈ-រៈ ឬ អ័ប-ភ័ន-ដ) | រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ (ពាក្យប្រើក្នុងព្រះវិន័យព្រះពុទ្ធសាសនា សម្រាប់កំណត់គោលអពទ្ធសីមា) ដែលមានប្រវែង៧ព្យាម ឬ ប្រវែង២៨ហត្ថខ្នាត ស្មើនឹង ១៤ម៉ែត្រ។ |

| | |
|---|---|
| **១៤៣- អាណាស្ទីឡូស**<br>អ. anastylosis<br>បារ. anastylose<br>( f. ) | បច្ចេកទេសជួសជុលសំណង់ប្រាសាទឬអគារ ដែលត្រូវរុះរើទាំងស្រុង រួចរៀបសង់ជាថ្មីឡើងវិញ ដោយប្រើប្រាស់រចនាសម្ព័ន្ធដើម(សម្ភារៈដើម), ក្នុងករណីបាត់បង់ឬខ្វះខាត ត្រូវបន្ថែមសម្ភារៈថ្មី។<br>ឧ. បុរាណវិទូជនជាតិបារាំង Henry Marchal ប្រើប្រាស់បច្ចេកទេសអាណាស្ទីឡូស ដើម្បីជួសជុលប្រាសាទបន្ទាយស្រី។ |
| **១៤៤- ឥន្ទ្រតដាក**<br>អ. Indratataka | ឈ្មោះតដាកដែលសាងនៅក្នុងរាជ្យព្រះបាទឥន្ទ្រវរ្ម័ន (៨៧៧-៨៨៩) មានទំហំ ៣.៨ គ.ម. x ៨០០ គ.ម. ទាញពីទឹកស្ទឹងរលួសមកបញ្ចូល។ |
| **១៤៥- ឧសភ**<br>(អ៊ុសប់) | រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ ដែលមានប្រវែង ១៤០ហត្ថខ្នាត (២០យដ្ឋិ) ឬ ៣៥ ព្យាម ស្មើនឹង ៧០ម៉ែត្រ (ចម្ងាយស្មើនឹងសំឡេងគោឧសភរាជរោទ៍)។ |
| **១៤៦- ឱប** | ខ្នាតរង្វាស់ទំហំខ្មែរពីបុរាណ ដែលគិតជារង្វង់ ដោយយកដៃទាំងពីរព័ទ្ធរួបចូលជិតដល់ទ្រូង ដោយប្រទល់ចុងម្រាមដៃចង្អុលខ្មោច។<br>ឧ. ដើមឈើមួយឱប។ |
| **១៤៧- អ្នកបុរាណវត្ថុវិទ្យា**<br>អ. archeologist<br>បារ. archéologue<br>( m. ) | អ្នកដែលបានសិក្សាស្រាវជ្រាវកម្រិតឧត្តម និងប្រកបអាជីពផ្នែកបុរាណវត្ថុវិទ្យា។ |

## ២- បច្ចេកសព្ទចិត្រសិល្បៈ

| | |
|---|---|
| ១- កង-ក | គ្រឿងអលង្ការមួយយ៉ាងសម្រាប់ពាក់នៅនឹងក មានសណ្ឋានជារង្វង់ ធ្វើពីវត្ថុធាតុផ្សេងៗ។ ឧ. ខ្មែរបុរាណនិយមពាក់កង-ក (រូបចម្លាក់នៅប្រាសាទអង្គរវត្ត, ប្រាសាទបាយ័ន...)។ |
| ២- កងកន់ | គ្រឿងប្រដាប់ដៃមួយប្រភេទ ធ្វើពីលោហៈ មានបន្ទារទំហំប្រហែលប្រាំមួយសង់ទីម៉ែត្រ ជាបន្ទះអង្កន់ៗចំនួន៤ឬ៥កងជាប់ៗគ្នា សម្រាប់តួនាយរោង តួយក្ស និង តួស្វាក្បាច់ ពាក់លម្អជុំវិញកដៃបន្ទាប់ពីកងរាក់។ |
| ៣- កងទងឈូក | គ្រឿងអលង្ការមួយប្រភេទធ្វើពីលោហៈ ដែលផ្នែកខាងចុងទាំងពីរខាងទល់មុខគ្នា រចនាដូចផ្កាឈូកក្រពុំ សម្រាប់ពាក់នៅលើ កជើងនៃអ្នករបាំបុរាណខ្មែរ។ កងទងឈូកក៏មានពាក់លម្អកជើងកូនក្រមុំក្នុងពិធីមង្គលការដែរ។ |
| ៤- កងរាក់ | គ្រឿងប្រដាប់ដៃមួយប្រភេទ ជាកងដៃមានមុខកាត់បីជ្រុង រាងដូចទ្រនុងខ្នងសត្វពស់ ដោយមានឆ្លាក់ក្បាច់ភ្ញី សម្រាប់ឱ្យអ្នករបាំបុរាណខ្មែរពាក់លម្អនៅលើ កដៃចំនួនម្ខាងមួយ ពាក់បន្ទាប់ពីកន្ទ្រំ។ |

| | |
|---|---|
| **៥- កញ្ចាំង** | ក្បាច់រចនាដែលមានទម្រង់ស្លឹកពោធិ៍ឬត្របកទំពាំង មានបណ្តូលក្បាច់រាងមូល ស្រួចចុង ឬរាងតំណក់ទឹក មានផែក១ជាន់ឬ២ជាន់។ ក្បាច់នេះមានដូចជា ក្បាច់កញ្ចាំងរាយ កញ្ចាំងជុំ កញ្ចាំងត្របកទំពាំងជាដើម សម្រាប់លម្អលើចន បល្លង្ក មកុដ ដោយដាំត្បូង បិទកញ្ចក់ បញ្ចុះភ្លុក។ល។ សម័យបុរាណ គេនិយមប្រើក្បាច់កញ្ចាំងចង្វាយ។ |
| **៦- កញ្ចាំងចង្វាយ** | ក្បាច់រចនាដែលមានទម្រង់ស្លឹកពោធិ៍ បណ្តូលមានមាត្ររាងមូលស្រួចចុងឬរាងតំណក់ទឹក មានផែក១ជាន់ឬ២ជាន់។ ក្បាច់នេះផ្គុំឡើងដោយកញ្ចាំងរាយ លម្អលើចង្វាយផ្សេងៗគ្នា។ |
| **៧- កញ្ចាំងជុំ** | ក្បាច់រចនាមានទម្រង់ស្លឹកពោធិ៍ បណ្តូលមានមាត្ររាងមូល ស្រួចចុងឬរាងតំណក់ទឹក មានផែក១ជាន់ឬ២ជាន់ ដែលផ្គុំឡើងដោយកញ្ចាំងរាយចាប់ពីពីរឡើងទៅ។ |
| **៨- កញ្ចាំងត្របកទំពាំង** | ក្បាច់រចនាដែលមានទម្រង់ស្លឹកពោធិ៍ទ្រវែង បណ្តូលមានមាត្ររាងមូលស្រួចចុងឬរាងតំណក់ទឹក មានផែក១ជាន់ឬ២ជាន់។ ក្បាច់នេះមានទម្រង់វែងជាងកញ្ចាំងរាយ និង មានទម្រង់ដូចត្របកទំពាំង ជួនផ្គុំឡើងដោយកញ្ចាំងរាយ។ |

| | |
|---|---|
| **៩- កញ្ចាំងរាយ** | ក្បាច់រចនាដែលមានទម្រង់ស្លឹកពោធិ៍ បណ្ដូលមានមាត្រារាងមូលស្រួចចុងឬរាងតំណក់ទឹក មានផែក១ជាន់ឬ២ជាន់។ ក្បាច់នេះនៅរាយដាច់ពីគ្នា ហើយ មានទម្រង់ខ្លីជាងត្របកទំពាំង។ |
| **១០- កន្ទុយប្រា** | កន្ទុយសំពត់ក្បិនរបស់តួនាយរោងដែលបត់ទម្លាក់ចេញក្រៅ មានទម្រង់ដូចកន្ទុយត្រីប្រា។ |
| **១១- កន្ទ្រុំ** | គ្រឿងប្រដាប់ដៃមួយប្រភេទជាខ្សែដៃ មានសណ្ឋានជាគ្រាប់មូលតូចៗ រចនាដោយទម្លុះជាក្បាច់ចក្កច័ន ក្បាច់ពងត្រី ឬ ដាំត្បូង ដោយចោះរន្ធ ដើម្បីដោតខ្សែពីមួយគ្រាប់ទៅមួយគ្រាប់ សម្រាប់ឱ្យអ្នករបាំបុរាណខ្មែរពាក់លម្អនៅលើកដៃចំនួន២ខ្សែម្ខាង បន្ទាប់ពីកងញ៉ែរដៃ។ |
| **១២- កបិត** [កៈបិត] | គ្រឿងអលង្ការមួយយ៉ាងពាក់នឹងទងត្រចៀក ធ្វើពីវត្ថុធាតុផ្សេងៗ ដែលផ្នែកខាងមុខមានក្រចាប់ដាំត្បូងមួយគ្រាប់ធំពទ្ធដោយគ្រាប់ត្បូងច្រើន ភ្ជាប់ទៅនឹងទងវែង និង មានសន្ទះមួយដាច់ដោយឡែកសម្រាប់ស៊កផ្ទប់ដើម្បីកុំឱ្យរបូតនៅពេលប្រើប្រាស់។ នៅសម័យបុរាណ គេមិនធ្វើសន្ទះស៊កផ្ទប់ទេ ប៉ុន្តែ គេប្រើក្រមួនឃ្មុំបិទភ្ជាប់រាងដូចប្រាក់កាក់( កាក់+បិទ )។<br>ពាក្យសៀមហៅថា ទុំហូ។ |

| | |
|---|---|
| **១៣- ការពិនិត្យសង្កេតបុរាណវត្ថុវិទ្យាបឋម**<br>អ. archaeological reconnaissance<br>បារ. reconnaissance archéologique (f.) | ការសិក្សាពិនិត្យសង្កេតជាប្រព័ន្ធជាដំបូងដើម្បីកំណត់ទីតាំង កំណត់អត្តសញ្ញាណ និង កត់ត្រារបាយទីតាំងស្ថានីយបុរាណវត្ថុវិទ្យាដែលមាននៅលើនិងក្នុងដីក្នុងបរិស្ថាននៃភូមិសាស្ត្រធម្មជាតិ។ |
| **១៤- ការអង្កេតផ្ទៃលើ**<br>អ. surface survey<br>បារ. enquête (f.) de surface (f.) | វិធីសាស្ត្រមួយរបស់បុរាណវត្ថុវិទ្យាក្នុងការសិក្សាពិនិត្យសង្កេតវត្ថុ គំហើញ មានដូចជាបុរាណវត្ថុសិល្បៈ រចនាសម្ព័ន្ធសំណង់ បុរាណអចលនវត្ថុជាដើម ដែលស្ថិតនៅលើផ្ទៃដីនៃស្ថានីយណាមួយ។ |
| **១៥- ការវទងខ្វេរ** | គ្រឿងអលង្ការមួយយ៉ាងពាក់នឹងទងត្រចៀកធ្វើពីវត្ថុធាតុផ្សេងៗ មានក្បាលជាំត្បូងកញ្ចុំ និងមានទងកោងខុបដូចកង្វេរប្រើជាតម្លក់។ |
| **១៦- ការវទងត្រង់** | គ្រឿងអលង្ការមួយយ៉ាងពាក់នឹងទងត្រចៀកធ្វើពីវត្ថុធាតុផ្សេងៗ មានក្បាលជាំត្បូងកញ្ចុំដែលមានទងវែងត្រមោងកណ្ដាល ឬ មានទងវែងត្រង់ ភ្ជាប់ដោយសន្ទះមួយជាច់ដោយឡែកសម្រាប់ស៊កផ្ទប់មិនឱ្យរបូតនៅពេលប្រើប្រាស់។ |
| **១៧- កំណាយសង្គ្រោះ**<br>អ. salvage excavation | បច្ចេកទេសស្រាវជ្រាវរបស់បុរាណវត្ថុវិទ្យាសង្គ្រោះ តាមរយៈការធ្វើកំណាយនៅលើស្ថានីយបុរាណវត្ថុវិទ្យាណាមួយដើម្បីប្រមូលទិន្នន័យដើមឱ្យបានមុនការបាត់បង់ដោយប្រការណាមួយ។ |

| | |
|---|---|
| ១៨- កំបោរប្រេង | ល្បាយម្យ៉ាងដែលផ្សំពីស៊ីម៉ងត៍ខ្មៅនិងទឹកសម្រាប់បន្សុំបេតុងចាស់និងបេតុងថ្មី ឬ បាយ-អចាស់និងបាយអថ្មី ជាដើម។<br>ឧ. ជាងពុម្ពលាយកំបោរប្រេងចាក់ក្នុងពុម្ពសសរ មុននឹងចាក់ល្បាយបេតុងបន្តទៀត។ |
| ១៩- ក្បាច់<br>អ. decoration<br>បារ. ornament ( m. ) | រូបរចនាដែលមានលក្ខណៈវិចិត្រ បង្កើតចេញពីទិដ្ឋភាពឬរូបភាពអ្វីមួយសម្រាប់តុបតែងលម្អស្ថាបត្យកម្មឬវត្ថុផ្សេងៗ។<br>ឧ. ក្បាច់ភ្ញីភ្លើង ក្បាច់ចក ក្បាច់ពងត្រី ក្បាច់ធ្មេញក្រពើ ។ល។ |
| ២០- ក្បាច់កញ្ចុំរីក | ក្បាច់កញ្ចុំរីកមានរបៀបរាំដោយប្រើម្រាមដៃទាំងប្រាំរួមប្រមូលគ្នាពត់ងឃ្លាតពីគ្នា ដែលមានលំនាំដូចផ្កាចាយ( ផ្ការីក )។ |
| ២១- ក្បាច់កញ្ចុំរួម | ក្បាច់កញ្ចុំរួមមានរបៀបរាំដោយប្រើម្រាមដៃទាំងប្រាំរួមប្រមូលផ្តុំគ្នា ពត់ងស្មើតជិតគ្នា ដែលមានលំនាំដូចផ្កាក្រពុំ។ |
| ២២- ក្បាច់ក្តាប់ | ក្បាច់ក្តាប់មានរបៀបរាំដោយប្រើម្រាមដៃបួនក្តាប់ ឯមេដៃលាចេញ ដែលមានលំនាំដូចក្តីបផ្លែឈើ។ |
| ២៣- ក្បាច់ក្តោប | ឈ្មោះក្បាច់រាំដែលប្រើម្រាមដៃទាំង៥ ក្តាប់ហើយកាច់កដៃឱ្យក្ងុកទៅមុខ។ នៅពេលរាំ ម្តង |

| | |
|---|---|
| | គេលើកដៃឆ្វេងឡើងលើ ម្តងគេលើកដៃស្តាំឡើងលើ ដែលមានលំនាំដូចដើងសេះដើរឬផាយ។<br>២. នៅក្នុងរបាំរឿងរាមកេរ្តិ៍ ត្រង់ឈុតរាមលក្សណ៍និងជបលក្សណ៍ជិះលើសេះចម្បាំងជាមួយហនុមាន។ |
| **២៤- ក្បាច់ក្រញាំ** | ក្បាច់ក្រញាំមានរបៀបរាំដោយប្រើម្រាមដៃទាំងប្រាំពត់ប្រឈមរកគ្នា ដែលមានលំនាំដូចក្រញាំខ្លាឬក្រញាំឆ្មាជាដើម។ |
| **២៥- ក្បាច់ខ្ចង** | ក្បាច់ខ្ចងមានរបៀបរាំដោយប្រើចុងមេដៃនិងចុងម្រាមដៃកណ្តាលទល់ភ្ជាប់គ្នា កើតចេញជារង្វង់មូល ឯម្រាមបីទៀតកាច់ងស្មើតឡើងដែលមានលំនាំដូចផ្លែឈើចាស់។ |
| **២៦- ក្បាច់ខ្ចងផ្ទាត់** | ក្បាច់ខ្ចងផ្ទាត់មានរបៀបរាំដោយប្រើចុងមេដៃនិងចុងម្រាមដៃកណ្តាលកាច់ទល់ភ្ជាប់គ្នាជារង្វង់មូល ហើយ នៅពេលចុងបញ្ចប់នៃសាច់ភ្លេង គេតែងផ្ទាត់លាម្រាមដៃកណ្តាលចេញពីម្រាមមេដៃ ដោយឱ្យម្រាមកណ្តាលមកជាប់នឹងម្រាម៤វិញ ដូចផ្លែឈើទុំជ្រុះ ក្នុងន័យថាលាគ្នាឬបែកគ្នានាពេលបញ្ចប់សាច់រឿង។ |
| **២៧- ក្បាច់ខ្ចងហា** | ក្បាច់ខ្ចងហាមានរបៀបរាំដោយប្រើចុងមេដៃនិងចុងម្រាមដៃកណ្តាលកាច់បែររកគ្នាជារង្វង់ដោយមិនទល់ចុងម្រាមជាប់គ្នា ដែលមានលំនាំដូចផ្លែឈើទុំប្រេះ។ |

<table>
<tr>
<td>២៨- ក្បាច់ខ្សែទឹក</td>
<td>ក្បាច់ម្យ៉ាងប្រើប្រាស់សម្រាប់លម្អស្ថាបត្យកម្ម ដែលធ្វើពីសម្ភារៈផ្សេងៗ មានសណ្ឋានជាល្បាក់ខ្សែ ជ្រុង ធ្នូតវែង ដាក់ផ្ដេក ឬ បញ្ឈរទៅតាមលក្ខណៈនៃអគារ ដោយយកភាពស្មើគ្នានៃកម្រិតទឹកជាគោល។<br>គេប្រើក្បាច់ខ្សែទឹកដាក់នៅខាងក្រៅឬខាងក្នុងអគារ ជាទូទៅ នៅលើផ្ទៃជញ្ជាំង ពិតាន វត្ថុផ្សេងៗ ឬ ឧបករណ៍ប្រើប្រាស់ប្រចាំថ្ងៃ។ ខ្មែរនិយមប្រើក្បាច់ខ្សែទឹកផ្ដេក បញ្ឈរ និង ព័ទ្ធវ័ណ្ឌ (ព័ទ្ធជុំ)។<br>



</td>
</tr>
<tr>
<td>២៩- ក្បាច់គូ</td>
<td>១- ក្បាច់គូមានរបៀបរាំដោយប្រើម្រាមចង្អុលដៃនិងម្រាមកណ្ដាល ចង្អុលបញ្ឈរញែកចេញពីគ្នា មានលំនាំដូចមែកឈើបែកចម្លាម ឯម្រាមបីទៀតបត់ប្រជុំគ្នា ដោយអ្នករាំត្រូវបែរបាតដៃមករកមុខរបស់ខ្លួន។<br>២- ក្បាច់គូមានរបៀបរាំដោយប្រើម្រាមចង្អុលដៃទាំងពីរមកដាក់ផ្គូផ្គងគ្នា មានលំនាំដូចរុក្ខ-ជាតិមានមែកពីរទន្ទឹមគ្នា ក្នុងន័យប្រៀបធៀប</td>
</tr>
</table>

| | |
|---|---|
| | ឯម្រាមបួនទៀត បត់ប្រជុំគ្នា ដោយអ្នករាំត្រូវផ្កាប់បាតដៃ។ |
| **៣០- ក្បាច់ចង្អុល** | ក្បាច់ចង្អុលមានរបៀបរាំផ្សេងៗដោយប្រើម្រាមចង្អុលដៃ ចង្អុលទៅឆ្វេង ស្តាំ លើ ក្រោម ខ្ពស់ ទាប ជិត ឆ្ងាយ... ទៅតាមអត្ថន័យក្នុងសាច់រឿង។ ក្បាច់នេះមានលក្ខណៈដូចរុក្ខជាតិដុះចេញជាពន្លក។ |
| **៣១- ក្បាច់ឆា** | ឈ្មោះក្បាច់បាតឬក្បាច់មូលដ្ឋានសម្រាប់បំពត់រាងកាយ ដើម្បីបង្កើនសោភណភាព និង សុក្រឹតភាព តាមចលនាក្បាច់យឺតៗ ដោយប្រឹងសង្កត់ឱ្យនួន រមួត បញ្ឆាគ្រប់សរសៃ គ្រប់សន្លាក់ និង គ្រប់សាច់ដុំ តាមចង្វាក់ភ្លេងពិណពាទ្យ ឬ តាមរនាតឯក និង សម្ភោរ ឬ ប្រសិនបើគ្មានឧបករណ៍ភ្លេង អ្នកហាត់ទាំងអស់ស្រែកជាចង្វាក់ព្រមៗគ្នាថា «ចាក់ ចូង ចាក់ ធីង ធីងធីង ចូង ធីង»។ |
| **៣២- ក្បាច់ឆា-បញ្ចុះ** | ឈ្មោះក្បាច់បាតឬក្បាច់មូលដ្ឋានសម្រាប់បំពត់រាងកាយ ដើម្បីបង្កើនសោភណភាព និង សុក្រឹតភាព តាមចង្វាក់ភ្លេងពិណពាទ្យ ឬ តាមរនាតឯក និង សម្ភោរ ឬ ប្រសិនបើគ្មានឧបករណ៍ភ្លេងទេ អ្នកហាត់ទាំងអស់ស្រែកជាចង្វាក់ព្រមៗគ្នា។ |

| | |
|---|---|
| ៣៣- ក្បាច់ជីប | ក្បាច់ជីបមានរបៀបរាំដោយប្រើម្រាមមេដៃ និងម្រាមចង្អុលដៃ រឹតចុងម្រាមរួមភ្ជាប់គ្នាដូចផ្កានោប (ក្ដឹបផ្កាបើកមាត់ចាប) ឬ រុក្ខជាតិកំពុងចេញត្រួយ។ |
| ៣៤- ក្បាច់ជីបផ្កាប់ | ឈ្មោះក្បាច់មេមួយប្រភេទដកចេញពីក្បាច់ជីប ដោយដាក់ចុងជីបឱ្យផ្កាប់សំយ៉ុងចុះក្រោម។ |
| ៣៥- ក្បាច់ជីបផ្កាប់ឆ្វេង | ឈ្មោះក្បាច់រាំមួយប្រភេទ ដោយដាក់ចុងជីបដៃឆ្វេងឱ្យផ្កាប់សំយ៉ុងចុះក្រោម ស្មើចុងចិញ្ចើម ស្មើចុងដង្ហើម ឬ ស្មើចង្កេះ។ |
| ៣៦- ក្បាច់ជីបផ្កាប់ស្ដាំ | ឈ្មោះក្បាច់រាំមួយប្រភេទ ដោយដាក់ចុងជីបនៃដៃស្ដាំឱ្យផ្កាប់សំយ៉ុងចុះក្រោម ស្មើចុងចិញ្ចើម ស្មើចុងដង្ហើម ឬ ស្មើចង្កេះ។ |
| ៣៧- ក្បាច់ជីបផ្កាប់ស្ដាំឆ្វេង | ឈ្មោះក្បាច់រាំមួយប្រភេទ ដោយដាក់ចុងជីបដៃទាំងពីរឱ្យផ្កាប់សំយ៉ុងចុះក្រោម ស្មើចុងចិញ្ចើម ស្មើចុងដង្ហើម ឬ ស្មើចង្កេះ។ |
| ៣៨- ក្បាច់ជីបផ្ងារ | ឈ្មោះក្បាច់មេមួយប្រភេទ ដកចេញពីក្បាច់ជីប ដោយដាក់ចុងជីបងើយឡើងលើ។ |
| ៣៩- ក្បាច់ជីបផ្ងារឆ្វេង | ឈ្មោះក្បាច់រាំមួយប្រភេទ ដោយដាក់ចុងជីបដៃឆ្វេងឱ្យងើយឡើងលើស្មើចុងចិញ្ចើម ស្មើចុងដង្ហើម ឬ ស្មើចង្កេះ។ |

| | |
|---|---|
| ៤០- ក្បាច់ជីបផ្ការស្តាំ | ឈ្មោះក្បាច់រាំមួយប្រភេទ ដោយដាក់ចុងជីបដៃស្តាំឱ្យងើយឡើងលើស្មើចុងចិញ្ចើម ស្មើចុងដង្ហើម ឬ ស្មើចង្កេះ។ |
| ៤១- ក្បាច់ជីបផ្ការស្តាំឆ្វេង | ឈ្មោះក្បាច់រាំមួយប្រភេទ ដោយដាក់ចុងជីបដៃទាំងពីរឱ្យងើយឡើងលើស្មើចុងចិញ្ចើម ស្មើចុងដង្ហើម ឬ ស្មើចង្កេះ។ |
| ៤២- ក្បាច់ជើងប្រើស | ក្បាច់ជើងប្រើសមានរបៀបរាំដោយប្រើម្រាមចង្អុលដៃភ្ជាប់ម្រាមដៃកណ្តាលទន្ទឹមគ្នា ឯម្រាមបីទៀតបត់ប្រជុំភ្ជាប់គ្នាមានលំនាំដូចរុក្ខ-ជាតិទើបបែកមែកចេញពីគ្នា។<br>ឧ. ក្នុងរបាំបុរាណ អ្នកដើរតួតំណាងសត្វប្រើសប្រើក្បាច់ជើងប្រើស ដោយលើកដៃទាំង២ខាងធ្វើចលនា ហើយលោតផ្លោតៗតាមដំណើរសត្វប្រើស។ |
| ៤៣- ក្បាច់ឈរពង់ | ឈ្មោះក្បាច់រាំដែលឈរជើងតែម្ខាង ដោយបញ្ឈប់ជង្គង់បន្តិច ឯជើងម្ខាងទៀតលើកកាច់ពង់ទៅក្រោយ ដោយឱ្យប្រអប់ជើងកាច់កោងក្នុងលំនាំ-ង។ |
| ៤៤- ក្បាច់ឈរពង់ជើងឆ្វេង | ឈ្មោះក្បាច់រាំដែលឈរជើងស្តាំ ដោយបញ្ឈប់ជង្គង់បន្តិច ឯជើងឆ្វេងលើកកាច់ពង់ទៅក្រោយដោយឱ្យប្រអប់ជើងកាច់កោងក្នុងលំនាំ-ង។ |

| | |
|---|---|
| ៤៥- ក្បាច់ឈរពង់ជើងស្ដាំ | ឈ្មោះក្បាច់រាំដែលឈរជើងឆ្វេង ដោយបញ្ឈរជង្គង់បន្តិច ឯជើងស្ដាំលើកកាច់ពង់ទៅក្រោយដោយឱ្យប្រអប់ជើងកាច់កោងក្នុងលំនាំ-ង។ |
| ៤៦- ក្បាច់ដើរ | ឈ្មោះក្បាច់រាំមួយប្រភេទដោយប្រើជើងឆ្វេងបោះទៅមុន និង ជើងស្ដាំអូសឈូសបោះទៅមុខក្បែរជើងឆ្វេង ដោយឱ្យម្រាមជើងទាំងពីរខាងកាច់-ងឡើងលើ។ |
| ៤៧- ក្បាច់តឹន | ឈ្មោះក្បាច់រាំមួយប្រភេទដែលប្រើចុងជើងទាំងពីរបញ្ឆាន់លើឆាក កែងជើងទាំងពីរទល់គ្នា ចុងជើងញែកចេញក្រៅ ហើយ ធ្វើចលនាជញ្រ្ជំ។<br>ឧ. អ្នករាំប្រើក្បាច់តឹននៅក្នុងរបាំមណីមេខលា។ |
| ៤៨- ក្បាច់បញ្ចុះ | ឈ្មោះក្បាច់បាតឬក្បាច់មូលដ្ឋានសម្រាប់បំពត់រាងកាយ ដើម្បីបង្កើនសោភណភាព និង សុក្រឹតភាព តាមចលនាលឿនរហ័ស ហៅថា «ឡូក» តាមចង្វាក់ភ្លេងពិណពាទ្យ ឬ តាមរនាតឯក និង សម្ភោរ ឬ ប្រសិនបើគ្មានឧបករណ៍ភ្លេងទេ អ្នកហាត់ទាំងអស់ស្រែកជាចង្វាក់ព្រមៗគ្នាថា «តាក់ ធីង ធីង ធីង តាក់ ធីង ធីង...», «តាក់ តាក់ ធីង តាក់ ធីង...», «ធីង ធីង ធីង...»។ |

| | |
|---|---|
| **៤៩- ក្បាច់ប៉ប្រេក** | ក្បាច់លម្អដំបូលអគារមួយប្រភេទ មានទម្រង់ជាស្លែក្តោប ភ្នែកមាន់ សម្រាប់ដាក់នៅចុងចែងសំយាបព្រំ (អ្នកស្រុកខ្លះហៅក្បាច់នេះថា ក្បាច់ភ្នែកមាន់)។<br>ឧ. គេដាក់ក្បាច់ប៉ប្រេកឬក្បាច់ភ្នែកមាន់នៅចុងចែងនៃព្រំអគារ។ |
| **៥០- ក្បាច់ប្រធឹប** | ១- ឈ្មោះក្បាច់រាំមួយប្រភេទសម្រាប់តួយក្ស ដែលប្រើជើងទាំងពីរតន្ត្រំលើឆាក ដោយជើងស្តាំតន្ត្រំឱ្យធ្ងន់ខ្លាំងជាងជើងឆ្វេង។<br>២- ឈ្មោះក្បាច់រាំមួយប្រភេទសម្រាប់តួស្វា ដែលប្រើជើងស្តាំតន្ត្រំលើឆាក ឯជើងឆ្វេងរុញប្រអប់ជើងទៅចំហៀង និង ម្រាមជើងទាំងអស់-ងឡើងលើ ដោយកែងជើងទល់ជាប់នឹងឆាក។ |
| **៥១- ក្បាច់ពង់** | ក្បាច់ពង់មានរបៀបរាំដោយបើកដៃជារង្វង់។ |
| **៥២- ក្បាច់ពង់ក្រោម** | ក្បាច់ពង់ក្រោមមានរបៀបរាំដោយលុតជង្គង់លើកជើងម្ខាងបត់ទៅក្រោយនិងលើកឡើងលើ ដោយបើកដៃជារង្វង់។ |
| **៥៣- ក្បាច់ពង់ឆ្វេង** | ក្បាច់ពង់ឆ្វេងមានរបៀបរាំដោយបើកដៃឆ្វេងជារង្វង់។ |
| **៥៤- ក្បាច់ពង់រង្វង់** | ក្បាច់ពង់រង្វង់មានរបៀបរាំដោយបើកដៃទាំងពីរខាងជារង្វង់។ |

| | |
|---|---|
| **៥៥- ក្បាច់ពង់លើ** | ក្បាច់ពង់លើមានរបៀបរាំដោយឈរជើងមួយ បញ្ឆចជង្គង់បន្តិច លើកជើងម្ខាងទៀតបត់ទៅក្រោយនិងលើកឡើងលើដោយបើកដៃជារង្វង់។ |
| **៥៦- ក្បាច់ពង់ស្តាំ** | ក្បាច់ពង់ស្តាំមានរបៀបរាំដោយបើកដៃស្តាំជារង្វង់។ |
| **៥៧- ក្បាច់ពត់ដៃជើង** | លំហាត់បំពត់រាងកាយ ដៃ ជើង កដៃ កជើង ម្រាមដៃ ម្រាមជើង  ព្រមទាំង ក ក្បាល ស្មា ចង្កេះ ដងខ្លួន តាមក្បួន ដោយមិនមានភ្លេងកំដរ ដើម្បីឱ្យមានភាពទន់ភ្លន់រៀងរាល់ពេលព្រឹក។ |
| **៥៨- ក្បាច់ភ្លូក** | ឈ្មោះក្បាច់រាំមួយប្រភេទដែលឈរឬអង្គុយដោយប្រើដងខ្លួនផ្អៀងជ្រុលហួសទៅឆ្វេង ឬទៅស្តាំ។ ក្បាច់នេះមិនប្រើនៅក្នុងរបាំបុរាណខ្មែរឡើយ។ |
| **៥៩- ក្បាច់រត់** | ឈ្មោះក្បាច់រាំមួយប្រភេទដោយប្រើជើងទាំងពីររត់ឈូសលឿនទៅមុខជាលក្ខណៈសិល្បៈដោយឱ្យម្រាមជើងទាំងពីរកាច់-ងឡើងលើ។ |
| **៦០- ក្បាច់លា** | ក្បាច់លាមានរបៀបរាំដោយប្រើម្រាមដៃបួនលា  កាច់ងស្មើតជាប់គ្នា  ឯម្រាមមេដៃកាច់ចូលបាតដៃមានលក្ខណៈដូចស្លឹកឈើ។ |

| | |
|---|---|
| ៦១- ក្បាច់លាផ្ទារ | ឈ្មោះក្បាច់រាំដែលប្រើម្រាមដៃបួនលា កាច់ងស្មើតជាប់គ្នា ឯម្រាមមេដៃកាច់ចូលបាតដៃ ដោយផ្ងារបាតដៃឡើងលើឬរាដៃទៅមុខ។ |
| ៦២- ក្បាច់លាវង់កណ្តាល | ឈ្មោះក្បាច់មេមួយប្រភេទដកចេញពីក្បាច់លាផ្ងារ ដោយលើកដៃបើកជារង្វង់ ដាក់ចុងម្រាមដៃស្មើចុងដង្ហើម។ |
| ៦៣- ក្បាច់លាវង់កណ្តាលឆ្វេង | ឈ្មោះក្បាច់រាំមួយប្រភេទ ដោយលើកដៃឆ្វេងបើកជារង្វង់ ដាក់ចុងម្រាមដៃឆ្វេងស្មើចុងដង្ហើម។ |
| ៦៤- ក្បាច់លាវង់កណ្តាលស្តាំ | ឈ្មោះក្បាច់រាំមួយប្រភេទ ដោយលើកដៃស្តាំបើកជារង្វង់ ដាក់ចុងម្រាមដៃស្តាំស្មើចុងដង្ហើម។ |
| ៦៥- ក្បាច់លាវង់កណ្តាលស្តាំឆ្វេង | ឈ្មោះក្បាច់រាំមួយប្រភេទ ដោយលើកដៃទាំងពីរបើកជារង្វង់ ដាក់ចុងម្រាមដៃទាំងពីរស្មើចុងដង្ហើម។ |
| ៦៦- ក្បាច់លាវង់ក្រោម | ឈ្មោះក្បាច់មេមួយប្រភេទដកចេញពីក្បាច់លាផ្ងារ ដោយលើកដៃបើកជារង្វង់ ដាក់កដៃស្មើនឹងចង្កេះ។ |
| ៦៧- ក្បាច់លាវង់ក្រោមឆ្វេង | ឈ្មោះក្បាច់រាំមួយប្រភេទ ដោយលើកដៃឆ្វេងបើកជារង្វង់ ដាក់កដៃឆ្វេងស្មើនឹងចង្កេះ។ |

| | |
|---|---|
| ៦៨- ក្បាច់លាវង់ក្រោមស្ដាំ | ឈ្មោះក្បាច់រាំមួយប្រភេទ ដោយលើកដៃស្ដាំបើកជារង្វង់ ដាក់កដៃស្ដាំស្មើនឹងចង្កេះ ។ |
| ៦៩- ក្បាច់លាវង់ក្រោមស្ដាំឆ្វេង | ឈ្មោះក្បាច់រាំមួយប្រភេទ ដោយលើកដៃទាំងពីរបើកជារង្វង់ ដាក់កដៃទាំងពីរស្មើនឹងចង្កេះ។ |
| ៧០- ក្បាច់លាវង់លើ | ឈ្មោះក្បាច់មេមួយប្រភេទដកចេញពីក្បាច់លាផ្ទារ ដោយលើកដៃបើកជារង្វង់ ដាក់ចុងម្រាមដៃស្មើចុងចិញ្ចើម។ |
| ៧១- ក្បាច់លាវង់លើឆ្វេង | ឈ្មោះក្បាច់របៀបរាំមួយប្រភេទ ដោយលើកដៃឆ្វេងបើកជារង្វង់ ដាក់ចុងម្រាមដៃឆ្វេងស្មើចុងចិញ្ចើមឆ្វេង។ |
| ៧២- ក្បាច់លាវង់លើស្ដាំ | ឈ្មោះក្បាច់របៀបរាំមួយប្រភេទ ដោយលើកដៃស្ដាំបើកជារង្វង់ ដាក់ចុងម្រាមដៃស្ដាំស្មើចុងចិញ្ចើមស្ដាំ។ |
| ៧៣- ក្បាច់លាវង់លើស្ដាំឆ្វេង | ឈ្មោះក្បាច់រាំមួយប្រភេទ ដោយលើកដៃទាំងពីរបើកជារង្វង់ ដាក់ចុងម្រាមដៃទាំងពីរស្មើចុងចិញ្ចើមទាំងពីរ។ ក្បាច់នេះមានលក្ខណៈពិសេសសម្រាប់ប្រើចំពោះតួអង្គសម្ដែងជាសត្វស្លាបធំៗ ដូចជាសត្វគ្រុឌ សត្វក្ងោក ជាដើម។ |
| ៧៤- ក្បាច់លៀម | ឈ្មោះក្បាច់មេមួយប្រភេទក្នុងរបាំបុរាណខ្មែរដែលប្រើចលនាជើងចុះឡើងឆ្វេង ស្ដាំ មុខ ក្រោយ បើក និង បិទ ជាដើម។ |

| | |
|---|---|
| **៧៥- ក្បាច់លៀមឈរទាបបិទឆ្វេង** | របៀបរាំមួយប្រភេទដោយប្រើជើងឆ្វេងលើកឡើងពាក់កណ្តាល កាច់កជើងនិងម្រាមជើងឡើងបែរទៅមុខ ឯជើងស្តាំឈរបញ្ឈច់ជង្គង់បន្តិចបែរទៅមុខ។ |
| **៧៦- ក្បាច់លៀមឈរទាបបិទស្តាំ** | របៀបរាំមួយប្រភេទដោយប្រើជើងស្តាំលើកឡើងពាក់កណ្តាល កាច់កជើងនិងម្រាមជើងឡើងបែរទៅមុខ ឯជើងឆ្វេងឈរបញ្ឈច់ជង្គង់បន្តិចបែរទៅមុខ។ |
| **៧៧- ក្បាច់លៀមឈរទាបបើកឆ្វេង** | របៀបរាំមួយប្រភេទដោយប្រើជើងឆ្វេងលើកឡើងពាក់កណ្តាលបែរទៅឆ្វេង កាច់កជើងនិងម្រាមជើងឡើង ឯជើងស្តាំឈរបញ្ឈច់ជង្គង់បន្តិចបែរទៅមុខ។ |
| **៧៨- ក្បាច់លៀមឈរទាបបើកស្តាំ** | របៀបរាំមួយប្រភេទដោយប្រើជើងស្តាំលើកឡើងពាក់កណ្តាលបែរទៅស្តាំ កាច់កជើងនិងម្រាមជើងឡើង ឯជើងឆ្វេងឈរបញ្ឈច់ជង្គង់បន្តិចបែរទៅមុខ។ |
| **៧៩- ក្បាច់លៀមឈរបិទឆ្វេង** | របៀបរាំមួយប្រភេទដោយប្រើជើងឆ្វេងលើកឡើងពាក់កណ្តាល កាច់កជើងនិងម្រាមជើងឡើងបែរទៅមុខ ឯជើងស្តាំឈរបន្តឹងអស់បែរទៅមុខ។ |

| | |
|---|---|
| ៨០- ក្បាច់លៀមឈរបិទស្តាំ | របៀបរាំមួយប្រភេទដោយប្រើជើងស្តាំលើកឡើងពាក់កណ្តាលដោយកាច់កជើងនិងម្រាមជើងឡើងបែរទៅមុខ ឯជើងឆ្វេងឈរបន្តឹងអស់ បែរទៅមុខ។ |
| ៨១- ក្បាច់លៀមឈរបើកឆ្វេង | របៀបរាំមួយប្រភេទដោយប្រើជើងឆ្វេងលើកឡើងពាក់កណ្តាលបែរទៅឆ្វេង កាច់កជើងនិងម្រាមជើងឡើង ឯជើងស្តាំឈរបន្តឹងអស់បែរទៅមុខ។ |
| ៨២- ក្បាច់លៀមឈរបើកស្តាំ | របៀបរាំមួយប្រភេទដោយប្រើជើងស្តាំលើកឡើងពាក់កណ្តាលបែរទៅស្តាំ កាច់កជើងនិងម្រាមជើងឡើង ឯជើងឆ្វេងឈរបន្តឹងអស់ បែរទៅមុខ។ |
| ៨៣- ក្បាច់លៀមដើរទា | របៀបរាំមួយប្រភេទដោយបន្ទាបខ្លួនចុះ ឱ្យគូទស្មើជង្គង់ ក្បាលជង្គង់ហុចទៅមុខទាញចេញពីគ្នាបន្តិច បង្ហើបកែងជើងឡើង គូទហើបពីកែងជើង ហើយ ដើរទៅមុខ។<br><u>បញ្ជាក់</u> : ពេលដើរទោរទៅមុខ មិនឱ្យគូទសង្កត់ជាប់លើកែងជើងទេ។ |
| ៨៤- ក្បាច់លៀមបញ្ឆិតឆ្វេង | របៀបរាំមួយប្រភេទដោយប្រើជើងឆ្វេងបោះទៅមុខបញ្ឆិតខាងឆ្វេងខ្លួនបន្តិច រួចបន្ទាបខ្លួនចុះពាក់កណ្តាល ដោយសង្កត់ទម្ងន់ជងខ្លួន |

| | |
|---|---|
| | ទោរទៅលើជើងមុខ ហើយ បង្ហើបកែងបន្តិច ជើងស្តាំបោះទៅក្រោយ បញ្ឆិតខាងស្តាំខ្លួនម្រាមនិងជង្គង់បែរទៅខាងស្តាំ ដោយបង្ហើបកែងបន្តិច។ |
| **៨៥- ក្បាច់លៀម បញ្ឆិតទាបឆ្វេង** | របៀបរាំមួយប្រភេទដោយប្រើជើងឆ្វេងបោះបញ្ឆិតទៅមុខខាងឆ្វេងខ្លួនបន្តិច កែងជើងបង្ហើបឡើង បន្ទាបខ្លួនចុះ ទម្ងន់ដងខ្លួនសង្កត់លើជើងឆ្វេង ទោរទៅមុខបន្តិច ជើងស្តាំបោះសណ្តូកទៅក្រោយបញ្ឆិតដងខ្លួន ម្រាមជើងនិងជង្គង់បែរទៅខាងស្តាំ ដងខ្លួននិងកែងជើងបង្ហើបឡើងបន្តិច។ |
| **៨៦- ក្បាច់លៀម បញ្ឆិតទាបស្តាំ** | របៀបរាំមួយប្រភេទដោយប្រើជើងស្តាំបោះបញ្ឆិតទៅមុខ ខាងស្តាំខ្លួនបន្តិច កែងជើងបង្ហើបឡើង បន្ទាបខ្លួនចុះ ទម្ងន់ដងខ្លួនសង្កត់លើជើងស្តាំទោរទៅមុខបន្តិច ជើងឆ្វេងបោះសណ្តូកទៅក្រោយបញ្ឆិតដងខ្លួន ម្រាមជើងនិងជង្គង់បែរទៅខាងឆ្វេង ដងខ្លួននិងកែងជើងបង្ហើបឡើងបន្តិច។ |
| **៨៧- ក្បាច់លៀម បញ្ឆិតស្តាំ** | របៀបរាំមួយប្រភេទដោយប្រើជើងស្តាំបោះទៅមុខ បញ្ឆិតខាងស្តាំខ្លួនបន្តិច រួចបន្ទាបខ្លួនចុះពាក់កណ្តាល ដោយសង្កត់ទម្ងន់ដងខ្លួនទោរទៅលើជើងមុខ ហើយ បង្ហើបកែងបន្តិច |

| | |
|---|---|
| | ជើងឆ្វេងបោះទៅក្រោយ បញ្ឆិតខាងឆ្វេងខ្លួនម្រាមនិងជង្គង់បែរទៅខាងឆ្វេង ដោយបង្ហើបកែងបន្តិច។ |
| **៨៨- ក្បាច់លៀមផ្អែកឆ្វេង** | របៀបរាំមួយប្រភេទដោយកន្ទែកជើងទាំងពីរបន្ទាបខ្លួនពាក់កណ្ដាលបែរទៅឆ្វេង ជើងស្ដាំបញ្ឆាច់ជង្គង់បន្តិច ម្រាមនិងជង្គង់បែរទៅស្ដាំសង្កត់ទម្ងន់ដងខ្លួនទោរទៅលើជើងស្ដាំ ឯជើងឆ្វេងបន្ដឹងបោះទៅឆ្វេងដោយកែងជើងសង្កត់ចុះ បង្ហើបចុងជើងឡើងលើ។ |
| **៨៩- ក្បាច់លៀមផ្អែកស្ដាំ** | របៀបរាំមួយប្រភេទដោយបោះជើងឆ្វេងបញ្ឆាច់ទៅមុខ និង ជើងស្ដាំបោះបន្ដឹងទៅក្រោយ។ ជើងឆ្វេងបោះទៅមុខ ប្រអប់និងជង្គង់ជើងឆ្វេងបែរទៅមុខចំ បញ្ឆាច់ចុះពាក់កណ្ដាល សង្កត់ទម្ងន់ដងខ្លួនទោរទៅមុខបន្តិច ឯកែងជើងស្ដាំបង្ហើបឡើងលើ ចុងម្រាមទប់បន្ថើរទៅលើកម្រាល ក្នុងលក្ខណៈឈរបន្ទាបខ្លួនពាក់កណ្ដាល។ |
| **៩០- ក្បាច់លៀមលុតជង្គង់** | របៀបរាំមួយប្រភេទអង្គុយលុតជង្គង់ចុះទាំងពីរ ចន្លោះជង្គង់ឃ្លាតចេញពីគ្នាសមតាមដងខ្លួន គូទដាក់លើកែងជើង ដោយកែងទាំងពីរខិតជាប់គ្នា ចុងម្រាមជើងចុចទៅលើកម្រាល។ |

| | |
|---|---|
| ៩១- ក្បាច់លៀម លុតជង្គង់ឆ្វេង | របៀបរាំមួយប្រភេទដោយលុតជង្គង់ឆ្វេងចុះគូទហើបចេញពីកែងជើងបន្តិច ជើងស្តាំទាញបោះទៅមុខបញ្ឆិតស្តាំ ចុចចុងម្រាមជើងលើកម្រាល បង្ហើបកែងបន្តិច ដងខ្លួនសង្កត់ទៅលើជើងស្តាំទោរទៅមុខបន្តិច។ |
| ៩២- ក្បាច់លៀម លុតជង្គង់ស្តាំ | របៀបរាំមួយប្រភេទដោយលុតជង្គង់ស្តាំចុះគូទហើបចេញពីកែងជើងបន្តិច ជើងឆ្វេងទាញបោះទៅមុខបញ្ឆិតឆ្វេង ចុចចុងម្រាមជើងលើកម្រាល បង្ហើបកែងបន្តិច ដងខ្លួនសង្កត់ទៅលើជើងឆ្វេងទោរទៅមុខបន្តិច។ |
| ៩៣- ក្បាច់លៀមស្មើ | របៀបរាំមួយប្រភេទដោយបន្ទាបខ្លួនចុះពាក់កណ្តាល ឯជើងឆ្វេងនិងជើងស្តាំកន្ធែកចេញបន្តិច កែងជើងប្រឈមគ្នា ម្រាមជើងឆ្វេងស្តាំងទ្បើងលើ។ |
| ៩៤- ក្បាច់លៀម ស្មើឆ្វេងមុខ | របៀបរាំមួយប្រភេទដោយបន្ទាបខ្លួនចុះពាក់កណ្តាល រួចជើងឆ្វេងនិងជើងស្តាំកន្ធែកចេញពីគ្នាបន្តិច កែងជើងទម្រង់ប្រឈមគ្នា ម្រាមជើងឆ្វេងស្តាំ-ងទ្បើងលើ ប៉ុន្តែ ជើងឆ្វេងបោះលយទៅមុខបន្តិច។ |
| ៩៥- ក្បាច់លៀម ស្មើស្តាំមុខ | របៀបរាំមួយប្រភេទដោយបន្ទាបខ្លួនចុះពាក់កណ្តាល រួចជើងឆ្វេងនិងជើងស្តាំកន្ធែកចេញ |

| | |
|---|---|
| | ពីគ្នាបន្តិច កែងជើងទម្រង់ប្រឈមគ្នា ម្រាមជើងឆ្វេងស្តាំ-ងឡើងលើ ប៉ុន្តែ ជើងស្តាំបោះលយទៅមុខបន្តិច។ |
| **៩៦- ក្បាច់លៀម អង្គុយជើងមួយ** | របៀបរាំមួយប្រភេទដោយលុតជង្គង់ឆ្វេងចុះបែរចំទៅមុខ ដាក់គូទអង្គុយសង្កត់ទៅលើកែងជើង ឯក្បាលជង្គង់ស្តាំដាក់លើកម្រាលទៅក្រោយ លើកបាតជើងឡើងលើនិងកាច់ក ជើងចុះ។ |
| **៩៧- ក្បាច់លៀម អង្គុយអេះ** | របៀបរាំមួយប្រភេទដោយដាក់គូទអង្គុយទៅកម្រាល ជើងស្តាំបោះសណ្តូកទៅមុខជាងពាក់កណ្តាលដោយបញ្ឈរជង្គង់ឡើង កែងជើងជាប់កម្រាល ប្រអប់ជើងបែរចំទៅមុខ ឯជើងឆ្វេងដូចជើងស្តាំដែរ តែបោះទៅមុខខ្លីជាងជើងស្តាំបន្តិច។ |
| **៩៨- ក្បាច់លំនឹង** | ឈ្មោះក្បាច់រាំមួយប្រភេទដែលឈរឬអង្គុយដោយប្រើដងខ្លួនក្នុងលំនាំត្រង់ បង្ហាញពីលក្ខណៈអែនអន ពត់ពេន ដើម្បីកុំឱ្យធ្មឹងក្រ-ទាំង។ ក្បាច់នេះជាសោភណភាពមួយដ៏ល្អឯកក្នុងរបាំបុរាណខ្មែរ។ |
| **៩៩- ក្បាច់សំពះ បួងសួង** | ឈ្មោះក្បាច់រាំមួយប្រភេទ ដោយផ្គុំប្រអប់បាតដៃទាំងពីរចូលគ្នាជាបង្គុំក្នុងទម្រង់សំពះ ដាក់មេដៃស្មើចុងដង្ហើម រួចលើកបង្គុំដៃឡើងទៅលើដាក់មេដៃត្រឹមជើងសក់លើថ្ងាស។ |

| | |
|---|---|
| **១០០- ក្បាច់សំពះប្រណម្យ** | ឈ្មោះក្បាច់រាំមួយប្រភេទ ដោយផ្គុំប្រអប់បាតដៃទាំងពីរចូលគ្នាក្នុងទម្រង់សំពះ ហើយ ដាក់មេដៃស្មើចុងដង្ហើម។ |
| **១០១- ក្បាច់ហួន** | ឈ្មោះក្បាច់មេមួយប្រភេទក្នុងទម្រង់ល្ខោនបាសាក់ ដែលប្រើកាយវិការ ហក់ លោតរហ័សស្វាហាប់ ទៅតាមចង្វាក់ភ្លេងនិងទៅតាមបច្ចេក-ទេសក្បាច់ដោយឡែកៗ មាន ក្បាច់ហួនដៃ ក្បាច់ហួនផ្តិត ក្បាច់ហួនដំបង ក្បាច់ហួនដាវ ក្បាច់ហួនលំពែង ក្បាច់ហួនធ្នូ ក្បាច់ហួនកាំបិតខ្លី ក្បាច់ហួនយក្ស ក្បាច់ហួននាគ ក្បាច់ហួនសេះ ក្បាច់ហួនគ្រុឌ ក្បាច់ហួនរាជសីហ៍ ...។ |
| **១០២- ក្បាច់ហួនកាំបិតខ្លី** | របៀបសម្តែងមួយប្រភេទក្នុងទម្រង់ល្ខោនបា-សាក់ ដោយម្តងប្រើដៃស្តាំកាន់កាំបិតខ្លីនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំ ទើបប្រើដៃឆ្វេងកាន់កាំបិទខ្លីនិងជើងស្តាំគ្រវាត់ទៅមុខឱ្យប៉ះគ្នាម្តងវិញ។ បន្ទាប់មកបង្វិលខ្លួនមួយជុំទៀត ហើយជួនកាលប្រើដៃស្តាំកាន់កាំបិទខ្លីនិងជើងស្តាំគ្រវាត់ទៅមុខឱ្យប៉ះគ្នាឬប្រើដៃឆ្វេងកាន់កាំបិទខ្លីនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំទៀត ហើយ ដៃស្តាំកាន់ដាវទាញយ៉ាងរហ័ស |

| | |
|---|---|
| | ទៅលើស្មើត្រចៀក និង ហក់លោតយ៉ាងស្វាហាប់ទៅតាមចង្វាក់ភ្លេង។ ជួនកាលក្បាច់នេះមានការច្នៃប្រឌិតកាយវិការទៅតាមទេពកោសល្យនៃតួសម្ដែងនីមួយៗ។ |
| **១០៣- ក្បាច់ហួនគ្រុឌ** | របៀបសម្ដែងមួយប្រភេទក្នុងទម្រង់ល្ខោនបាសាក់ ដោយម្ដងប្រើដៃស្ដាំនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចលោតឡើងលើបង្វិលខ្លួនមួយជុំ ទើបប្រើដៃឆ្វេងនិងជើងស្ដាំគ្រវាត់ទៅមុខឱ្យប៉ះគ្នាម្ដងវិញ។ បន្ទាប់មក លោតឡើងលើបង្វិលខ្លួនមួយជុំទៀត ហើយ ជួនកាលប្រើដៃស្ដាំនិងជើងស្ដាំគ្រវាត់ទៅមុខឱ្យប៉ះគ្នា ឬ ប្រើដៃឆ្វេងនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចលោតឡើងលើបង្វិលខ្លួនមួយជុំទៀត ហើយបើកលៀមនិងសំកាំងដៃដូចគ្រុឌត្រដាងស្លាបដោយហក់លោតយ៉ាងស្វាហាប់ទៅតាមចង្វាក់ភ្លេង។ ជួនកាល ក្បាច់នេះមានការច្នៃប្រឌិតកាយវិការទៅតាមទេពកោសល្យនៃតួសម្ដែងនីមួយៗ។ |
| **១០៤- ក្បាច់ហួនដាវ** | របៀបសម្ដែងមួយប្រភេទក្នុងទម្រង់ល្ខោនបាសាក់ ដោយម្ដងប្រើដៃស្ដាំកាន់ដាវនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំ ទើបប្រើដៃឆ្វេងកាន់ដាវនិងជើងស្ដាំគ្រវាត់ទៅមុខឱ្យប៉ះគ្នាម្ដងវិញ។ បន្ទាប់មក បង្វិលខ្លួន |

| | |
|---|---|
| | មួយជុំទៀត ហើយ ជួនកាលប្រើដៃស្តាំកាន់ដាវ និងជើងស្តាំគ្រវាត់ទៅមុខឱ្យប៉ះគ្នា ឬ ប្រើដៃឆ្វេងកាន់ដាវនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំទៀត ហើយដៃស្តាំកាន់ដាវទាញយ៉ាងរហ័សទៅលើស្មើត្រចៀក និង ហក់លោតយ៉ាងស្វាហាប់ទៅតាមចង្វាក់ភ្លេង។ ជួនកាល ក្បាច់នេះមានការច្នៃប្រឌិតកាយវិការទៅតាមទេពកោសល្យនៃតួសម្តែងនីមួយៗ។ |
| **១០៥- ក្បាច់ហួនដៃ** | របៀបសម្តែងមួយប្រភេទក្នុងទម្រង់ល្ខោនបា-សាក់ ដោយម្តងប្រើដៃស្តាំនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំ ទើបប្រើដៃឆ្វេងនិងជើងស្តាំគ្រវាត់ទៅមុខឱ្យប៉ះគ្នាម្តងវិញ។ បន្ទាប់មកបង្វិលខ្លួនមួយជុំទៀត ហើយ ជួនកាល ប្រើដៃស្តាំនិងជើងស្តាំគ្រវាត់ទៅមុខឱ្យប៉ះគ្នា ឬ ប្រើដៃឆ្វេងនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំទៀត ហើយលើកដៃស្តាំលាបាតដៃវាត់ឡើងលើស្មើត្រចៀក និង ហក់លោតយ៉ាងស្វាហាប់ទៅតាមចង្វាក់ភ្លេង។ ជួនកាល ក្បាច់នេះមានការច្នៃប្រឌិតកាយវិការទៅតាមទេពកោសល្យនៃតួសម្តែងនីមួយៗ។ |
| **១០៦- ក្បាច់ហួនដំបង** | របៀបសម្តែងមួយប្រភេទក្នុងទម្រង់ល្ខោនបា-សាក់ ដោយម្តងប្រើដៃស្តាំកាន់ចុងម្ខាងនៃដំបង |

| | |
|---|---|
| | និងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំ ទើបប្រើដៃឆ្វេងកាន់ដំបងនិងជើងស្តាំគ្រវាត់ទៅមុខឱ្យប៉ះគ្នាម្តងវិញ។ បន្ទាប់មកបង្វិលខ្លួនមួយជុំទៀត ហើយ ជួនកាល ប្រើដៃស្តាំកាន់ដំបងនិងជើងស្តាំគ្រវាត់ទៅមុខឱ្យប៉ះគ្នា ឬ ប្រើដៃឆ្វេងកាន់ដំបងនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំទៀត ហើយដៃស្តាំកាន់ដំបងបោកទម្លាក់ទៅនឹងឆាក ហើយទាញយ៉ាងរហ័សទៅលើស្មើត្រចៀក និង ហក់លោតយ៉ាងស្វាហាប់ទៅតាមចង្វាក់ភ្លេង។ ជួនកាល ក្បាច់នេះមានការច្នៃប្រឌិតកាយវិការទៅតាមទេពកោសល្យនៃតួសម្តែងនីមួយៗ។ |
| **១០៧- ក្បាច់ហួនផ្លិត** | របៀបសម្តែងមួយប្រភេទក្នុងទម្រង់ល្ខោនបា-សាក់ ដោយម្តងប្រើដៃស្តាំកាន់ផ្លិតនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំ ទើបប្រើដៃឆ្វេងកាន់ផ្លិតនិងជើងស្តាំគ្រវាត់ទៅមុខឱ្យប៉ះគ្នាម្តងវិញ។ បន្ទាប់មកបង្វិលខ្លួនមួយជុំទៀត ហើយ ជួនកាល ដៃស្តាំកាន់ផ្លិតនិងជើងស្តាំគ្រវាត់ទៅមុខឱ្យប៉ះគ្នា ឬ ប្រើដៃឆ្វេងកាន់ផ្លិតនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំទៀត ហើយ ដៃស្តាំរលាស់បើកផ្លិតទៅលើយ៉ាងរហ័ស និង ហក់លោតយ៉ាងស្វាហាប់ទៅតាមចង្វាក់ភ្លេង។ ជួនកាល ក្បាច់នេះមានការច្នៃប្រឌិតកាយវិការទៅតាមទេពកោសល្យនៃតួសម្តែងនីមួយៗ។ |

| | |
|---|---|
| **១០៨- ក្បាច់ហួនផ្ទូ** | របៀបសម្ដែងមួយប្រភេទក្នុងទម្រង់ល្ខោនបា-សាក់ ដោយម្ដងប្រើដៃស្ដាំកាន់ផ្ទូនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំទើបប្រើដៃឆ្វេងកាន់ផ្ទូនិងជើងស្ដាំគ្រវាត់ទៅមុខឱ្យប៉ះគ្នាម្ដងវិញ។ បន្ទាប់មកបង្វិលខ្លួនមួយជុំទៀត ហើយជួនកាលប្រើដៃស្ដាំកាន់ផ្ទូ និង ជើងស្ដាំគ្រវាត់ទៅមុខឱ្យប៉ះគ្នា ឬ ប្រើដៃឆ្វេងកាន់ផ្ទូនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំទៀត ហើយ ដៃស្ដាំកាន់ផ្ទូទាញយ៉ាងរហ័សទៅលើស្មើត្រចៀកនិងហក់លោតយ៉ាងស្វាហាប់ទៅតាមចង្វាក់ភ្លេង។ ជួនកាល ក្បាច់នេះមានការច្នៃប្រឌិតកាយវិការទៅតាមទេពកោសល្យនៃតួសម្ដែងនីមួយៗ។ |
| **១០៩- ក្បាច់ហួននាគ** | របៀបសម្ដែងមួយប្រភេទក្នុងទម្រង់ល្ខោនបា-សាក់ ដោយម្ដងប្រើដៃស្ដាំនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចពត់ពេនបង្វិលខ្លួនមួយជុំទើបប្រើដៃឆ្វេងនិងជើងស្ដាំគ្រវាត់ទៅមុខឱ្យប៉ះគ្នាម្ដងវិញ។ បន្ទាប់មក ពត់ពេនបង្វិលខ្លួនមួយជុំទៀត ហើយ ជួនកាល ប្រើដៃស្ដាំនិងជើងស្ដាំគ្រវាត់ទៅមុខឱ្យប៉ះគ្នា ឬ ប្រើដៃឆ្វេងនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចពត់ពេនបង្វិលខ្លួនមួយជុំទៀត និង ហក់លោតយ៉ាងស្វាហាប់ |

| | |
|---|---|
| | ទៅតាមចង្វាក់ភ្លេង ទើបបើកលៀមនិងសំកាំងដៃដូចនាគបើកពពារចេញទៅចំហៀងទាំងពីរខាង។ ជួនកាល ក្បាច់នេះមានការច្នៃប្រឌិតកាយវិការទៅតាមទេពកោសល្យនៃតួសម្ដែងនីមួយៗ។ |
| **១១០- ក្បាច់ហួនរាជសីហ៍** | របៀបសម្ដែងមួយប្រភេទក្នុងទម្រង់ល្ខោនបា-សាក់ ដោយម្ដងប្រើដៃស្ដាំនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចលោតបំពត់ខ្លួនបង្វិលមួយជុំ ទើបប្រើដៃឆ្វេងនិងជើងស្ដាំគ្រវាត់ទៅមុខឱ្យប៉ះគ្នាម្ដងវិញ។ បន្ទាប់មក លោតបំពត់ខ្លួនបង្វិលមួយជុំទៀត ហើយ ជួនកាល ប្រើដៃស្ដាំនិងជើងស្ដាំគ្រវាត់ទៅមុខឱ្យប៉ះគ្នា ឬ ប្រើដៃឆ្វេងនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចលោតបំពត់ខ្លួនបង្វិលមួយជុំទៀត ហើយ ដើរចុងជើង បន្ទាប់មកលោតហក់ឡើងលើ ឬលោតហក់ពីកន្លែងមួយទៅកន្លែងមួយទៀតយ៉ាងស្វាហាប់ទៅតាមចង្វាក់ភ្លេង។ ជួនកាលក្បាច់នេះមានការច្នៃប្រឌិតកាយវិការទៅតាមទេពកោសល្យនៃតួសម្ដែងនីមួយៗ។ |
| **១១១- ក្បាច់ហួនលំពែង** | របៀបសម្ដែងមួយប្រភេទក្នុងទម្រង់ល្ខោនបា-សាក់ ដោយម្ដងប្រើដៃស្ដាំកាន់លំពែងនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយ |

| | |
|---|---|
| | ជុំ ទើបប្រើដៃឆ្វេងកាន់លំពែងនិងជើងស្តាំគ្រវាត់ទៅមុខឱ្យប៉ះគ្នាម្តងវិញ។ បន្ទាប់មកបង្វិលខ្លួនមួយជុំទៀត ហើយ ជួនកាល ប្រើដៃស្តាំកាន់លំពែងនិងជើងស្តាំគ្រវាត់ទៅមុខឱ្យប៉ះគ្នា ឬ ប្រើដៃឆ្វេងកាន់លំពែងនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំទៀត ហើយ ដៃស្តាំកាន់លំពែងទាញយ៉ាងរហ័សទៅលើស្មើត្រចៀក និង ហក់លោតយ៉ាងស្វាហាប់ទៅតាមចង្វាក់ភ្លេង។ ជួនកាល ក្បាច់នេះមានការច្នៃប្រឌិតកាយវិការទៅតាមទេពកោសល្យនៃតួសម្តែងនីមួយៗ។ |
| **១១២- ក្បាច់ហួនយក្ស** | របៀបសម្តែងមួយប្រភេទក្នុងទម្រង់ល្ខោនបាសាក់ ដោយម្តងប្រើដៃស្តាំនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នាក្នុងចលនាដែលបង្ហាញពីភាពមានទម្ងន់ អំណាច និង ភាពកាចសាហាវ រួចបង្វិលខ្លួនមួយជុំ ទើបប្រើដៃឆ្វេងនិងជើងស្តាំគ្រវាត់ទៅមុខឱ្យប៉ះគ្នាម្តងវិញ។ បន្ទាប់មកបង្វិលខ្លួនមួយជុំទៀត ហើយជួនកាល ប្រើដៃស្តាំនិងជើងស្តាំគ្រវាត់ទៅមុខឱ្យប៉ះគ្នា ឬ ប្រើដៃឆ្វេងនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំទៀតនិងហក់លោតយ៉ាងស្វាហាប់ទៅតាមចង្វាក់ភ្លេង ទើបបើកលៀម |

| | |
|---|---|
| | និងសំកាំងដៃដូចឥន្ទ្រីបើកស្លាប។ ជួនកាល ក្បាច់នេះមានការច្នៃប្រឌិតកាយវិការ ទៅតាមទេពកោសល្យនៃតួសម្ដែងនីមួយៗ។ |
| **១១៣- ក្បាច់ហួនសេះ** | របៀបសម្ដែងមួយប្រភេទក្នុងទម្រង់ល្ខោនបាសាក់ ដោយម្ដងប្រើដៃស្ដាំនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំ ទើបប្រើដៃឆ្វេងនិងជើងស្ដាំគ្រវាត់ទៅមុខឱ្យប៉ះគ្នាម្ដងវិញ។ បន្ទាប់មក បង្វិលខ្លួនមួយជុំទៀត ហើយជួនកាល ប្រើដៃស្ដាំនិងជើងស្ដាំគ្រវាត់ទៅមុខឱ្យប៉ះគ្នា ឬ ប្រើដៃឆ្វេងនិងជើងឆ្វេងគ្រវាត់ទៅមុខឱ្យប៉ះគ្នា រួចបង្វិលខ្លួនមួយជុំទៀត ហើយលើកដៃក្ដាប់កាច់កដៃទៅមុខទាំងពីរ និង ហក់លោតយ៉ាងស្វាហាប់ទៅតាមចង្វាក់ភ្លេង ដោយត្រាប់តាមសេះលុន។ ជួនកាល ក្បាច់នេះមានការច្នៃប្រឌិតកាយវិការទៅតាមទេពកោសល្យនៃតួសម្ដែងនីមួយៗ។ |
| **១១៤- ក្បាច់អង្គុយពង់** | ឈ្មោះក្បាច់រាំដែលអង្គុយលុតជង្គង់តែម្ខាង ឯជើងម្ខាងទៀតកាច់ពង់ទៅក្រោយ ដោយឱ្យប្រអប់ជើងកាច់កោងក្នុងលំនាំ-ង។ |
| **១១៥- ក្បាច់អង្គុយពង់ជើងឆ្វេង** | ឈ្មោះក្បាច់រាំដែលអង្គុយលុតជង្គង់ស្ដាំ ឯជើងឆ្វេងកាច់ពង់ទៅក្រោយ ដោយឱ្យប្រអប់ជើងកាច់កោងក្នុងលំនាំ-ង។ |

| | |
|---|---|
| ១១៦- ក្បាច់អង្គុយពង់ជើងស្ដាំ | ឈ្មោះក្បាច់រាំដែលអង្គុយលុតជង្គង់ឆ្វេង ឯជើងស្ដាំកាច់ពង់ទៅក្រោយ ដោយឱ្យប្រអប់ជើងកាច់កោងក្នុងលំនាំ-ង។ |
| ១១៧- ក្បាលខាប | ក្បាច់ចម្លាក់បុរាណមួយប្រភេទ មានសណ្ឋានជាក្បាលសត្វ ស្រដៀងគ្នានឹងក្បាលគ្រុឌ ក្បាលរាហូ ជាដើម ខាំពាំឬខ្ជាក់នូវចង្វាយក្បាច់ងៗ ជានិមិត្តរូបនៃភាពអមតៈនិងភាពរុងរឿង។ |
| ១១៨- ក្បាំងតួនាង | គ្រឿងអលង្ការធ្វើពីមាសឬលោហៈផ្សេងៗ ដែលមានទម្រង់ជាបន្ទះរាងកោងពាក់កណ្ដាលរង្វង់ ស្របតាមរង្វង់មុខ សម្រាប់បាំងសក់ពាក់ត្រង់ថ្ងាស ដោយមានរូបលម្អផ្សេងៗ ដាំត្បូងគ្រប់ពណ៌ រីឯផ្នែកខាងចុងក្បាំងមានឆ្លាក់ក្បាច់កន្ទុយហង្ស។ ក្បាំងនេះសម្រាប់បំពាក់ឱ្យតួនាងវ័យជំទង់។ |
| ១១៩- ក្បាំងសំពត់ក្រោយ | បន្ទះកំណាត់ប៉ាក់ឱនមួយប្រភេទ សម្រាប់តួយក្ស និង តួស្វាក្បាច់ ពាក់បាំងលើសំពត់ពីខាងក្រោយ។ |
| ១២០- ក្បាំងសំពត់ចំហៀង/ក្បាំងសំពត់គ្រែង | បន្ទះកំណាត់ប៉ាក់ឱនមួយប្រភេទ សម្រាប់តួនាយរោង តួយក្ស និង តួស្វាក្បាច់ ពាក់បាំងលើសំពត់ពីចំហៀងទាំងពីរខាង។ |

| | |
|---|---|
| **១២១- ក្បាំងសំពត់មុខ** | បន្ទះកំណាត់ប៉ាក់ឱនមួយប្រភេទ សម្រាប់តួនាយរោង តួយក្ស និង តួស្វាក្បាច់ ពាក់បាំងលើសំពត់ចំពីមុខ។ |
| **១២២- ក្រមាចាប៉ុច** | ប្រភេទក្រមាត្បាញពីសរសៃសូត្រ ដែលលម្អដោយពណ៌ផ្សេងៗ នៅលើផ្ទៃមានសណ្ឋានដូចគេច្បុចតាមបច្ចេកទេសច្បុចសូត្រជ្រលក់ពណ៌ (ចាប៉ុចជាវិធីចាប់ច្បុចក្រណាត់យកទៅជ្រលក់ពណ៌)។ |
| **១២៣- ក្រវិលជើង** | គ្រឿងអលង្ការមួយប្រភេទធ្វើពីលោហៈ មានសណ្ឋានដូចរ៉ឺស័រស្ប៉ៀរ៉ាល់ ដោយមានខ្សែក្នុងកងចងភ្ជាប់ សម្រាប់ឱ្យអ្នករបាំបុរាណខ្មែរពាក់លម្អនៅលើ កជើងម្ខាងមួយ ពីក្រោមកងទងឈូក។ ក្រវិលជើងក៏មានពាក់លម្អកជើងកូនក្រមុំក្នុងពិធីមង្គលការដែរ។ |
| **១២៤- ក្រវិលដៃ** | គ្រឿងប្រដាប់ដៃមួយប្រភេទ ជាខ្សែដៃធ្វើពីលោហៈ មានសណ្ឋានដូចរ៉ឺស័រស្ប៉ៀរ៉ាល់ ដោយមានខ្សែក្នុងកងចងភ្ជាប់សម្រាប់ឱ្យអ្នករបាំបុរាណខ្មែរពាក់លម្អលើ កដៃម្ខាងមួយ បន្ទាប់ពីចិញ្ចៀនក្រង។ គេអាចហៅគ្រឿងប្រដាប់នេះថា *លួសព័ន្ធ* ឬ *កងញ៉រដៃ*។ |
| **១២៥- ក្រវិលពុកបង្កង** | គ្រឿងលម្អមួយបែប ដែលភាគច្រើនពាក់នឹងទងត្រចៀក ធ្វើពីវត្ថុធាតុផ្សេងៗ មានរាងជាកងស៊កភ្ជាប់មុខគ្នា ភាគច្រើនសម្រាប់ពាក់ |

| | |
|---|---|
| | ឱ្យក្មេងស្រី។ ក្រវិលប្រភេទនេះ គេច្រើនប្រើបើក មុខពេលដែលចោះត្រចៀកដំបូង ព្រោះមាន ទម្ងន់ស្រាល។ |
| **១២៦- ក្រឹស** | គ្រឿងលម្អអាវតួយក្សក្នុងរបាំបុរាណដែលធ្វើ ពីកំណាត់ មានរាងជាក្បាច់ចក្កច័នបួនបន្ទះ ទំហំប៉ុនបាតដៃ លម្អដោយក្បាច់ប៉ាក់ឌិន ដាក់ ផ្តោបពីលើអាវ មួយនៅចំកណ្តាលទ្រូង មួយ ទៀតនៅពីក្រោយខ្នង ត្រង់កន្លែងបោះដៃផុត និងនៅក្រោមក្លៀកម្ខាងមួយ ចងរឹតដោយ បន្ទះខ្សែប៉ាក់ឌិនទំហំបីធ្នាប់។ នៅសម័យបុ-រាណ ក្រឹសធ្វើពីលោហៈ លម្អដោយចម្លាក់រូប ក្បាលខាប។ |
| **១២៧- ខឹមខាត់** | គ្រឿងអលង្ការមួយយ៉ាង ធ្វើពីលោហៈ មាន សណ្ឋានជាខ្សែក្រវាត់ដែលមានក្បាលធំ ដាំ ត្បូង និង រចនាជាក្បាច់ផ្សេងៗ។ |
| **១២៨- ខោស្នាប់ភ្លៅ** | ប្រភេទខោជើងខ្លីចង្អៀតដេរពីកំណាត់ធម្មតា នៅផ្នែកខាងលើ ឯខាងចុងជើងមានដេរភ្ជាប់ ដោយកំណាត់ល្អនិងមានរចនាប៉ាក់ឌិន សម្រាប់ តួនាយរោង តួយក្ស និង តួស្វាក្បាច់ ស្លៀកពី ក្នុងសំពត់ក្បិនខើច។ |
| **១២៩- ខ្នុក** | បច្ចេកទេសរចនាបន្ទាប់ពីស្នាច់រួច ដោយយក ទៅលាបពណ៌ឬបិទក្បាច់តាមតម្រូវការ។ |

| | |
|---|---|
| ១៣០- ខ្សែ-ក | គ្រឿងអលង្ការម្យ៉ាង ពាក់នឹងក មានសណ្ឋានជាខ្សែ ធ្វើពីវត្ថុធាតុផ្សេងៗ។ |
| ១៣១- ខ្សែឆៀង | គ្រឿងអលង្ការមួយយ៉ាងធ្វើពីលោហៈឬវត្ថុធាតុផ្សេងៗ មានសណ្ឋានជាខ្សែវែង សម្រាប់តួនាងពាក់ឆៀងពីលើស្មាឆ្វេងចំនួន២ឬ៣ខ្សែ ដោយទម្លាក់មកដល់ត្រគាកខាងស្តាំ។ គ្រឿងអលង្ការនេះមានប្រើសម្រាប់កូនក្រមុំក្នុងពេលរៀបអាពាហ៍ពិពាហ៍ដែរ។ |
| ១៣២- គ្រឿងលម្អត្រចៀក | គ្រឿងអលង្ការសម្រាប់លម្អនៅត្រង់ត្រចៀក ធ្វើពីវត្ថុធាតុផ្សេងៗដែលមានច្រើនបែប ដូចជាក្រវិល ក្រវិលពុកបង្គង រយ៉ា ការ ។ល។ |
| ១៣៣- ចន | ផ្នែកមួយនៃមកុដភ្ជាប់នឹងនៃបក្តោបទៅក្រោយ ឬក្រោមត្រចៀក ដោយឆ្លាក់ក្បាច់អង្គរទម្រង់កន្ទុយហង្ស ក្បាច់កញ្ចាំង ឬ លម្អក្បាច់ផ្សេងៗ ជួនមានដាំត្បូង។ |
| ១៣៤- ចិញ្ចៀនក្រង | គ្រឿងប្រដាប់ដៃមួយប្រភេទ ជាខ្សែដៃមានសណ្ឋានដូចចិញ្ចៀនចម្រៀកផ្តៅរាបតូចៗ ក្រងជាខ្សែដៃ ដាំត្បូងរាយពទ្ធជុំវិញ ចងភ្ជាប់នឹងខ្សែដោយដាក់ផ្តេកបញ្ឈិត ប្រដេញគ្នាចំនួន៧ឬ៩វង់ សម្រាប់ឱ្យអ្នករបាំបុរាណខ្មែរពាក់នៅលើកដៃចំនួន២ខ្សែម្ខាងបន្ទាប់ពីស្លឹកទេស។ |

| | |
|---|---|
| **១៣៥- ចិញ្ចៀន ចម្រៀកផ្គៅ** | គ្រឿងអលង្ការដៃមួយប្រភេទធ្វើពីលោហៈ សម្រាប់ពាក់លម្អលើម្រាមដៃ ជាពិសេស លើម្រាមនាងដៃ។ នៅលើជញ្ជាំងប្រាសាទអង្គរវត្ត យើងឃើញចម្លាក់អប្សរខ្លះពាក់ចិញ្ចៀន ចម្រៀកផ្គៅនៅគ្រប់ម្រាមដៃទាំង១០ និង នៅក្នុងអំឡុងទសវត្សរ៍ទី៦ នៃសតវត្សរ៍ទី២០ អ្នករាំរបាំអប្សរាក៏ពាក់ចិញ្ចៀនចម្រៀកផ្គៅគ្រប់ម្រាមទាំង១០ដែរ។ |
| **១៣៦- ចឹម** | តំណក់ម្សៅបីចំណុចជារាងត្រីកោណដែលក្បិតលើថ្ងាសតួព្រាហ្មណ៍ក្នុងរបាំព្រាហ្មណ៍។ |
| **១៣៧- ចុកជាយ** | ផ្នែកចុងជាយនៃសំពត់ក្បិនរបស់តួនាយរោង តួយក្ស តួស្វាក្បាច់ ដែលបត់ជាផ្នត់ត្រង់កន្លែងជាយក្បិនសម្រាប់បត់ចេញមកក្រៅរួចដេរភ្ជាប់ពីលើខ្សែចំណងមានចុងប្រវែង១០សង់ទីម៉ែត្រ ខុសពីកន្ទុយក្បិនធម្មតាដែលគេញ៉ុកចូលក្នុង។ |
| **១៣៨- ឆាកក្លារបែន** | ទីសម្ដែងដែលមានរាងជាកាកបាទ ស្ថិតខាងនៅមុខប្រាសាទធំខ្លះ សម្រាប់អ្នករបាំបុរាណរាំក្នុងពិធីផ្សេងៗ។ |
| **១៣៩- ឆាកទំនើប** | ទីសម្ដែងដែលមានការតុបតែងតាមលក្ខណៈបច្ចេកវិជ្ជាខ្ពស់ តាមសម័យកាលទំនើប បង្កើតបានជាទស្សនីយភាពផ្សេងៗដ៏អស្ចារ្យ។ |

| | |
|---|---|
| **១៤០- ឆាកនិមិត្តរូប** | ទីសម្តែងដែលមានការតុបតែងតែវាំងនន សម្រាប់បិទបាំងនិងគ្រែល្អប្រណីតមួយដាក់ចំកណ្តាលឆាក។ គ្រែនេះតំណាងឱ្យរាជវាំង រាជបល្លង្ក ទីដែលអង្គុយ ឬ ព្រៃភ្នំ ជាដើម។ អ្នកទស្សនាអាចយល់បាន តាមរយៈការសម្តែង ការប្រើក្បាច់រាំ និង ការច្រៀងរៀបរាប់។ |
| **១៤១- ឆាកអច្ឆរិយៈ** | ទីសម្តែងដែលតុបតែងលម្អដោយដើមឈើមានផ្លែផ្កាលាបលនពណ៌ទឹកមាសឬទឹកប្រាក់។ ដើមឈើទាំងអស់នោះធ្វើពីបន្ទះក្តារមានលំនាំតាមចម្លាក់ដើមឈើនៅតាមប្រាសាទនានា មានប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន ជាដើម។ ឆាកនេះបង្កើតឡើងដំណាលគ្នានឹងសម័យរបាំអប្សរានៅទសវត្សរ៍ទី៦នៃសតវត្សរ៍ទី២០។ |
| **១៤២- ជាយជរ / មុខនាង** | ផ្នែកលាតនៃជាយទាំងពីរខាងរបស់សំពត់ហូលមួយក្បិនដែលមានគោមមួយធ្លូតនៅចំកណ្តាលនៃផ្ទៃលាត។ ខ្មែរសុរិន្ទ ហៅថា *មុខនាង*។ |
| **១៤៣- ជី** | គ្រឿងអលង្ការមួយយ៉ាងធ្វើពីវត្ថុធាតុផ្សេងៗ មានសណ្ឋានជាបន្តោងធំ មានដាំត្បូងចម្រុះពណ៌ សម្រាប់ពាក់ព្យួរបន្តោកនៅនឹងកង-ក ឬ ខ្សែ-ក។ |

| | |
|---|---|
| **១៤៤- ដូនសំពត់** | របៀបពគ្រាបសំពត់ធ្វើពីសូត្រដែលទក់ធ្វើឱ្យស្មើសាច់ ដោយយកកំណាត់ស្អាតផ្សេងទៀតទៅជ្រលក់ទឹក រួចពូតឱ្យអស់ទឹក ទើបយកមកជូតក្បឹតដដែលៗលើសំពត់សូត្រត្រង់កន្លែងដែលទក់ បន្ទាប់មកទើបយកសំពត់សូត្រនោះទៅស៊កនឹងស្នប្ញស្សីឬឈើ។ ចំណែកឯចុងម្ខាងទៀតនៃកំណាត់សំពត់ដែលទម្លាក់ចុះ ត្រូវស៊កដោយអង្រែបុកស្រូវដើម្បីទាញបន្តឹងឱ្យស្មើសាច់។ |
| **១៤៥- ដៃប៉ិត** | ប្រភេទដៃអាវខ្លីដែលកាត់បញ្ឆិតដោយមានផ្នែកខាងលើវែងជាងផ្នែកខាងក្រោម។ |
| **១៤៦- តាឡែក** | បំពង់ខ្យល់ធ្វើពីដីឥដ្ឋ ប្រើសម្រាប់បញ្ចូលខ្យល់ទៅក្នុងសន្លុង។<br>ឧ. តាមការស្រាវជ្រាវ តាឡែកមាន៣ប្រភេទ ៖<br>- ប្រភេទទី១ បំពង់មានអង្កត់ផ្ចិតប្រហែល ២,៥ ស.ម. ទៅ ៣,៥ ស.ម.<br>- ប្រភេទទី២ បំពង់មានអង្កត់ផ្ចិត ៤,0 ស.ម. ទៅ ៦,0 ស.ម.<br>- ប្រភេទទី៣ បំពង់មានអង្កត់ផ្ចិតប្រហែលពី ៧,0 ស.ម. ទៅ ៤0 ស.ម.។ |
| **១៤៧- តំបន់វប្បធម៌**<br>អ. cultural area | ទីតាំងភូមិសាស្ត្រឬទីតាំងស្រាវជ្រាវដែលបង្ហាញឱ្យឃើញពីនានាភាពនៃវប្បធម៌។<br>ឧ. អង្គរគឺជាតំបន់វប្បធម៌នៃប្រទេសកម្ពុជា និងជាបេតិកភណ្ឌពិភពលោក។ |

| | |
|---|---|
| **១៤៨- តួខេន** | អ្នកសម្តែងជាតួពលយក្សឬជាបរិវារ ដែលច្រើនរាំក្នុងឈុតធ្វើសង្គ្រាមធំៗ។ ពួកនេះទទួលភារៈកិច្ចកាន់ទង់ក្នុងក្បួនទ័ព ហើយក៏មានខ្លះកាន់ដាវផងដែរ។ តួទាំងអស់នេះពាក់ខ្នុកមុខយក្សមានក្បាលដុះពកៗក្នុងទម្រង់ដូចសក់ក្រញាញ់ផ្ទុយពីពួកពលមនុស្សដែលមានក្បាលជួតឈ្នួត។<br>៍. អ្នកសម្តែងតួខេននៅក្នុងរឿងព្រះជិនវង្ស។ |
| **១៤៩- តួជបលក្សណ៍** | អ្នកសម្តែងក្នុងរឿងរាមកេរ្តិ៍ជាបុត្ររបស់នាងសីតា ដែលព្រះមុនីឥសីជប ដើម្បីជំនួសរាមលក្សណ៍ដែលស្មានថាបាត់ និង ដើម្បីបំភាន់ភ្នែកនាងសីតា នៅពេលព្រះនាងយាងត្រឡប់មកពីបេះផ្លែឈើក្នុងព្រៃ។ បន្ទាប់មក រាមលក្សណ៍ក៏បានត្រឡប់មកអាស្រម ពេលនោះព្រះមុនីឥសីមានបំណងចង់រំលាយជបលក្សណ៍វិញ ប៉ុន្តែ ព្រះនាងសីតាបានសុំឱ្យទុកទាំងពីរ។ ចំពោះតួរាមលក្សណ៍ គ្រូរបាំតែងជ្រើសរើសអ្នកសម្តែងណាដែលមានសម្បុរជ្រះ និង តួជបលក្សណ៍មានសម្បុរស្រគាំដោយសារជបចេញមកពីក្អែលព្រះមុនីឥសី។ |
| **១៥០- តួទេពអប្សរ** | អ្នកសម្តែងជាតួនាងក្នុងរបាំបុរាណ។ តួទេពអប្សរមានប្រវត្តិចេញមកពីរឿងកូរសមុទ្រទឹកដោះ។<br>៍. របាំទេពអប្សរត្រូវបានដំឡើងក្នុងចន្លោះឆ្នាំ |

| | |
|---|---|
| | ១៩៦០-១៩៦៣ ដោយសម្ដេចព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរត្ន សិរីវឌ្ឍនា។ ***របាំអប្សរ*** ជាទូទៅ គេនិយមហៅថា ***របាំអប្សរា*** ។ |
| **១៥១- តួនាងនាគ** | អ្នកសម្ដែងជាតួនាងក្នុងរបាំរឿងព្រះថោង នាងនាគ។ របាំរឿងព្រះថោង នាងនាគ ត្រូវបានដំឡើងក្នុងចន្លោះឆ្នាំ១៩៦៤-១៩៦៥ ដោយសម្ដេចព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរត្ន សិរីវឌ្ឍនា។ |
| **១៥២- តួព្រាហ្មណ៍** | អ្នកសម្ដែងក្នុងរបាំព្រាហ្មណ៍ជាតួនាងដែលស្លៀកពាក់ពណ៌សតាមបែបតួនាយរោង។ តួនេះមានចឹមលើថ្ងាសតាមបែបព្រហ្មញ្ញសាសនា។ |
| **១៥៣- តួព្រាហ្មណ៍កេស** | អ្នកសម្ដែងក្នុងរឿងសុវណ្ណហង្ស ត្រង់ឈុតនាងកេសសុរិយង្គក្លែងខ្លួនជាបុរស ទៅរកឱសថទិព្វដើម្បីប្រស់ប្ដីឱ្យរស់ឡើងវិញ។ |
| **១៥៤- តួព្រាហ្មណ៍តូ (កុម្ភណ៌)** | អ្នកសម្ដែងជាតួយក្សប្រុសដែលមានចិត្តប្រមាថចង់បៀតបៀនព្រាហ្មណ៍កេស ដោយសង្ស័យថាជាមនុស្សស្រី តែ ទីបំផុតច្បាំងចាញ់នាង ហើយក៏សុំថ្វាយខ្លួនជាសេនាក្នុងលក្ខណៈជាព្រាហ្មណ៍ដែរ តែ មានរូបកាយអាក្រក់។ |
| **១៥៥- តួព្រះថោង** | អ្នកសម្ដែងជាតួនាយរោងក្នុងរបាំរឿងព្រះថោង នាងនាគ។ របាំរឿងព្រះថោង នាងនាគ ត្រូវបានដំឡើងក្នុងចន្លោះឆ្នាំ១៩៦៤-១៩៦៥ |

| | |
|---|---|
| | ដោយសម្តេចព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរត្ន សិរីវឌ្ឍនា។ |
| **១៥៦- តួរាមលក្សណ៍** | អ្នកសម្តែងក្នុងរឿងរាមកេរ្តិ៍ ជាបុត្របង្កើតរបស់ព្រះរាមនិងនាងសីតា។ |
| **១៥៧- តួឥសី** | ១- អ្នកសម្តែងជាតួតាបសមិនល្អ ដែលស្លៀកស្បង់ពណ៌លឿង ស្ពាយថង់យាមពណ៌លឿងចាស់ ពាក់មកុដខ្នុកមានកំពូលរាងកន្ទុយត្រី ដៃកាន់ឈើច្រត់ មានពាក់ពុកមាត់ ពុកចង្កា និងចិញ្ចើមពណ៌ស។<br>ឧ. តួឥសីសម្តែងក្នុងរឿងឥសីដាច់ឈាន។<br>២- អ្នកសម្តែងជាតួតាបសល្អ ដែលស្លៀកស្បង់ពណ៌លឿង ស្ពាយថង់យាមពណ៌លឿងចាស់ ដៃកាន់ឈើច្រត់ ពាក់មុខខ្នុក ដែលមានមាត់គ្រហឹប ចង្កាវែង ។<br>ឧ. តួឥសីសម្តែងក្នុងរឿងរាមកេរ្តិ៍។ |
| **១៥៨- ត្រសាល់** | គ្រឿងអលង្ការមួយយ៉ាងពាក់នឹងទងត្រចៀក ធ្វើពីវត្ថុធាតុផ្សេងៗ ដូចជា ឈើ ដីដុត ភ្លុក ស្នែង... មានសណ្ឋានស្រដៀងនឹងត្បាល់បុកស្រូវ ដែលមានប្រើតាំងពីសម័យបុរាណ។ |
| **១៥៩- ថង់សំពត់** | សំពត់ដែលបត់ជាពីរតាមបណ្តោយធ្មេញឈើឱ្យសម្រុងត្រួតគ្នា។ |

| | |
|---|---|
| **១៦០-នព្វសូល៍** | ប្រភេទនៃគ្រឿងរចនាម្យ៉ាង សម្រាប់លម្អស្ថាបត្យកម្ម មានសណ្ឋានផ្សេងៗ ជួនកាលជាក្បាច់កន្ទុបកន្ទុលឬវែងស្រួច ផ្ទាំងក្បាច់ ផ្ទាំងលេខ ផ្ទាំងចម្លាក់សត្វ ដែលជាផ្ចិតសមប្បមាណស្ថិតនៅចំកណ្តាលព្រំផ្ទះឬចំមណ្ឌលប្រាង្គប្រា-សាទបុរាណដែលជានិមិត្តរូបនៃផ្កាយព្រះគ្រោះទាំងប្រាំបួន គឺ ព្រះអាទិត្យ ព្រះចន្ទ ព្រះអង្គារ ព្រះពុធ ព្រះព្រហស្បតិ៍ ព្រះសុក្រ ព្រះសៅរ៍ ព្រះកេតុ និង រាហុ។<br>ទំនៀមទម្លាប់ខ្មែរ មានជំនឿថា ជីវិតមនុស្សឬសត្វ គឺសុទ្ធតែទទួលឥទ្ធិពលពីផ្កាយនព្វ-គ្រោះ ដូច្នេះ ដើម្បីមានសិរីសួស្តីនិងជាការដឹងគុណចំពោះផ្កាយទាំងប្រាំបួននេះ គេបានធ្វើវត្ថុតំណាងមួយហៅថា «នព្វសូល៍» ដាក់នៅលើព្រំដំបូលផ្ទះចំពីខាងលើនៃល្វែងចន្ទឬចំមណ្ឌលប្រាង្គ។<br><br> |

| | |
|---|---|
| **១៦១- នួន** | ឥរិយាក្នុងរបាំបុរាណដែលប្រើដងខ្លួនធ្វើចល-នាបង្អួសយឺតៗ ប្រកបដោយភាពហ្មត់ចត់ ទឹកមុខផ្ទូរផង់និងស្រស់បំព្រង។ |
| **១៦២- នែប** | ផ្នែកមួយនៃមកុដ ក្បាំង និង មួក រាងជាបន្ទះផ្សេងៗសំយុងចុះគ្របលើជើងសក់ទាំងពីរខាង ដែលរចនាដោយក្បាច់កញ្ចាំង រំយោល និង ក្បាច់ផ្សេងៗ។ |
| **១៦៣- បន្តោង-ក** | គ្រឿងអលង្ការមួយយ៉ាងធ្វើពីវត្ថុធាតុផ្សេងៗ មានសណ្ឋានច្រើនប្រភេទទៅតាមការនិយម សម្រាប់ពាក់ព្យួរបន្តោកនៅនឹងកង-ក ឬ ខ្សែ-ក។ |
| **១៦៤- បរិវត្តន៍វប្បធម៌** | ការប្រែប្រួលកស្តុតាងបុរាណវត្ថុវិទ្យាដោយសារសកម្មភាពមនុស្សនាសម័យក្រោយៗ ដូចជា ការជីកកកាយ ការជួសជុល ការប្រើប្រាស់ និង សកម្មភាពផ្សេងៗទៀត។ |
| **១៦៥- បាយអ**<br>អ. mortar<br>បារ. mortier ( m. ) | ល្បាយម្យ៉ាងមានធាតុផ្សំដូចជាស៊ីម៉ងត៍ ខ្សាច់ ទឹកជាដើម ជួនកាលគេបន្ថែមសារធាតុផ្សេងៗ សម្រាប់បង្កើនគុណភាព។<br>បាយអបុរាណ មានធាតុផ្សំដូចជា កំបោរ ខ្សាច់ ស្ករ ទឹក ជាដើម។ |

| | |
|---|---|
| **១៦៦- បាំងខ្លែង** | ក្បាច់លម្អស្ថាបត្យកម្មមួយប្រភេទមានសណ្ឋានបែបបាំងខ្លោង ច្រើនភ្ជាប់នឹងប៉ែកដំបូលអគារ ទ្វារ បង្អួច មណ្ឌប ជាដើម។<br>ឧ. បាំងខ្លែងនៅលើប៉ែកដំបូលអគារទីស្ដីការគណៈរដ្ឋមន្ត្រី។<br> |
| **១៦៧- បាំងខ្លោង** | គ្រឿងលម្អស្ថាបត្យកម្មដែលមានទម្រង់ផ្សេងៗ សម្រាប់តុបតែងលម្អ នៅលើខ្លោងទ្វារឬគោបុរៈ ប្រាសាទបុរាណ វត្តអារាម និង អគារសាធារណៈ។ នៅកម្ពុជា ជាទូទៅ បាំងខ្លោងច្រើនមានទម្រង់ដូចស្លឹករកា (បច្ចុប្បន្ន ស្ថាបត្យកររចនាឱ្យមានទម្រង់ផ្សេងៗ)។<br>ឧ. - បាំងខ្លោងនៅលើច្រកចេញចូលរបស់ទីស្ដីគណៈរដ្ឋមន្ត្រី។<br> |

| | |
|---|---|
| | - បាំងខ្លោងវត្តជីបាល ស្ថិតក្នុងភូមិជីបាល ឃុំជីបាល ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។  |
| **១៦៨- បុរាណវត្ថុវិទ្យាក្រោមទឹក / បុរាណវត្ថុវិទ្យាជលបាត** អ. underwater archaeology បារ. archéologie sous-marine (f.) | បុរាណវត្ថុវិទ្យាដែលសិក្សាអំពីតឹកតាងបុរាណវត្ថុទាំងឡាយដែលបន្សល់នៅបាតសមុទ្រ ទន្លេ បឹង ស្ទឹង ។ល។ មានដូចជា នាវា សំណង់អគារ ទីក្រុងបុរាណ កំពង់ផែបុរាណ ឬ វត្ថុផ្សេងៗដោយប្រើប្រាស់បច្ចេកវិទ្យាទំនើប ដើម្បីបកស្រាយពីទំនាក់ទំនងរវាងជីវិតនៅក្នុងទឹក និងលើគោក។ ឧ. ការសិក្សាបុរាណវត្ថុវិទ្យាជលបាតនៅប្រទេសកម្ពុជាបានចាប់ផ្ដើមឡើងបន្ទាប់ពីព្រះរាជាណាចក្រកម្ពុជាបានផ្ដល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹកនៅឆ្នាំ ២០០៧។ |

| | |
|---|---|
| **១៦៩- បុរាណវត្ថុវិទ្យាទេសភាព**<br>អ. landscape archaeology<br>បារ. paysage archéologique (m.) | បុរាណវត្ថុវិទ្យាដែលសិក្សាអំពីសំណល់សកម្មភាពនិងទំនាក់ទំនងរបស់មនុស្សជាលក្ខណៈរូបីនិងអរូបីជាមួយនឹងបរិស្ថានដែលស្ថិតជុំវិញភូមិឋានឬក្នុងទីកន្លែងណាមួយដើម្បីបកស្រាយអំពីវប្បធម៌ សាសនា សង្គមនយោបាយ សេដ្ឋកិច្ច ដែលមានក្នុងសម័យអតីតកាល។ |
| **១៧០- បុរាណវត្ថុវិទ្យានគរូបនីយកម្ម**<br>អ. urban archaeology | បុរាណវត្ថុវិទ្យាដែលសិក្សាអំពីរចនាសម្ព័ន្ធក្រុងសំណល់ឬស្នាមនៃលំនៅឋាន សំណង់អគារនៅក្នុងក្រុងផ្សេងៗ ជាទីកន្លែងដែលមនុស្សបានតាំងទីលំនៅក្នុងរយៈពេលនៃសម័យកាលណាមួយ។ |
| **១៧១- បុរាណវត្ថុវិទ្យាបុរេប្រវត្តិសាស្ត្រ**<br>អ. prehistoric archaeology<br>បារ. archéologie préhistorique (f.) | បុរាណវត្ថុវិទ្យាដែលសិក្សាអំពីសង្គមវប្បធម៌និងបរិស្ថានដែលកើតមានឡើងតាំងពីសម័យកាលមិនទាន់មានអក្សរសម្រាប់កត់ត្រា ដោយផ្អែកលើសំណល់ផ្សេងៗ ដូចជា សម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ សំណល់ផ្ទះបាយ សំណល់រុក្ខជាតិ ឆ្អឹងមនុស្ស ឆ្អឹងសត្វ ទីជម្រក ទីបញ្ចុះសព ជាដើម។<br>ឧ. ការសិក្សាបុរាណវត្ថុវិទ្យាបុរេប្រវត្តិសាស្ត្រនៅស្ថានីយល្អាងស្ពាន ធ្វើឱ្យយើងយល់ដឹងនិងបកស្រាយបានថា ខ្មែរយើងបានតាំងទីលំនៅក្នុងតំបន់នោះ តាំងពីប្រាំពីរពាន់ឆ្នាំមុនគ្រិស្តសករាជ។ |

| | |
|---|---|
| **១៧២- បុរាណវត្ថុវិទ្យាប្រព័ន្ធគំនិត**<br>អ. cognitive archaeology/structural archaeology<br>បារ. archéologie cognitive ( f. ) | បុរាណវត្ថុវិទ្យាដែលប្រើវិធីសាស្ត្របែបទ្រឹស្តីរបស់បុរាណវត្ថុវិទ្យាដែលប្រើសម្រាប់ស្រាវជ្រាវនិងបកស្រាយអំពីទំនាក់ទំនងវប្បធម៌របស់មនុស្សដោយផ្អែកលើមូលដ្ឋានក្បួនខ្នាតនៃទំនៀមទម្លាប់ ប្រពៃណីផ្សេងៗ។ |
| **១៧៣- បុរាណវត្ថុវិទ្យាប្រវត្តិសាស្ត្រ**<br>អ. historic archaeology<br>បារ. archéologie historique ( f. ) | បុរាណវត្ថុវិទ្យាដែលសិក្សាអំពីប្រវត្តិសាស្ត្រដោយផ្អែកលើភស្តុតាង បុរាណវត្ថុវិទ្យា ដូចជា សិលាចារឹក ឯកសារសំណេរ សំណង់បុរាណ សិល្បៈចម្លាក់ក្នុងសម័យកាលដែលជាតិសាសន៍មួយមានអក្សរសម្រាប់កត់ត្រា។ |
| **១៧៤- បុរាណវត្ថុវិទ្យាសង្គ្រោះ**<br>អ. salvage archaeology / rescue archaeology / preventive archaeology | បុរាណវត្ថុវិទ្យាដែលស្រាវជ្រាវនិងប្រមូលភស្តុតាងឬទិន្នន័យដើម តាមរយៈការធ្វើកំណាយសង្គ្រោះ នៅក្នុងស្ថានីយបុរាណវត្ថុវិទ្យាណាមួយដែលទទួលរងការគំរាមកំហែងពីគ្រោះធម្មជាតិ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជាលក្ខណៈឯកជន ឬ សាធារណៈដូចជា ការសាងសង់ពង្រីកទីក្រុង ការស្ថាបនាបណ្ដាញគមនាគមន៍ ការសាងសង់សំណង់អគារធំៗ ទំនប់ទឹក វារីអគ្គិសនី ព្រលានយន្តហោះ និង មូលដ្ឋានយោធា ជាដើម។ |

| | |
|---|---|
| **១៧៥- បុរាណវត្ថុវិទ្យាឧស្សាហកម្ម**<br>អ. industrial archaeology | បុរាណវត្ថុវិទ្យាដែលសិក្សាអំពីតឹកតាងនៃការវិវឌ្ឍឧស្សាហកម្មសម័យបុរាណ ដូចជា រចនា-សម្ព័ន្ធសំណង់ឧស្សាហកម្មកន្លែងស្លដែកឬរ៉ែផ្សេងៗទៀត សំណង់ស្ថានីយអយស្ម័យាន ម៉ាស៊ីនដើរដោយកម្លាំងខ្យល់នៅក្នុងសម័យកាលនៃការវិវត្តឧស្សាហកម្ម ឬ ក្រោយសម័យនោះ។ |
| **១៧៦- បូង៉ា** | ពាក្យកម្ចីពីភាសាឥណ្ឌូណេស៊ី មានន័យថា **ផ្កា**។ គេប្រទះឃើញមានប្រើពាក្យនេះនៅក្នុងទំនុកច្រៀងរបាំអប្សរានៃល្បះទី២៖ «(...) នឹងធ្វើបូង៉ា(២ដង) ច្រើនចំនួន ដាក់ខាងជិតខ្លួនទីសយនា ...»។<br>ធ្វើ «បូង៉ា» សំដៅរបៀបធ្វើផ្កាបីបែបគឺ៖<br>១- ផ្កាស្រស់ខ្ចប់ស្លឹកចេកដែលគេកេរជាកន្ទោងរាងសាជីដាក់ផ្កាសម្រាប់ស្រង់ក្លិន។ កន្ទោងនោះជួនគេទុកចំហមាត់ ជួនគេបិទមាត់ឱ្យជិតហើយកាត់ចុងត្រង់កំពូលស្រួចបន្តិច។<br>២- ផ្កាសម្រាប់ខ្ចប់ដោយស្បៃ ស្ត្រីខ្មែរជំនាន់ដើមនិយមខ្ចប់អប់ផ្កានឹងស្បៃដែលជាកំណាត់ស្តើងប៉ើងរ៉ើងៗសម្រាប់កាន់ដើរ ឬ ដាក់ក្បាលដំណេកសម្រាប់ស្រង់ក្លិន។ ផ្កាស្រស់ដែលគេចូលចិត្តខ្ចប់អប់ ច្រើនជាផ្កាម្លិះ ផ្កាកុលាប ផ្កាចម្ប៉ាក្រហម ផ្កាក្រពេន ផ្កាក្ដាំងងា...។ ចំពោះ |

| | |
|---|---|
| | ផ្កាក្ដាំងងា បើចង់អប់ឱ្យចេញក្លិនក្រអូបខ្លាំងមុតឆ្អួល គេច្រើនយកទៅពេលភ្លើងទៀនសិន។ ៣- ផ្កាសម្រាប់ដាក់ជូនសព គេយកផ្កាក្រៀមមកខ្ចប់នឹងស្បៃពណ៌ស ហើយ ក្របួចចងបូពណ៌ខ្មៅ រាងជាដុំមូល។ |
| **១៧៧- បាំងស្លាប** | បន្ទះមានរាងដូចព្រុយត្រីសម្រាប់ចាប់ភ្ជាប់នៅចំហៀងមកុដអប្សរាទាំងពីរខាង។ |
| **១៧៨- ប្រចាំយាម** | គ្រឿងអលង្ការមួយយ៉ាងធ្វើពីបន្ទះលោហៈមានសណ្ឋានដូចក្បាច់ចក្កចន (ចតុកោណស្មើ) មានទំហំតូចជាងស្លឹកពោធិ៍ ដោយមានរចនាជាក្បាច់ផ្សេងៗសម្រាប់ដាក់ភ្ជាប់លើសង្វារព័ន្ធ ត្រង់កន្លែងខ្នែងនៅផ្នែកខាងក្រោយ។ |
| **១៧៩- ប្រដាប់ជើង** | គ្រឿងអលង្ការមួយប្រភេទធ្វើពីលោហៈសម្រាប់ពាក់លម្អនៅលើ កជើងឆ្វេង-ស្ដាំនៃអ្នករបាំបុរាណខ្មែរ។ ប្រដាប់ជើងមាន កងទងឈូក និង កងញ័រជើង។ |
| **១៨០- ប្រដាប់ដៃ** | គ្រឿងអលង្ការសម្រាប់ពាក់នៅលើ កដៃឆ្វេង-ស្ដាំរបស់អ្នករបាំបុរាណខ្មែរ ដូចជា ស្លឹកទេសចិញ្ចៀនក្រង កងញ័រដៃ កន្ត្រុំ កងរាក់ កងកន់នៃឈុតសម្លៀកបំពាក់គ្រឿងធំ។ |
| **១៨១- ប្រពាយ** | គ្រឿងអលង្ការធ្វើពីមាសឬលោហៈផ្សេងៗ ជាផ្នែកមួយនៃមកុដបញ្ចរត្ន ភ្ជាប់ពីនៃបឆ្វេងទៅនៃបស្ដាំនៅផ្នែកខាងក្រោយ មានសណ្ឋានដូចផ្លែប្រពាយស្បែក។ |

| | |
|---|---|
| **១៨២- ផាឱប** | ពាក្យកម្ចីពីភាសាសៀម មានន័យថា សំពត់អំបោះឆៅ។ ប្រភេទសំពត់ដែលគេត្បាញពីអំបោះឆៅ ឥតឱ្យបាយជូរ។ |
| **១៨៣- ផាហ៊ុម** | ប្រភេទកំណាត់លម្អមួយផ្ទាំងដែលមានភ្លីច្រើន និងពណ៌ផ្សេងៗ ប្រើក្នុងរបាំបុរាណ សម្រាប់តួនាងវ័យជំទង់ពាក់រុំលើដងខ្លួន ដោយវាត់មកលើស្មាឆ្វេង ទម្លាក់ចុងជាយម្ខាងមកក្រោយត្រឹមត្រគាក។ |
| **១៨៤- ផ្កាខ្លឹមចន្ទន៍** | បន្ទះអាចម៍ឈើរម្ងរបានមកពីការឈូសឈើខ្លឹមចន្ទន៍ឬឈើផ្សេងៗដែលគេកាត់បិទរចនាជាផ្កា៤ឬ៥នៅលើគ្រោងឆ្អឹងឫស្សីមានរាងជាពពិល ប្រើជាគ្រឿងតង្វាយសម្រាប់ដាក់ជា-មួយដុំបូង៉ា ជូនសពមុនពេលបូជា។ |
| **១៨៥- ផ្កាញ័រ** | គ្រឿងអលង្ការជារូបផ្កាធ្វើពីមាស ឬ លោហៈផ្សេងៗ មានទងធ្វើដោយលួសរួញម្ងរជាជាន់ៗ ដើម្បីឱ្យកក្រើកញ័រសម្រាប់បំពាក់ភ្ជាប់នៅតាមជាន់នីមួយៗនៃមកុដ។ |
| **១៨៦- ផ្កាប្រាក់** | គ្រឿងលម្អមួយបែបធ្វើពីប្រាក់ឬស្ពាន់ជ្រលក់ទឹកប្រាក់ មានរាងជាផ្កាមួយកញ្ចុំ មានទងមួយសម្រាប់កាន់រាំក្នុងរបាំផ្កាមាសផ្កាប្រាក់។ បច្ចុប្បន្ន គេនិយមធ្វើពីក្រដាសពណ៌ប្រាក់។ |

| | |
|---|---|
| **១៨៧- ផ្កាមាស** | គ្រឿងលម្អមួយបែបធ្វើពីមាសឬស្ពាន់ជ្រលក់ទឹកមាស មានរាងជាផ្កាមួយកញ្ចុំ មានទងមួយសម្រាប់កាន់រាំក្នុងរបាំផ្កាមាសផ្កាប្រាក់ និង របាំអប្សរា ជាពិសេស រាំលើឆាកអច្ឆរិយៈ។<br>បច្ចុប្បន្ន គេនិយមធ្វើផ្កានេះពីក្រដាសពណ៌មាស។ |
| **១៨៨- ផ្កាសៀត** | ផ្កាចងមួយកញ្ចុំឬផ្កាធំមួយ សម្រាប់តួនាយរោងសៀតលើត្រចៀកស្តាំ ចំណែកឯតួនាងសៀតខាងឆ្វេង។ |
| **១៨៩- ផ្តេកមក្លឿ** | បច្ចេកទេសជ្រលក់ពណ៌សំពត់ឱ្យខ្មៅជាមួយនឹងទឹកផ្លែមក្លឿ រួចហាលលើដីស្ងួត (ជ្រលក់និងហាលច្រើនដងរហូតឡើងពណ៌ខ្មៅតាមការចង់បាន)។ |
| **១៩០- ពណ៌**<br>អ. color/colour<br>បារ. couleur (f.) | លក្ខណៈសម្គាល់វត្ថុឬធាតុភូតដែលកំណត់ដោយចក្ខុវិញ្ញាណតាមរយៈពន្លឺ ជាប្រភេទផ្សេងៗ ដូចជា ក្រហម លឿង ខៀវ ជាដើម។<br>ឧ. ព្រះអាទិត្យបញ្ចេញពន្លឺចម្រុះពណ៌។ |
| **១៩១- ព្រៃឡាញ់** | ឡាញ់ ជាភាសាវៀតណាម មានន័យថា ត្រជាក់។ ប្រភេទសំពត់ត្បាញពីអំបោះ មានសាច់ម៉ដ្ឋរលើបរលោង មានគ្រប់ពណ៌ នាំចូលពីប្រទេសវៀតណាម ដែលប្រើសម្រាប់កាត់សម្លៀកបំពាក់ |

| | |
|---|---|
| | មួយចំនួនក្នុងរបាំខ្មែរ។<br>ស្ត្រីវ័យក្មេងនិយមប្រើព្រែឡាញ់នេះនៅផ្ទះ ព្រោះវាត្រជាក់ ចំណែកស្ត្រីវ័យចំណាស់និយម កាត់ជាសំពត់សម្លុយ ស្លៀកក្នុងជីវភាពសាមញ្ញ ឯបុរសវ័យចំណាស់ និយមកាត់ខោស្លៀក សម្រាប់ចូលរួមក្នុងពិធីបុណ្យទានផ្សេងៗ។ ដោយឡែក ព្រែឡាញ់ពណ៌ខ្មៅ មានសាច់ ក្រាស់ តែ មិនសូវមានគុណភាពទេ។ |
| **១៩២- ព្រំ** | គ្រឿងបង្គុំនៃដំបូលអគារសម្រាប់ប្រក់ភ្ជិត ដំបូលសំណង់ត្រង់ប្រទល់ក្បាលកណ្ដប ក្បឿង ស័ង្កសី ដោយប្រើសម្ភារៈផ្សេងៗ ដូចជា ក្បឿង បាយអ ស្លឹកកណ្ដប ស័ង្កសី ជាដើម។<br>ឧ. ព្រំដំបូលផ្ទះ ព្រំដំបូលអគារ។ |
| **១៩៣- មកុដ** | គ្រឿងអលង្ការមួយយ៉ាងធ្វើពីមាសឬលោហៈ ផ្សេងៗឬធ្វើពីក្រដាសស្នាច់ ហើយ បន្ទំក្បាច់ ឌុកឬធ្វើពីកំណាត់ បិទពណ៌មាស ដាំត្បូង ដែលមានកំពូលនិងរចនាតាមក្បាច់ផ្សេងៗ ដ៏ល្អវិចិត្រ សម្រាប់ពាក់នៅលើក្បាល។ |
| **១៩៤- មកុដតួនាង** | គ្រឿងអលង្ការធ្វើអំពីមាសឬលោហៈផ្សេងៗ មានកំពូលមួយ មានក្បាំង និង រចនាកំពូលរួត ស្រួចៗចំនួន៧ជាន់ បំពាក់ដោយផ្កាញីរគ្រប់ |

| | |
|---|---|
| | ដាន់ភ្ជាប់ដោយនៃបជិតថ្កាល់ និង ប្រើចនដាឃ្នាបសម្រាប់គាបឱ្យជាប់។ មកុដនេះសម្រាប់ពាក់ចំពោះតែតួទេពធីតា ឬ សម្រាប់ព្រះមហាក្សត្រិយានីប្រើនៅពេលអភិសេកឡើងគ្រងរាជ្យ ដោយរចនាជាក្បាច់ខុសៗគ្នាទៅតាមអង្គព្រះមហាក្សត្រិយានី និង តាមមុខងារផ្សេងៗដែលត្រូវប្រើ។ |
| **១៩៥- មកុដនាងនាគ** | គ្រឿងអលង្ការធ្វើពីមាសឬលោហៈ ឆ្លាក់ជាមកុដ រាងក្បាលនាគបីបើកពពារ មានភ្ជាប់ចនដោយប្រើក្បាច់អង្គរ។ ចំណែកពីក្រោយកំពូលនាគ ផ្នែកកណ្ដាល លម្អដោយកន្ទុយនាគ១គូព័ន្ធគ្នា និង កន្ទុយ២អមម្ខាង១។ មកុដនេះយកតាមលំនាំមកុដនាងទេពអប្សរនៅប្រាសាទព្រះលានស្ដេចគម្លង់បង្កើតនៅឆ្នាំ២០១០។ |
| **១៩៦- មកុដនាយរោង** | គ្រឿងអលង្ការធ្វើអំពីមាសឬលោហៈផ្សេងៗ មានកំពូលមួយ គ្មានក្បាំង និង រចនាកំពូលរួតស្រួចៗចំនួន៩ជាន់ បំពាក់ផ្កាញ័រគ្រប់ជាន់ភ្ជាប់ដោយនៃបជិតថ្កាល់ និង ប្រើចនជាឃ្នាបសម្រាប់គាបឱ្យជាប់។ មកុដនេះសម្រាប់បំពាក់ឱ្យតួទេពប្រុសឬសម្រាប់ព្រះមហាក្សត្រប្រើនៅពេលអភិសេកឡើងគ្រងរាជ្យ ដោយរចនាជាក្បាច់ខុសៗគ្នាទៅតាមអង្គព្រះមហាក្សត្រនិងតាមមុខងារផ្សេងៗដែលត្រូវប្រើ។ |

| | |
|---|---|
| **១៩៧- មកុដបញ្ញវត្ថ** | គ្រឿងអលង្ការធ្វើពីមាសឬលោហៈផ្សេងៗ រចនាជាក្បាច់កញ្ចាំងឬភ្ញីទេស មានឬគ្មានបន្ទំត្បូងប្រាំបែប (មរកត ប្រពាល ពេជ្រ កណ្តៀង មុក្តារ) មានរាងជាក្បាំងភ្ជាប់នឹងនែប លម្អដោយប្រពាយភ្ជាប់ពីនែបឆ្វេងទៅនែបស្តាំនៅផ្នែកខាងក្រោយ និង មានផ្កាញ៉រនៅជាប់ជុំវិញផ្នែកខាងលើនៃមកុដ។ មកុដបញ្ញវត្ថសម្រាប់បំពាក់ឱ្យតួនាយរោងពេលនៅជាព្រះអង្គម្ចាស់មិនទាន់ឡើងគ្រងរាជ្យ។<br>ឧ. តួព្រះថោងគ្រងមកុដបញ្ញវត្ថ នៅពេលកំពុងច្បាំងជាមួយព្រះនាងនាគ។ |
| **១៩៨- មកុដប្រើស** | គ្រឿងអលង្ការធ្វើអំពីមាសឬលោហៈផ្សេងៗ មានកំពូលរូបក្បាលប្រើសមួយធ្វើពីខ្មុក គ្មានក្បាំង និង រចនាកំពូលរួតស្រួចៗចំនួន៦ជាន់ បំពាក់ដោយផ្កាញ៉រគ្រប់ជាន់ ភ្ជាប់ដោយនែបជិតថ្ពាល់ និង ប្រើចនជាឃ្នាបសម្រាប់គាបឱ្យជាប់។ មកុដនេះសម្រាប់តួប្រើស។ |
| **១៩៩- មកុដវត្ថខ្លោង** | គ្រឿងអលង្ការធ្វើពីមាសឬវត្ថុធាតុផ្សេងៗ មានរាងជម ហ៊ុមពទ្ធដោយក្បាច់កញ្ចាំងរាក់រយ និង ក្បាច់ផ្កាច័នដាំត្បូងនៅលើជ្រុងទាំង៤ និង មានចន១គូ ផ្នែកខាងលើរចនាក្បាច់កន្ទុយហង្សមួយគូនិងមានបន្ទំត្បូង ព្រមទាំងមានក្បាច់ |

| | |
|---|---|
| | ធ្មេញរណោទម្លុះហ៊ុមពទ្ធជុំវិញតួមកុដ សម្រាប់តួនាងពាក់ដែលតំណាងឱ្យវ័យជំទង់។ |
| **២០០- មកុដរាពណ៍/ មកុដទសមុខ** | គ្រឿងអលង្ការធ្វើពីខ្មុកមានមុខ១០ ដែលផ្នែកខាងក្រោមជាន់ទី១មានមុខមួយធំនៅចំពីមុខ និងមុខបួនតូចៗនៅពីក្រោយ នៅជាន់ទី២ មានមុខបួនតូចៗ (នៅពីមុខ ក្រោយ ឆ្វេង ស្តាំ) និង ជាន់ទី៣ មានមុខតូចមួយបែរមក ខាងមុខ និង មានកំពូលស្រួចតូចមួយ។ |
| **២០១- មកុដរាមបរមាសូរ/មកុដរាមាសូរ** | គ្រឿងអលង្ការមានទម្រង់ជាមុខពាក់ មានកំពូលក្បាច់កន្ទុយហង្សមួយ មានវណ្ណក្បាច់កញ្ចាំងរាក់រយ កំពូលរួតស្រួចៗនៅលើក្បាល និង មានចនភ្ជាប់នឹងជើងសក់ឆ្វេងស្តាំ ដែលធ្វើពីខ្មុកលាបពណ៌ទឹកមាស។ |
| **២០២- មកុដហនុមាន** | គ្រឿងអលង្ការធ្វើពីខ្មុក រចនាតួរាងជាក្បាលស្វាហាមាត់ ដោយក្បាច់កញ្ចាំងពទ្ធជុំវិញក្បាល និងមានចនរាងកន្ទុយហង្ស។ |
| **២០៣- មកុដអប្សរា** | គ្រឿងអលង្ការធ្វើពីមាសឬលោហៈផ្សេងៗ មានក្បាំងមួយលម្អដោយក្បាច់អង្គរ មានចនពីរបាំងស្លាបពីរនិងកំពូលបី ដែលកំពូលនីមួយៗមានផ្កាបិណ្ឌនិងក្បាច់រាងមូលសំប៉ែតចំនួនពីរបញ្ឈរលើគ្នា(សម្រាប់តួឯក) ឬ ក្បាច់រាងមូល |

| | |
|---|---|
| | សំប៉ែតចំនួនមួយ (សម្រាប់តួរង) ដែលលម្អដោយក្បាច់ផ្សេងៗ ដូចជា ចកកញ្ចុំ ត្របកឈូកបំបែក ពងត្រី ជាដើម។ |
| **២០៤- យឿង** | ឥរិយាក្នុងរបាំបុរាណដែលប្រើ ក ធ្វើចលនាផ្អៀងផ្អង បង្អួសយឺតៗទន់ភ្លន់ រស់រវើក ស្អិតជាប់គ្នា និង ឱ្យហាប់ណែន។ |
| **២០៥- របាំ**<br>អ. dance<br>បារ. danse (f.) | សិល្បៈនៃការបញ្ចេញកាយវិការពត់ពេនខ្លួនប្រាណ វាសដៃ វាសជើង ហក់លោតចាក់ក្បាច់ ឬ/និង ញាក់មុខញាក់មាត់ តាមបែបបទនិយមផ្សេងៗដែលធ្វើឡើងទៅតាមចង្វាក់ភ្លេង និងចម្រៀងដោយបង្កប់នូវមនោសញ្ចេតនា អត្ថ-និង មុខងាររៀងៗខ្លួន។ |
| **២០៦- រមួត/ល្មួត** | ឥរិយាបថក្នុងរបាំបុរាណដែលប្រើដងខ្លួនធ្វើចលនាផ្អៀងផ្អងបង្អួសយឺតៗ ទន់ភ្លន់ រស់រវើកស្អិតជាប់គ្នា និង ហាប់ណែន។ |
| **២០៧- រយ៉ា** | គ្រឿងលម្អមួយបែបពាក់នឹងទងត្រចៀក ធ្វើពីវត្ថុធាតុផ្សេងៗ សណ្ឋានស្រដៀងនឹងរំយោលផ្កា។ រយ៉ាមានទងវែងទម្លាក់ជារំយោល (តាមទម្លាប់អ្នកស្រុកខ្លះហៅថា ផ្ការយ៉ា ឬ ផ្ការំ-យោល)។ រយ៉ា មានដូចជា រយ៉ាដក់, រយ៉ាផ្កាម្ទេស, រយ៉ាផ្កាក្រសាំង ជាដើម។ |

| | |
|---|---|
| **២០៨- រយ៉ាដក់** | គ្រឿងលម្អមួយបែបពាក់នឹងទងត្រចៀកធ្វើពីវត្ថុធាតុផ្សេងៗ សណ្ឋានស្រដៀងនឹងរំយោលផ្កា។ រយ៉ាដក់មានទងវែងទម្លាក់ជារំយោលភ្ជាប់នឹងត្បូងមួយគ្រាប់ឬធ្វើពីលោហៈ រាងមូលយោលតិកតុកៗ។ |
| **២០៩- រយ៉ាផ្កាក្រសាំង** | គ្រឿងលម្អមួយបែបពាក់នឹងទងត្រចៀក ធ្វើពីវត្ថុធាតុផ្សេងៗ សណ្ឋានស្រដៀងនឹងផ្កាក្រ-សាំងមួយឬមួយកញ្ចុំ មានទងវែងទម្លាក់ជារំយោលភ្ជាប់ខាងចុង។ |
| **២១០- រយ៉ាផ្កាម្ទេស** | គ្រឿងលម្អមួយបែបពាក់នឹងទងត្រចៀក ធ្វើពីវត្ថុធាតុផ្សេងៗ សណ្ឋានស្រដៀងនឹងផ្កាម្ទេស មានទងវែងទម្លាក់ជារំយោលភ្ជាប់ខាងចុង។ |
| **២១១- រាក់រយ** | ក្បាច់រចនាដែលមានទម្រង់ច្រើនប្រភេទដូចជាទម្រង់ត្របកឈូក កញ្ចាំង ផ្កាចាន់ កេសរធ្មេញក្របី ពងត្រី ... ធ្លាក់រាក់ រាងដដែលៗបន្តបន្ទាប់គ្នា ។ |
| **២១២- របៃចង្កេះ** | បន្ទះកំណាត់ប៉ាក់ឱនមួយប្រភេទ សម្រាប់តួនាយរោង តួយក្ស និង តួស្វាក្បាច់ ក្រវាត់ជុំវិញចង្កេះ ដោយដេររឹបនៅផ្នែកខាងមុខ។ |

| | |
|---|---|
| ២១៣- ឫកធើតឆាយ | កិរិយាបថនៃតួសម្ដែងដែលបង្ហាញពីភាពសប្បាយ ធើតឆាយ ធ្មើងធ្មៃ ក្រអឺតក្រអោង ។ល។ ឫកនេះ ច្រើនប្រើនៅក្នុងរឿងបរទេស។ ឧ. ឫកធើតឆាយនៃតួនាង(តួស្រី)សម្ដែងក្នុងនាមជាស្រីមិនគ្រប់លក្ខណ៍។ ឫកធើតឆាយនៃតួនាយរោង(តួប្រុស)សម្ដែងក្នុងនាមជាបុរសហ៊ឹហា អួតក្អេងក្អាង។ |
| ២១៤- ឫកនាងក្រសត្រ | កិរិយាបថនៃតួនាង(តួស្រី)ដែលមានអំណោយទានពីធម្មជាតិ អាចសម្ដែងក្នុងនាមជាអ្នកមានឋានៈខ្ពង់ខ្ពស់ បង្ហាញនូវកាយវិការឆាប់រហ័សរហួនតែទន់ភ្លន់។ ឫករបស់តួនាងក្រសត្រច្រើនដកស្រង់ពីក្បាច់បញ្ចុះ។ ឧ. ឫករបស់តួម្ចាស់ក្សត្រីរាំរបាំទេពមនោរម្យក្នុងពេលជួបជាមួយម្ចាស់ក្សត្រាបង្ហាញនូវឫកនាងក្រសត្រ ដោយបង្កប់មនោសញ្ចេតនាទន់-ភ្លន់។ |
| ២១៥- ឫកនាងង | កិរិយាបថនៃតួនាង (តួស្រី) ដែលមានអំ-ណោយទានពីធម្មជាតិ អាចសម្ដែងក្នុងនាមជាអ្នកមានឋានៈខ្ពង់ខ្ពស់ បង្ហាញនូវភាពម៉ឺង-ម៉ាត់ ហ្មត់ចត់ ដោយប្រើក្បាច់សង្កត់ឱ្យហាប់ណែន ល្អូត ទន់ ភ្លន់ ហើយ អណ្ដែត។ ឫក-នាងង ច្រើនដកស្រង់ពីក្បាច់ឆា។ ឧ. ឫកនាងងរបស់នាងមេខលារាំទប់ទល់នឹងក្រុងយក្សរាមបរមាសូរ។ |

| | |
|---|---|
| **២១៦- ឫករបាំ** | តិរិយាបថនៃតួសម្ដែងដែលបង្ហាញពីទឹកមុខញញឹមក្នុងន័យមនោសញ្ចេតនានិងស្វាគមន៍។ ឫករបាំនេះ មានក្នុងរបាំជូនពរ របាំកន្សែង របាំផ្លិត។<br>ឧ. តួនាង (តួស្រី) និង តួនាយរោង (តួប្រុស) សម្ដែងក្នុងនាមជាម្ចាស់ផ្ទះឬម្ចាស់ស្រុក។ |
| **២១៧- ល្ខោនបាសាក់** | ទម្រង់សិល្បៈទស្សនីយភាពរបាំធំមួយដែលយកឈ្មោះតាមស្រុកមួយ គឺស្រុកបាសាក់ ក្នុងខេត្តឃ្លាំង ទល់មុខនឹងខេត្តព្រះត្រពាំងនៃទឹកដីកម្ពុជាក្រោម។ ល្ខោនបាសាក់មានលក្ខណៈពិសេស ដូចជា៖<br>- កាយវិការមានភាពរហ័សរហួន,<br>- ពិធីហោមរោងប្រើបទភ្លេងហោមរោង,<br>- របៀបបង្ហាញតួដោយតួសម្ដែងពោលប្រាប់ឈ្មោះខ្លួនឯង,<br>- សម្លៀកបំពាក់មានលក្ខណៈភ្លឺផ្លេក,<br>- មុខតួមានលាបម្សៅច្រើន,<br>- ការកាត់កងឆាកប្រើកញ្ចែផ្លុំផ្ដាច់ឬវាយស្គររន្លីនផ្ដាច់,<br>- ការតុបតែងឆាកប្រើផ្ទាំងគំនូរ,<br>- តួត្លុកសម្ដែងជាមួយតួឯក,<br>- ឧបករណ៍តន្ត្រីប្រើស្គរឡុក ទ្រ ឃឹម ឆាប ឡោ ប៉ាន់..., |

| | |
|---|---|
| | - បទភ្លេងនិងចម្រៀងប្រើបទមហោរី បាសាក់ បទបារាំង ...,<br>- ដំណើររឿងច្រើនទាក់ទងនឹងស្តេច យក្ស ឥសី...,<br>- ការសម្តែងប្រើក្បាច់ហួនជាគោល,<br>- តួយក្សក្មេងដែលទើបនឹងចេញពីរៀនសិល្ប៍-សាស្ត្រ តុបតែងមុខដោយមិនមានចង្កូម និងមានចរិតស្លូត,<br>- តួយក្សចំណាស់ដែលទើបនឹងចេញពីរៀនសិល្ប៍សាស្ត្រ តុបតែងមុខ ដោយមានចង្កូម មានចរិតកាច និង ប្រើក្បាច់ហួនខ្លាំង,<br>- យក្សកាន់សីលមានចរិតស្លូត ទោះបីមានការតុបតែងមុខដោយមានចង្កូមក៏ដោយ។<br>**ប្រវត្តិល្ខោនបាសាក់**៖<br>កាលពីដំបូង អ្នកស្រុកនាំគ្នាហៅល្ខោននេះថា«ល្ខោនទ្រើងឃ្លោក»ដោយហេតុថាសិល្បករសម្តែងផ្ទាល់លើដី ក្នុងរោងដែលសង់ឡើងដោយយកមែកឈើប្រក់គ្រប មានទម្រង់ប្រ-ហែលនឹងទ្រើងឃ្លោក។ ទន្ទឹមនេះ ក៏មានខ្មែរក្រោមខ្លះហៅល្ខោននេះថា «ល្ខោនយូរកេរ» ព្រោះវាជាកេរមរតករបស់ខ្មែរដែលកើតឡើងតាំងពីយូរលង់មកហើយ។ ល្ខោនបាសាក់បានពង្រឹងពង្រីកប្រជាប្រិយភាពរបស់ខ្លួនយ៉ាង |

| | |
|---|---|
| | ធាប់រហ័ស ព្រោះអ្នកដឹកនាំនិងអ្នកសម្តែងជាអ្នកប្អូសរៀន ពូកែខាងអក្សរសិល្ប៍ ពូកែប្រើពាក្យសម្តី លើកជាកំណាព្យ លើកជាកម្រងកែវ និងលើកទំនុកច្រៀងដោយឥតព្រាងទុក។<br>ក្រោយមក ល្ខោននេះបានក្លាយជាកម្មវត្ថុនៃការប្រកួតប្រជែងជាមួយល្ខោន «កៃលឿង» របស់វៀតណាម និង ល្ខោន «ហ៊ី» របស់ចិន។ ដូច្នេះ អ្នកដឹកនាំល្ខោនបាសាក់ក៏បានចម្លងយកចំណុចល្អៗពីល្ខោនកៃលឿងនិងល្ខោនហ៊ីមកសំយោគបញ្ចូលគ្នា ហើយ សម្របខ្លួនទៅតាមកាលៈទេសៈ ដូចជា កន្លែងណាមានខ្មែរមើលច្រើន សិល្បករនិយាយនិងច្រៀងភាសាខ្មែរ ឯកន្លែងណាមានវៀតណាមមើលច្រើន សិល្បករខ្មែរប្រើភាសាខ្មែរផង និង ភាសាវៀត-ណាមផង ហើយ កន្លែងណាដែលមានចិនមើលច្រើន សិល្បករខ្មែរប្រើភាសាខ្មែរផង និង ភាសាចិនថែមទៀត។ នៅអំឡុងឆ្នាំ១៩៣០ ល្ខោនបាសាក់នៅកម្ពុជាក្រោម មានការពេញនិយមយ៉ាងខ្លាំង ដូច្នេះ លោក លី សួន ហៅ ធាគ្រួន ដែលជាអ្នកដឹកនាំបាននាំក្រុមសិល្បៈរបស់លោកមកសម្តែងនៅកម្ពុជាភាគកណ្តាល គឺនៅភ្នំពេញនិងនៅតាមខេត្តនានា ប៉ុន្តែ មិនសូវទទួលបានជោគជ័យ ព្រោះខ្មែរកណ្តាលកំពុង |

| | |
|---|---|
| | នៅពេញនិយមល្ខោនមហោរី និង ល្ខោនប្រាមោ-ទ័យដែលមានការរីកចម្រើនជាយូរមកហើយ។ បន្ទាប់ពីបរាជ័យ លោក លី សួន ហៅ ឆាគ្រួន បានរិះរកបញ្ចូលបច្ចេកទេសហោះហើរដ៏ប៉ិនប្រសប់ និង បញ្ចូលក្បាច់ «ហួន» ដែលមានភាពឆាប់រហ័ស ស្វាហាប់ក្នុងការសម្តែង រួចហើយលោកក៏បាននាំក្រុមសិល្បៈរបស់លោកមកកម្ពុជាកណ្តាលជាថ្មីម្តងទៀត ដោយធ្វើដំ-ណើរតាមទូកប៉ុកចាយ មានគ្រឿងសម្ភារៈតុប-តែងឆាកទំនើបៗ និង មានគ្រឿងដំឡើងឆាកលើដីក៏បាន លើទូកក៏បាន។ កត្តានេះបានធ្វើឱ្យទស្សនិកជនជក់ចិត្តជិតអារម្មណ៍យ៉ាងខ្លាំង រហូតធ្វើឱ្យខ្មែរកណ្តាលហៅល្ខោននេះថា «ល្ខោនបាសាក់»។ ចាប់ពីពេលនោះមក ឈ្មោះ «ល្ខោនទ្រើងឃ្លោក» ឬ «ល្ខោនយូរកេរ» ត្រូវបានជំនួសដោយឈ្មោះ «ល្ខោនបាសាក់» វិញ ។ |
| **២១៨- ល្បាក់ផ្កា សំយុង** | កម្រងផ្កាដែលចងជារំយោលភ្ជាប់នឹងមកុដសម្រាប់តួនាយរោងពាក់សំយុងនៅខាងស្តាំ និង តួនាងពាក់សំយុងនៅខាងឆ្វេង។ |
| **២១៩- វិធីប្រវត្តិវប្បធម៌** អ. culture-historical approch | របៀបសិក្សាស្រាវជ្រាវបុរាណវត្ថុវិទ្យាដោយប្រើវិធីអនុមានរួមក្នុងការបកស្រាយអំពីគំរូវប្ប-ធម៌និងសង្គមមនុស្សនៅក្នុងអតីតកាល ដោយ |

| | |
|---|---|
| បារ. approche culturo-historique (f.) | ផ្អែកលើភស្តុតាងបុរាណវត្ថុវិទ្យាដែលបានរកឃើញ ឬ ដោយផ្អែកលើការបកស្រាយរបស់អ្នកស្រាវជ្រាវមុនៗ។<br>របៀបសិក្សាស្រាវជ្រាវបុរាណវត្ថុវិទ្យាដោយប្រើវិធីអនុមានរួមក្នុងការបកស្រាយអំពីគំរូវប្បធម៌និងសង្គមមនុស្សនៅក្នុងអតីតកាល ដោយផ្អែកតាមភស្តុតាងបុរាណវត្ថុវិទ្យាបានរកឃើញ ឬដោយផ្អែកតាមការបកស្រាយរបស់អ្នកស្រាវជ្រាវមុនៗ។ |
| **២២០- សង្វារព័ន្ធ** | គ្រឿងអលង្ការមួយយ៉ាងធ្វើពីលោហៈឬវត្ថុធាតុផ្សេងៗ មានសណ្ឋានជាខ្សែឬខ្សែបន្ទះសម្រាប់ពាក់ខ្វែងលើដងខ្លួនអ្នករបាំបុរាណ និងអ្នកមានឋានន្តរសក្តិក្នុងរាជការនៅសម័យបុរាណ។ |
| **២២១- សន្លុង** | ឡបុរាណធ្វើពីដីឥដ្ឋសម្រាប់ចម្រាញ់យកដែក។ គេនិយមប្រើពាក្យនេះ នៅក្នុងតំបន់ភាគខាងជើងប្រទេសកម្ពុជា ក្នុងខេត្តកំពង់ធំ ព្រះវិហារ សៀមរាប ឧត្តរមានជ័យ និង តំបន់មួយចំនួនទៀត នៅភាគខាងលិចទន្លេមេគង្គ ក្នុងខេត្តស្ទឹងត្រែង។<br>ឧ. ក្រុមអ្នកស្រាវជ្រាវរាជបណ្ឌិត្យសភាកម្ពុជាបានស្រាវជ្រាវឃើញសន្លុងធំៗនៅក្នុងស្រុករវៀង ជ័យសែន ឆែប សង្គមថ្មី ក្នុងខេត្តព្រះវិហារ និង ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ។ |

| | |
|---|---|
| ២២២- សារុងសូត្រ | ប្រភេទសំពត់ត្បាញពីសរសៃសូត្រ មានឋានលម្អដោយក្រឡាចត្រង្គ រំលេចពណ៌ផ្សេងៗ។ បុរសខ្មែរនិយមស្លៀកសំពត់ប្រភេទនេះនៅផ្ទះ ព្រោះត្រជាក់ និង មានលក្ខណៈថ្លៃថ្នូរ ចំណែកស្ត្រីខ្លះក៏និយមស្លៀកនៅផ្ទះដែរ។ |
| ២២៣- សូរង-ក | គ្រឿងអលង្ការមួយយ៉ាងមានសណ្ឋានជាបន្ទះលម្អដោយក្បាច់រចនាផ្សេងៗ សម្រាប់ពាក់ជុំវិញកអ្នកសម្តែងរបាំបុរាណ ល្ខោនខោល ល្ខោនយីកេ ល្ខោនបាសាក់...។ កាលពីសម័យបុរាណ សូរង-ក ធ្វើពីមាសឬលោហៈមានតម្លៃ ដោយមិនដេរភ្ជាប់ជាមួយកំណាត់ជាទ្រនាប់ដូចសម័យបច្ចុប្បន្ន។ |
| ២២៤- សំពត់ក្បិន | ប្រភេទសំពត់ដែលមានថង់ធំខុសពីសំពត់ធម្មតា មានប្រវែង ៣២០សង់ទីម៉ែត្រ, ៣៤០ សង់ទីម៉ែត្រ និង ៤០០សង់ទីម៉ែត្រ ដែលបត់ជាពីរតាមបណ្តោយធ្មេញឈើឱ្យសម្រុងត្រួតគ្នា ដោយមិនដេរភ្ជាប់មុខ សម្រាប់ស្លៀកមូរជាយសំពត់ទាំងពីរខាងមកចុកនៅធ្នុកក្បិន។ |
| ២២៥- សំពត់ក្បិនខើច | ប្រភេទសំពត់សម្រាប់ស្លៀកចងក្បិនដោយចាប់ជាយទាំងពីរដាក់ខាងលើផ្ចិតក្របួចចងឱ្យជាប់ រួចមូរចុងជាយទាំងពីរវាត់កន្ទុយក្បិនទៅក្រោយ ទាញឱ្យខើចដល់ពាក់កណ្តាលភ្លៅ និង ចុកនៅធ្នុកក្បិន។ នៅក្នុងរបាំបុរាណ សំពត់ក្បិនខើច ប្រើសម្រាប់ស្លៀកឱ្យតួនាយរោង តួគ្រុឌ តួយក្ស និង តួស្វាក្បាច់ ជាដើម។ |

| | |
|---|---|
| **២២៦- សំពត់ក្បិនខោ** | ប្រភេទសំពត់សម្រាប់ស្លៀកចងក្បិនដោយចាប់ជាយទាំងពីរដាក់ខាងលើផ្ចិត ក្របួចចងឱ្យជាប់ រួចមូរចុងជាយទាំងពីរ វាត់កន្ទុយក្បិនទៅក្រោយ ទម្លាក់ចុងជាយក្បិនចុះក្រោមក្បាលជង្គង់បន្តិច និង ចុកនៅផ្នុកក្បិន។ គេស្លៀកសំពត់នេះនៅក្នុងពិធីតាមប្រពៃណី និង បុណ្យជាតិ។ |
| **២២៧- សំពត់ក្បិនខ្លី** | ប្រភេទសំពត់សម្រាប់ស្លៀកចងក្បិនដោយចាប់ជាយទាំងពីរដាក់ខាងលើផ្ចិតក្របួចចងឱ្យជាប់ រួចមូរចុងជាយទាំងពីរវាត់កន្ទុយក្បិនទៅក្រោយ ទាញឱ្យខើចដល់គល់ភ្លៅ និង ចុកនៅផ្នុកក្បិន។ ពលទ័ពបុរាណ កីឡាករល្បុក្កតោ កីឡាករចំបាប់(ចម្លាក់នៅប្រាសាទបាយ័ន) អ្នកឡើងត្នោត និង អ្នកបាចត្រីជាដើម និយមស្លៀកសំពត់ក្បិនខ្លី។ |
| **២២៨- សំពត់ក្បិនគយារ** | ប្រភេទសំពត់សម្រាប់ស្លៀកចងក្បិនដោយចាប់ជាយទាំងពីរដាក់ខាងលើផ្ចិត ក្របួចចងឱ្យជាប់ រួចមូរចុងជាយទាំងពីរវាត់កន្ទុយក្បិនទៅក្រោយ ទម្លាក់ចុងជាយក្បិនចុះក្រោមឱ្យស្លុយជិតដល់កជើង និង ចុកនៅផ្នុកក្បិន។ ចាស់ៗនៅជនបទស្រុកស្រែចម្ការនិយមស្លៀករបៀបនេះ។ |

| | |
|---|---|
| **២២៩- សំពត់ក្បិន ចំហៀង** | ប្រភេទសំពត់សម្រាប់ស្លៀកចងក្បិនដោយចាប់ជាយទាំងពីរដាក់ខាងលើផ្ចិត ក្របួចចងឱ្យជាប់ រួចមូរផ្នែកចំហៀងខាងឆ្វេងជាកន្ទុយក្បិន វាត់ទៅក្រោយនិងចុកនៅធ្នុកក្បិន ឯផ្នែកចំហៀងខាងស្តាំបត់ជាភ្លីចុកពីមុខ រួចយកខ្សែ-ក្រវាត់មកពាក់ពីលើ។ បើគេមើលសំពត់ក្បិនចំហៀងពីក្រោយ ឃើញដូចជាទម្រង់សំពត់ក្បិន តែបើគេមើលចំពីមុខ ឃើញដូចជាទម្រង់សំពត់សម្លុយ។ គេឃើញក្បាច់ចម្លាក់លោតឬចម្លាក់ក្រឡោតនៃរូបបដិមាស្លៀកសំពត់ក្បិនចំហៀងជាច្រើនតាំងនៅសារមន្ទីរជាតិភ្នំពេញគឺមានតាំងពីសម័យនគរភ្នំ សម័យចេនឡា និងសម័យអង្គរ ជាដើម។ |
| **២៣០- សំពត់ក្បិនតួនាយរោង** | ប្រភេទសំពត់សម្រាប់តួនាយរោង(របាំល្ខោនបុរាណ...) ស្លៀកពទ្ធពីក្រោយមកមុខចាប់ចុងស្មើគ្នា រួចខ្ទាស់ជាយដោយកន្លាស់ត្រង់ចំណុចខាងលើផ្ចិត ទើបចាប់ចុងជាយទាំងពីរខាងជីបភ្លីរួមគ្នាឱ្យមានផ្នត់តាមលំដាប់សមរម្យប្រកបតាមក្បួនស្លៀកក្បិន ដោយយកចុកជាយកន្ទុយក្បិនវាត់ទៅក្រោយ ទៅក្នុងខ្សែចំណងត្រង់កន្លែងធ្នុកក្បិន រួចទាញសាច់សំពត់ឱ្យប៉ោងនិងហាប់ណែនដើម្បីរំលេចជើងខោទាំងពីរ ហើយ ទាញភ្លីម្ខាងទម្លាក់ចុះទៅក្រោយ កើតចេញជាកន្ទុយ ហៅថា កន្ទុយប្រា (កន្ទុយត្រីប្រា) ឬ កន្ទុយក្បិនទម្លាក់។ |

| | |
|---|---|
| **២៣១- សំពត់ក្បិន តួយក្ស** | ប្រភេទសំពត់សម្រាប់តួយក្ស (របាំ ល្ខោន បុរាណ...) ស្លៀកព័ទ្ធពីក្រោយមកមុខ ចាប់ចុងស្មើគ្នា រួចខ្វាស់ជាយដោយកន្លាស់ត្រង់ចំណុចខាងលើផ្ចិត ទើបចាប់ចុងជាយទាំងពីរខាងជីបភ្លីរួមគ្នាឱ្យមានផ្នត់តាមលំដាប់សមរម្យប្រកបតាមក្បួនស្លៀកក្បិន ដោយយកចុកជាយកន្ទុយក្បិនវាត់ទៅក្រោយ ទៅក្នុងខ្សែចំណងត្រង់កន្លែងផ្នកក្បិន រួចទាញសាច់សំពត់ឱ្យប៉ោងនិងហាប់ណែន ដើម្បីរំលេចជើងខោទាំងពីរ។ |
| **២៣២- សំពត់ក្បិន តួស្វាក្បាច់** | ប្រភេទសំពត់សម្រាប់តួស្វាក្បាច់(របាំល្ខោន បុរាណ...)ស្លៀកពទ្ធពីក្រោយមកមុខ ចាប់ចុងស្មើគ្នា រួចខ្វាស់ជាយដោយកន្លាស់ត្រង់ចំណុចខាងលើផ្ចិត ទើបចាប់ចុងជាយទាំងពីរខាងជីបភ្លីរួមគ្នាឱ្យមានផ្នត់តាមលំដាប់សមរម្យប្រកបតាមក្បួនស្លៀកក្បិន ដោយយកចុកជាយកន្ទុយក្បិនវាត់ទៅក្រោយ ទៅក្នុងខ្សែចំណងត្រង់កន្លែងផ្នកក្បិន ដោយទាញសាច់សំពត់ឱ្យប៉ោងនិងហាប់ណែនដើម្បីរំលេចជើងខោទាំងពីរ និងមានបំពាក់កន្ទុយលម្អដោយប៉ាក់ឱនដេររឹបចង្កេះពីលើ រួចពាក់ខ្សែក្រវាត់ពីលើ។ |

| | |
|---|---|
| **២៣៣- សំពត់ក្រនៀវ / សំពត់ផ្កាកន្ត្រើយ** | ប្រភេទសំពត់ធ្វើពីសរសៃសូត្រឬអំបោះ ដោយវេញឱ្យខ្មាញ់និងត្បាញបញ្ចូលគ្នា ដើម្បីឱ្យមានពណ៌ត្របាញ់ប្រជេញគ្នាដូចផ្កាកន្ត្រើយ (ប្រើពណ៌ចាប់ពី៣ពណ៌ឡើងទៅ)។ |
| **២៣៤- សំពត់ខៀន** | ប្រភេទសំពត់ទេសឯកឬផាឱបនាំចូលពីបរទេស មានសាច់រឹង ផ្ទៃពណ៌ផ្សេងៗ និង មានពុម្ពជារូបផ្កាល្អិតៗ ដែលស្ត្រីខ្មែរវ័យចំណាស់ជាពិសេសនៅខេត្តបាត់ដំបងនិងខេត្តសៀមរាបនិយមស្លៀកចងក្បិនចូលរួមក្នុងពិធីបុណ្យទាននានា។ |
| **២៣៥- សំពត់តួនាង** | ប្រភេទសំពត់សារបាប់សម្រាប់តួនាងស្លៀករាំក្នុងរបាំល្ខោនបុរាណ ដោយស្លៀកចាប់ជាយបត់ក្លីជាផ្នត់ៗទាំងពីរខាង រួចប្រើខ្សែក្រវាត់ខឹមខាត់ពទ្ធពីលើជាលម្អនិងទាញជាយសំពត់ខាងឆ្វេងចេញជាទម្រង់ផ្លិត។ |
| **២៣៦- សំពត់ទេស/ សំពត់ទេសឯក** | ប្រភេទសំពត់ត្បាញពីអំបោះឆៅដែលមានសាច់ស្តើង ម៉ដ្ឋ និង ទន់រលោង។ |
| **២៣៧- សំពត់បញ្ជពណ៌** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រដោយចងគាធលើកគោមមានពណ៌ចាប់ពី៥ ឆ្លុះប្រជេញគ្នា។<br>ឲ. នៅសម័យបុរាណ នាម៉ឺន មន្ត្រី គហបតី និង អភិជន និយមស្លៀកសំពត់បញ្ជពណ៌។ |

| | |
|---|---|
| | សម័យបច្ចុប្បន្ន ក្នុងពិធីបុណ្យជាតិ បុណ្យប្រពៃណី ឥស្សរជនគួរស្លៀកសំពត់បញ្ចពណ៌នេះឡើងវិញ។ |
| **២៣៨- សំពត់បញ្ចរង្គ** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រដោយចងគាធលើកគោមរចនាជារូបភាពផ្សេងៗ ដែលមានខ្សែទឹកមាសចំនួន៤ និង ទឹកប្រាក់១ ឬ ខ្សែទឹកប្រាក់៣ និង ទឹកមាស២ កាត់ទទឹងនៅចន្លោះរូប។ |
| **២៣៩- សំពត់ផាមួង** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រ មានសាច់លាតនិងពណ៌ផ្សេងៗ ជួនមានបន្តក់ជរជើង និង មានបន្តក់លើផ្ទៃសំពត់។ សំពត់ដែលមានបន្តក់ឬជរជើងត្បាញពីអំបោះសម្រាប់ស្លៀកពេលថ្ងៃ។<br>ចំណែកសំពត់ដែលមានបន្តក់ឬជរជើង ត្បាញពីខ្សែពណ៌ទឹកមាសឬទឹកប្រាក់ មានពន្លឺចែងចាំងសម្រាប់ស្លៀកនៅពេលយប់។ |
| **២៤០- សំពត់ផាមួង ពណ៌ក្រហម** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រ មានសាច់លាតពណ៌ក្រហម តំណាងឱ្យព្រះអាទិត្យ សម្រាប់ស្លៀកនៅថ្ងៃអាទិត្យ។ |
| **២៤១- សំពត់ផាមួង ពណ៌ខៀវ** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រ មានសាច់លាតពណ៌ខៀវ តំណាងឱ្យព្រះសុក្រ សម្រាប់ស្លៀកនៅថ្ងៃសុក្រ។ |

| | |
|---|---|
| **២៤២- សំពត់ផាមួង ពណ៌ត្រួយចេក** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រ មានសាច់លាតពណ៌ត្រួយចេក តំណាងឱ្យព្រះព្រហស្បតិ៍ សម្រាប់ស្លៀកនៅថ្ងៃព្រហស្បតិ៍។ |
| **២៤៣- សំពត់ផាមួង ពណ៌ត្រួយល្វៀប** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រ មានសាច់លាតពណ៌ត្រួយល្វៀប តំណាងឱ្យព្រះពុធ សម្រាប់ស្លៀកនៅថ្ងៃពុធ។ |
| **២៤៤- សំពត់ផាមួង ពណ៌ព្រីងទុំ** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រ មានសាច់លាតពណ៌ព្រីងទុំ តំណាងឱ្យព្រះសៅរ៍ សម្រាប់ស្លៀកនៅថ្ងៃសៅរ៍។ |
| **២៤៥- សំពត់ផាមួង ពណ៌ស្លាទុំ** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រ មានសាច់លាតពណ៌លឿងទុំតំណាងឱ្យព្រះចន្ទ សម្រាប់ស្លៀកនៅថ្ងៃចន្ទ។ |
| **២៤៦- សំពត់ផាមួង ពណ៌ស្វាយ** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រ មានសាច់លាតពណ៌ស្វាយ តំណាងឱ្យព្រះអង្គារ សម្រាប់ស្លៀកនៅថ្ងៃអង្គារ។ |
| **២៤៧- សំពត់ព្រៃ/ព្រៃលាត** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រពណ៌ស មានសាច់ដិតម៉ដ្ឋរលីងរលើប។ សំពត់នេះ គេនិយមនាំចូលពីប្រទេសចិន ជាពិសេសពីទីក្រុងសៀងហៃ។ ពេលមកដល់ប្រទេសខ្មែរ គេយកសំពត់នេះមកបញ្ជាន់លក្តពណ៌ខ្មៅ រួចដំនឹងញញួរឈើដោយកម្លាំងបុរស។ពេលសាកពណ៌ |

| | |
|---|---|
| | (ហើរពណ៌) គេយកសំពត់នោះទៅជ្រលក់ទឹកផ្លែមក្លឿ រួចហាលលើដីស្ងួត ដែលគេហៅថា «ផ្តេកមក្លឿ»។ សំពត់នេះសម្រាប់ស្លៀកក្នុងជីវភាពសាមញ្ញ។ |
| **២៤៨- សំពត់ព្រៃផ្កា** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រ មានផ្ទៃពណ៌សនិងមានរំលេចផ្កាពណ៌ស។ មុនពេលប្រើប្រាស់ គេយកសំពត់នេះមកបញ្ជាន់លក្តពណ៌ខ្មៅ រួចដំនឹងញញួរឈើដោយកម្លាំងបុរស។ |
| **២៤៩- សំពត់ព្រៃអំបោះ** | ប្រភេទសំពត់ត្បាញពីសរសៃអំបោះ មានផ្ទៃពណ៌ស។ គេយកសំពត់នេះមកបញ្ជាន់លក្តពណ៌ខ្មៅ។ ពេលសាកពណ៌(ហើរពណ៌) គេយកសំពត់នោះទៅជ្រលក់ទឹកផ្លែមក្លឿ រួចហាលលើដីស្ងួត ដែលគេហៅថា«ផ្តេកមក្លឿ»។ សំពត់នេះសម្រាប់ស្លៀកក្នុងជីវភាពសាមញ្ញ។ |
| **២៥០- សំពត់លើកខ្នង់** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រដោយចងគាធ លើកគោមរចនាជារូបភាពផ្សេងៗ ដូចជារូបកូនហ៊ីងឬពងហ៊ីងជាដើម ដែលមានខ្សែកាត់កាត់ទទឹងធំៗ។ |
| **២៥១- សំពត់ល្បើក** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រដែលត្បាញលើកសាច់ដោយសរសៃអំបោះ រំលេចក្បាច់ជា |

| | |
|---|---|
| | រូបសត្វឬផ្កាល្អិតៗ លម្អពាសពេញផ្ទៃសំពត់ និង មានជរជើងធ្វើពីសរសៃអំបោះ សម្រាប់បុរសនិងស្ត្រីស្លៀកនៅពេលថ្ងៃ។ |
| **២៥២- សំពត់សម្លុយ** | ប្រភេទសំពត់បត់ជាពីរតាមបណ្ដោយធ្មេញឈើឱ្យសម្រុងត្រួតគ្នា ដោយដេរភ្ជាប់បិទមុខ សម្រាប់ស្លៀកទម្លាក់ជាយម្ខាងចុះក្រោមទាំងអស់។ |
| **២៥៣- សំពត់ សារបាប់** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រមានសាច់ក្រាស់ធ្ងន់ រំលេចក្បាច់ដោយខ្សែទឹកមាសឬទឹកប្រាក់។ សម័យដើម គេប្រើជាសម្លៀកបំពាក់សម្រាប់ព្រះមហាក្សត្រគ្រងក្នុងព្រះរាជពិធី។ បច្ចុប្បន្ន ខ្មែរប្រើសំពត់សារបាប់ជាសម្លៀកបំពាក់សម្រាប់កូនក្រមុំឬកូនកម្លោះស្លៀកពាក់ក្នុងពិធីមង្គលការ និង សម្រាប់អ្នករបាំបុរាណឬសិល្បកររល្ខោនបាសាក់ដែលដើរតួអង្គតំណាងឱ្យវណ្ណៈខ្ពង់ខ្ពស់។ អ្នកខ្លះហៅ ចរបាប់ ចារបាប់ ឬ ជរបាប់។ |
| **២៥៤- សំពត់ស៊ឹង** | ប្រភេទសំពត់ត្បាញពីអំបោះ មានក្បាច់ ឬឆ្នូតទទឹងនៅតាមជាយស្រដៀងគ្នានឹងស៊ឹងលាវ ប៉ុន្តែស៊ឹងលាវខុសគ្នាត្រង់មានដេរបន្ថែមជរនៅជើងសំពត់។ សំពត់នេះ ខ្មែរប្រើក្នុងជីវភាពរស់នៅធម្មតា ឬ ក្នុងការសម្ដែងរបាំគែន និង របាំក្ងោកប៉ៃលិន...។ គេឃើញមានសិប្បកម្មត្បាញ |

| | |
|---|---|
| | សំពត់ស៊ីង តែនៅតំបន់ព្រៃកហ្លួងទេក្នុងទស-វត្សរ៍ទី៦និងទី៧នៃសតវត្សរ៍ទី២០។ |
| **២៥៥- សំពត់ហូល** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រ ដោយចងគាធលើកគោមតូចឬធំ រចនាជារូបភាពតាមធម្មជាតិច្រើនបែបយ៉ាង។ សំពត់ហូលសម្រាប់ស្ត្រីមានគោមតូចៗដូចជា រូបផ្កាម្ទេស ផ្កាទទឹមសត្វពីងពាង សត្វអណ្តើក ជាដើម។ សម្រាប់បុរសស្លៀក គេលើកគោមធំៗមាន រូបសត្វដំរីសត្វនាគ សត្វហង្ស សត្វគ្រុឌ។ |
| **២៥៦- សំពត់អង្រ្កែម អង្រ្កម** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រឬអំបោះរចនាជាឆ្នូតៗបណ្តោយសម្រុងដែលចាក់ជាក្រឡាបួនជ្រុងល្អិតៗ លាយពណ៌ក្រហមនិងខ្មៅឆ្លាស់គ្នា ស្រដៀងនឹងសម្បុរគ្រាប់អង្រ្កែមអង្រ្កមទុំ (សៀមហៅថា អន្លូញមក្លាំ)។ |
| **២៥៧- សំពត់អន្លូញ** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រឬអំបោះរចនាជាឆ្នូតៗបណ្តោយសម្រុងដែលមានពណ៌ឆ្លាស់គ្នាចាប់ពី២ពណ៌ឡើងទៅ សម្រាប់ស្ត្រីស្លៀកប្រចាំថ្ងៃ។ សំពត់អន្លូញមានឈ្មោះផ្សេងៗដូចជា សំពត់អន្លូញបន្តក់, សំពត់អន្លូញជរដើង, សំពត់អន្លូញបន្តក់ជរដើង, សំពត់អន្លូញអង្រ្កែមអង្រ្កម, សំពត់អន្លូញប៉ប៉ក ជាដើម។ |

| | |
|---|---|
| **២៥៨- សំពត់អន្លូញជរជើង** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រឬអំបោះ រចនាជាឆ្នូតៗបណ្ដោយសម្រុងដែលមានពណ៌ឆ្លាស់គ្នាចាប់ពី២ពណ៌ឡើងទៅ ដែលមានការរចនាត្រង់ផ្នែកជើងសំពត់ ដោយត្បាញរំលេចពីអំបោះ។ |
| **២៥៩- សំពត់អន្លូញបន្តក់** | ប្រភេទសំពត់ត្បាញពីសរសៃសូត្រឬអំបោះ រចនាជាឆ្នូតៗបណ្ដោយសម្រុងដែលមានពណ៌ឆ្លាស់គ្នាចាប់ពី២ពណ៌ឡើងទៅ ដោយមានបន្តក់ផ្កាតូចៗ ត្បាញពីអំបោះរំលេចលើផ្ទៃ។ |
| **២៦០- សំពត់អន្លូញប៉ប៉ក** | ប្រភេទសំពត់ត្បាញពីសរសៃអំបោះ រចនាជាឆ្នូតៗបណ្ដោយសម្រុងដែលមានពណ៌សឆ្លាស់ពណ៌ខ្មៅ សាច់គ្រើមៗ។ |
| **២៦១- សំពត់អំបោះឆៅ** | ប្រភេទសំពត់ដែលខ្មែរត្បាញពីអំបោះឆៅ ដោយឱ្យបាយជូរ។ |
| **២៦២- ស្នាប់ដៃ** | គ្រឿងអលង្ការមួយយ៉ាងធ្វើពីលោហៈ មានសណ្ឋានជាបន្ទះកោង មានដាំត្បូង ឆ្លាក់រំលេចក្បាច់គ្របកឈូកអង្គរឬក្បាច់ផ្សេងៗ និង មានខ្សែនៅចុងទាំងពីរខាង សម្រាប់ចងភ្ជាប់ពាក់នៅលើដើមដៃនៃតួនាង។ |
| **២៦៣- ស្បៃ** | ប្រភេទកំណាត់មួយផ្ទាំងប៉ាក់ឱនជាក្បាច់ចក្កច័ន មានលម្អដោយរំយោលនៅចុងជាយ |

| | |
|---|---|
| | ម្ខាង ប្រើក្នុងរបាំបុរាណ សម្រាប់តួនាងពាក់លើអាវដៃម្ខាង ដោយរុំលើដងខ្លួនវាត់មកលើស្មាឆ្វេង និង ទម្លាក់ចុងជាយមកក្រោយបាំងត្រឹមត្រគាក។ |
| **២៦៤- ស្នាច់** | ១- បច្ចេកទេសមួយប្រភេទក្នុងសិល្បៈសូនរូប ដោយប្រើក្រដាសប៉ុយឬសរសៃ ឬ ក្រដាសធម្មតា តែត្រូវញីឱ្យទក់ រួចលាបបាយម៉ាន បិទជាប់នឹងពុម្ពជាន់ៗលើគ្នា ដើម្បីយករាងអ្វីមួយដែលយើងចង់បាន។<br>២- បច្ចេកទេសមួយប្រភេទសម្រាប់ធ្វើឧបករណ៍ប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ ដូចជា ចាន កែវ ចានលាងដៃ កាណូត ទូកម៉ាស៊ីន កង្ហារ... ដោយយកសរសៃនីឡុងទៅពង្រាយក្នុងពុម្ព រួចបិទត្រួតៗលើគ្នា បន្ទាប់មក បិទការ ដើម្បីយករាងអ្វីមួយដែលយើងចង់បាន។ ពេលស្ងួត គេបកឬគាស់ពុម្ពចេញ រួចតុបតែងលម្អ ជាការស្រេច។ |
| **២៦៥- ស្រទាប់វប្បធម៌**<br>អ. cultural layer<br>បារ. strate culturelle (f.) | ស្រទាប់ដីដែលមានសំណល់សកម្មភាពមនុស្ស មានដូចជា បុរាណវត្ថុសិល្បៈ បុរាណអចលនវត្ថុ បុរាណជីវវត្ថុ បុរាណភូគព្ភវត្ថុ រចនាសម្ព័ន្ធសំណង់ជាដើម ដែលអាចឱ្យយើងយល់ដឹង និងបែងចែកសម័យកាលនីមួយៗដាច់ដោយឡែកៗពីគ្នា។ |

| | |
|---|---|
| **២៦៦- ស្លឹកទេស** | គ្រឿងប្រដាប់ដៃមួយប្រភេទ ជាខ្សែដៃដែលលម្អដោយក្បាច់សន្លឹកជាច្រើន ធ្វើពីលោហៈរាងជាផ្លិតបើកស្មើរពាក់កណ្តាលរង្វង់ ដាំត្បូង៣ឬ៥គ្រាប់ ចងភ្ជាប់នឹងខ្សែ ទម្លាក់ជារំយោលព័ទ្ធជុំវិញកដៃចំនួន២ខ្សែម្ខាង សម្រាប់ឱ្យអ្នករបាំបុរាណខ្មែរពាក់នៅផ្នែកខាងចុងផុតនៃកដៃ។ |
| **២៦៧- ស្លឹកពោធិ៍** | គ្រឿងអលង្ការមួយយ៉ាងធ្វើពីបន្ទះលោហៈមានសណ្ឋានដូចក្បាច់ចក្កច័ន (ចតុកោណស្មើ) ដោយមានរចនាជាក្បាច់ផ្សេងៗ សម្រាប់ដាក់ភ្ជាប់លើសង្វារព័ន្ធត្រង់កន្លែងខ្វែងនៅផ្នែកខាងមុខលើចុងដង្ហើម។ |
| **២៦៨- អាវដៃម្ខាង** | ប្រភេទអាវកាក់ធ្វើពីក្រណាត់សាច់លាត ពណ៌ផ្សេងៗដែលមានតែដៃឆ្វេង សម្រាប់តួនាងពាក់ជាទ្រនាប់ស្បៃ។ |
| **២៦៩- អាវតូច** | ប្រភេទអាវកវៀល ដៃប៉ិត ពាក់រឹបរាងជាប់ដងខ្លួន មានទ្បេវញ៉ើកចំពីមុខ លម្អដោយប៉ាក់ឱនតិចតួចនៅជាយ-ក ជាយដៃ និង ទ្រូងអាវសម្រាប់តួនាង តួនាយរោង និង តួយក្ស ពាក់ហាត់រាំនិងសម្តែង។ អ្នករបាំខ្លះហៅអាវប្រភេទនេះថា អាវណោយ តាមភាសាសៀម។ |
| **២៧០- អាវតួនាយរោង** | ប្រភេទអាវដៃបំពង់ប៉ាក់ឱន មានរចនាក្បាច់ចក្កច័នពាសពេញផ្ទៃអាវនិងដៃអាវ។ នៅពេលពាក់ ទើបគេដេរឱ្យតឹងណែនរឹបចេញរាង ចាប់ពីដៃរហូតដល់ដងខ្លួន។ |

| | |
|---|---|
| **២៧១- អាវតួយក្ស** | ប្រភេទអាវដៃបំពង់ប៉ាក់ឱិន មានរចនាក្បាច់ចក្កច័នពាសពេញផ្ទៃអាវនិងដៃអាវ។ នៅពេលពាក់ ទើបគេដេរឱ្យតឹងណែនរឹបចេញរាងចាប់ពីដៃរហូតដល់ដងខ្លួន។ |
| **២៧២- អាវតួស្វាក្បាច់** | ប្រភេទអាវដៃបំពង់ប៉ាក់ឱិន មានរចនាក្បាច់ហៀនពាសពេញផ្ទៃអាវនិងដៃអាវ។ នៅពេលពាក់ ទើបគេដេរឱ្យតឹងណែនរឹបចេញរាង ចាប់ពីដៃរហូតដល់ដងខ្លួន។ |
| **២៧៣- អាវសន្ទះ** | ប្រភេទអាវដៃខ្លី កម្ងល ធ្វើពីកំណាត់ធម្មតា មានសន្ទះពីក រហូតដល់ដើមទ្រូង មានរន្ធឡេវចំនួន៣ សម្រាប់តួប្រុសពាក់ក្នុងពេលហាត់។ |
| **២៧៤- ឥន្ទធនូ អាវតួនាយរោង** | គ្រឿងលម្អធ្វើពីកំណាត់ប៉ាក់ឱិននៅលើស្មាអាវ មានសណ្ឋានជាស្នែងក្របីដែល មានអំបោះប៉ាក់ចងជារាងផ្កាផ្ទុកថ្នាំ លម្អនៅផ្នែកខាងចុង សម្រាប់តួនាយរោង។ |
| **២៧៥- ឥន្ទធនូ អាវតួយក្ស** | គ្រឿងលម្អធ្វើពីកំណាត់ប៉ាក់ឱិន មានសណ្ឋានជាក្បាលនាគ នៅលើស្មាអាវតួយក្ស ក្នុងរបាំបុរាណ។ |

**បោះពុម្ពលើកទី១ ចំនួន ១ ៥០០ច្បាប់**

**នៅរោងពុម្ព ស៊ី យូ**

ផ្ទះលេខ ៣៨CEo មហាវិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ